សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ROYAL UNIVERSITY OF LAW AND ECONOMICS

**សារណាបញ្ចប់ការសិក្សា**

# គោលនយោបាយសារពើពន្ធ

**ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤**

**ស្រាវជ្រាវដោយ**

**និស្សិតឈ្មោះ៖** កញ្ញា ស្រ៊ុន ស្រីពេជ្រ

លោក ជ័យ លិ

**ណែនាំដោយ**

**សាស្ត្រាចារ្យបណ្ឌិត** ស្រ៊ុន សុភ័ក្ត្រ

**ថ្នាក់បរិញ្ញាបត្រ៖ សេដ្ឋកិច្ចអភិវឌ្ឍន៍**

**ជំនាន់ទី ០៨**

**ឆ្នាំចូលសិក្សា** ២០២០

**ឆ្នាំសរសេរសារណា** ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ស្រ៊ុន ស្រីពេជ្រ** និង **ជ័យ លិ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញ **សេដ្ឋកិច្ចអភិវឌ្ឍន៍** ជំនាន់ទី៨ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ក្នុងការសរសេរសារណាបញ្ចប់ការសិក្សាលើប្រធានបទ **"គោលនយោបាយសារពើពន្ធ"** យើងខ្ញុំសូធ្វើការគោរពជូន និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនដូចតទៅៈ

ជាបឋមយើងខ្ញុំសូមសំសម្តែងនូវការដឹងគុណ និងការគោរពដ៏ខ្ពង់ខ្ពស់ចំពោះអ្នកមានគុណទាំងពីរ នូវគុណដ៏ធំធេងពីរគឺ ជាតិគុណ និងឧបការគុណដែលលោកទាំងពីរបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ព្រមទងអប់រំទូន្មានប្រៀនប្រដៅដែលពិសេសនោះគឺ លោកទាំងពីរបានខិតខំប្រឹងប្រែងទាំងកម្លាំងកាយ កម្លាំងចិត្ត និងធនធានទំនុកបម្រុងការសិក្សាតាំងពី ថ្នាក់បឋម រហូតដល់ថ្នាក់បរិញ្ញាបត្រ ដែលជាថ្នាក់ឧត្តមសិក្សានេះ។

លោកសាស្ត្រាចារ្យបណ្ឌិត **ស្រ៊ុន សុភ័ក្រ្ត** ដែលបានជួយជ្រោមជ្រែង ដឹកនាំ និងផ្តល់ជាទស្សនៈល្អៗ ហើយបានកែតម្រូវរាល់កំហុសខុសឆ្គង ដែលមាននៅក្នុងសារណាបញ្ចប់កាសិក្សានេះ ចាប់តាំងពីចំណុចចាប់ផ្តើមរហូតទទួលបានជោគជ័យទោះបីជាមានពេលវេលាតិចតួចស្តួចស្តើងយ៉ាងណាក៏ដោយ។

លោកគ្រូ **ង៉ាន់ ស៊ុនដេត** ដែលបានខិតខំបង្ហាត់បង្រៀនវិធីសាស្ត្រស្រាវជ្រាវ និងជួយណែនាំអំពីរបៀបសរសេរសារណា។

ជាមួយគ្នានេះដែរ យើងខ្ញុំសូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅដល់ការចូលរួមចំណែកដល់ការសិក្សាអស់រយៈពេល៤ឆ្នាំកន្លងមកចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ ព្រឹទ្ធបុរស សាស្ត្រាចារ្យ** និងបុគ្គលិកដែលកំពុងបម្រើការនៅសាកលវិទ្យាល័យទាំងអស់ព្រមទាំងមិត្តរួមថ្នាក់ដែលបានសិក្សាជាមួយគ្នាកន្លងមកឲ្យជួបតែពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេលបួនឆ្នាំកន្លងមក យើងខ្ញុំបានទទួលនូវចំណេះដឹងយ៉ាងច្រើនពីសាស្ត្រាចារ្យដែលបានបង្ហាត់បង្រៀនផ្នែកសេដ្ឋកិច្ចនិងគោលនយោបាយជាច្រើនទាំងផ្នែកទ្រឹស្តី និងផ្នែកអនុវត្ត។ នៅក្នុង ពេលសិក្សា ពេលអានអត្ថបទទាក់ទងប្រធានបទសេដ្ឋកិច្ចនានា យើងខ្ញុំមានការចាប់អារម្មណ៍ជាងគេទៅលើការ អនុវត្តគោលនយោបាយសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗ មានការអនុវត្តគោលនយោបាយសារពើពន្ធបានចូលរួម នៅក្នុងការដោះស្រាយបញ្ហាវិបត្តិសេដ្ឋកិច្ចនាឆ្នាំ២០០៨ និងបញ្ហាសេដ្ឋកិច្ចដែលបណ្តាលមកពីការរាតត្បាតនៃ ជំងឺកូវីដ១៩នាពេលថ្មីៗនេះជាដើម។ ការអនុវត្តគោលនយោបាយសារពើពន្ធ បានចូលរួមចំណែកនៅក្នុងការ ជំរុញកំណើន រក្សាស្ថេរភាពសេដ្ឋកិច្ច និងអភិវឌ្ឍប្រទេសកម្ពុជា ជាពិសេសក្នុងការដោះស្រាយបញ្ហាសេដ្ឋកិច្ច បណ្តាលមកពីការរាតត្បាតនៃជំងឺកូវីដ១៩។ អាស្រ័យហេតុនេះហើយ ទើបយើងខ្ញុំសម្រេចចិត្តសាកល្បងសិក្សា ស្រាវជ្រាវលើប្រធានបទ "គោលនយោបាយសារពើពន្ធ" ដោយពិនិត្យ មើលទាំងទិដ្ឋភាពភាពទ្រឹស្តីមួយចំនួន និងការអនុវត្តជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា។

បន្ទាប់ពីទទួលបានសន្តិភាពពេញលេញនាឆ្នាំ ១៩៩៨ ប្រទេសកម្ពុជាបានចាប់ផ្តើមអភិវឌ្ឍជាលំដាប់ដែលធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាទទួលបានការរីកចម្រើនគួរឱ្យកត់សម្គាល់ តែក៏នៅប្រឈមនឹងហានិភ័យមួយចំនួននៅឡើយ។ ត្បិតថាសេដ្ឋកិច្ចកម្ពុជាត្រូវប្រឈមនឹងភាពមិនប្រាកដប្រជាយ៉ាងណាក្តី ជាពិសេសត្រូវប្រឈមនឹងវិបត្តិហិរញ្ញវត្ថុនិងសេដ្ឋកិច្ចពិភពលោកនៅឆ្នាំ ២០០៨ ក៏កម្ពុជានៅតែអាចសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាជាមធ្យមប្រមាណ ៧% ក្នុងមួយឆ្នាំ។ លទ្ធផលដ៏ល្អនេះបណ្តាលមកពីការខិតខំដាក់ចេញនូវគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជារួមមានផែនការចំណាយ និងផែនការប្រមូលចំណូលយ៉ាងយកចិត្តទុកដាក់សមស្របតាមលក្ខខណ្ឌសេដ្ឋកិច្ចកម្ពុជាដើម្បីជំរុញកំណើនសេដ្ឋកិច្ចជាតិ។

យើងខ្ញុំសង្ឃឹមថា ឯកសារស្រាវជ្រាវមួយនេះនឹងក្លាយជាឯកសារផ្តល់ប្រយោជន៍ដល់មិត្តនិស្សិត និងអ្នកសិក្សាស្រាវជ្រាវក្រោយៗក្នុងការសិក្សាបន្តទៀតពីលើស្នាដៃមួយនេះ។ ជាចុងក្រោយ យើងខ្ញុំទាំងពីរសូមអភ័យទោសទុកជាមុនចំពោះលោកគ្រូ អ្នកគ្រូ អ្នកអាន និងអ្នកសិក្សាទាំងអស់សម្រាប់ចំណុចខ្វះខាត ឬកំហុសអក្ខរាវិរុទ្ធ និងមិនច្បាស់អត្ថន័យត្រង់កន្លែងឯណានីមួយ ត្បិតថាយើងខ្ញុំខិតខំពិនិត្យពិច័យល្អិតល្អន់យ៉ាងណាក៏ដោយ ឯកសារនេះនៅតែមានចំណុចខ្វះខាតជាក់ជាមិនខាន។ អាស្រ័យហេតុនេះ សូមអ្នកអានអ្នកសិក្សាមេត្តាអធ្យាស្រ័យដល់យើងខ្ញុំផង។ យើងខ្ញុំសូមទទួលយកនូវរាល់ការរិះគន់ក្នុងន័យស្ថាបនាទាំង អស់ដើម្បីជួយឱ្យឯកសារស្រាវជ្រាវមួយនេះកាន់តែល្អប្រសើរ។

# មាតិកា

ទំព័រទី៖

បញ្ជីក្រាហ្វិក ........ IV

បញ្ជីតារាង ........ V

បញ្ជីអក្សរកាត់ ........ VI

# សេចក្តីផ្តើម

ទំព័រទី៖

១. លំនាំបញ្ហា នៃការស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហា នៃការស្រាវជ្រាវ ........ ៣

៣. គោលបំណង នៃការស្រាវជ្រាវ ........ ៤

៤. ទំហំនិងដែនកំណត់ នៃការស្រាវជ្រាវ ........ ៥

៥. សារៈសំខាន់ នៃការស្រាវជ្រាវ ........ ៥

៦. វិធីសាស្ត្រ នៃការស្រាវជ្រាវ ........ ៥

# ជំពូកទី ១

## រំលឹកទ្រឹស្តី( ទ្រឹស្តីគោលនយោបាយសារពើពន្ធ )

១.១.និយមន័យ ........ ៦

១.១.១.គោលនយោបាយសារពើពន្ធ ........ ៦

១.១.២.លោក ( Adam Smith & Mathus ) ........ ៦

១.២.ឧបករណ៍គោលនយោបាយសារពើពន្ធ ........ ៧

១.២.១.ចំណូលថវិការដ្ឋ ........ ៨

១.២.២.ចំណាយរដ្ឋាភិបាល ........ ៩

១.២.៣.ចំណុលសាធារណៈ ........ ១៤

១.៣.ការអនុវត្តគោលនយោបាយសារពើពន្ធ ........ ១៥

## ជំពូកទី ២

## ស្ថានភាពសេដ្ឋកិច្ច និងគោលនយោបាយសារពើពន្ធនៅកម្ពុជា

២.១.ការវិវត្តថ្មីៗនៃសេដ្ឋកិច្ចកម្ពុជា ........ ១៨

២.១.១.ផលិតផលក្នុងស្រុកសរុប ( GDP ) ........ ១៩

២.១.២.ការវិនិយោគ ( Investment ) ........ ២១

២.១.៣.ពាណិជ្ជកម្មអន្តរជាតិ ( International Trade ) ........ ២៣

២.១.៤.ចំណាយរដ្ឋាភិបាល និងចំណូលរដ្ឋាភិបាល ........ ២៨

២.១.៥.អតិផរណា ........ ២៨

២.២.ស្ថានភាពទូទៅនៃគោលនយោបាយសារពើពន្ធ ........ ២៩

២.៣.ការអនុវត្តគោលនយោបាយសារពើពន្ធនៅកម្ពុជា ........ ៣៣

២.៣.១.អគ្គនាយកដ្ឋានគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ........ ៣៤

២.៤.ឧបករណ៍គោលនយោបាយសារពើពន្ធនៅកម្ពុជា ........ ៣៥

២.៤.១.ចំណូលសារពើពន្ធ ........ ៣៦

២.៤.២.ចំណូលមិនមែនសារពើពន្ធ ........ ៣៧

២.៤.៣.ចំណាយសាធារណៈ ........ ៣៨

២.៥.យុទ្ធសាស្ត្រកៀងគរចំណូល ....................................................................................... ៣៩

២.៥.១.យុទ្ធសាស្ត្រកៀងគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ....................................... ៤០

២.៥.២.យុទ្ធសាស្ត្រកៀងគរចំណូលឆ្នាំ ២០១៩-២០២៣ ....................................................... ៤១

២.៦.ការអនុវត្តគោលនយោបាយសារពើពន្ធក្នុងកំឡុងពេលវិបត្តិជំងឺកូវីដ១៩ ......... ៤៥

# ជំពូកទី ៣

## ការវិភាគ និងបកស្រាយលទ្ធផលនៃការស្រាវជ្រាវ

៣.១.លទ្ធផលនៃការស្រាវជ្រាវ ........................................................................ ៤៨

៣.២.ការប្រៀបធៀប និងផ្ទៀងផ្ទាត់លទ្ធផលស្រាវជ្រាវ ( Robustness check ) ................ ៤៩

៣.៣.ការបកស្រាយលទ្ធផល ........................................................................................ ៥៥

## សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

១.សេចក្តីសន្និដ្ឋាន ........................................................................................................ ៥៨

២.អនុសាសន៍ ................................................................................................................ ៦០

ឯកសារយោង

ឧបសម្ព័ន្ធ

# បញ្ជីក្រាហ្វិក


ក្រាហ្វិកទី១៖ គម្រោងចំណូលថវិការរដ្ឋ

ក្រាហ្វិក២៖ ចំណូលថវិការឆ្នាំ ២០២២

ក្រាហ្វិកទី៣៖ សូចនាករម៉ាក្រូសេដ្ឋកិច្ច

ក្រាហ្វិកទី៤៖ (GDP Per Capita)

ក្រាហ្វិកទី៥៖ ប្រភពទុនវិនិយោគ

ក្រាហ្វិកទី៦៖ គម្រោងវិនិយោគតាមវិស័យ

ក្រាហ្វិកទី៧៖ ស្ថិតិនាំចេញ និង ស្ថិតិនាំចូល

ក្រាហ្វិកទី៨៖ អត្រាអតិផរណា ជាមធ្យមប្រចាំឆ្នាំ

ក្រាហ្វិកទី៩៖ ចំណាយចរន្ត និងចំណាយមូលធន

ក្រាហ្វិកទី១០៖ ចំណាយចរន្តថ្នាក់ជាតិ

# បញ្ជីតារាង


តារាងទី១៖ ចំណូលថវិការឆ្នាំ ២០២១-២០២២

តារាងទី២៖ ចំណូលថវិការឆ្នាំ ២០២២

តារាងទី៣៖ ឯកតា គិតជាដុល្លារ (លានដុល្លារសហរដ្ឋអាមេរិក)

តារាងទី៤៖ ស្ថិតិនាំចេញទំនិញសំខាន់ៗ (ឯកតា៖ លានដុល្លារអាមេរិក

តារាងទី៤៖ ស្ថិតិនាំចូលទំនិញសំខាន់ៗ (ឯកតា៖ លានដុល្លារអាមេរិក)

តារាងទី៥៖ ស្ថិតិនាំចេញ ២០២២-២០២៣

តារាងទី៦៖ តារាងប្រៀបតម្លៃផលិតផលការនាំចេញពីកម្ពុជាទៅបណ្តាលប្រទេស ក្រោមប្រព័ន្ធអនុគ្រោះពន្ធពាណិជ្ជកម្ម និងពាណិជ្ជកម្មសេរីលើទីផ្សារពិភពលោក

តារាងទី៧៖ តារាងតុល្យភាពថវិការរដ្ឋ

តារាងទី៨៖ ការបង្ហាញពីទំនាក់ទំនង នៃអរថេរនីមួយ/Correlations

តារាងទី៩៖ លទ្ធផល នៃការវិភាគឥទ្ធិពលចំណាយចរន្ត ចំណាយមូលធន ចំណាយសារពើពន្ធ និងអត្រាអតិផរណា មកលើផលិតផលក្នុងស្រុកសរុបពិត

តារាងទី១០៖ លទ្ធផល នៃការវិភាគឥទ្ធិពល នៃចំណាយចរន្ត ចំណាយមូលធន ចំណូលសារពើពន្ធ និងអត្រាអតិផរណា មកលើផលិតផលក្នុងស្រុកសរុបដោយប្រើ Robustness Check

តារាងទី១១៖ ប្រៀបធៀបរវាងការប្រើប្រាស់លោការីត និងមិនប្រើប្រាស់លោការីតនៅក្នុងការវិភាគដោយប្រើ Robustness Check

## បញ្ជីអក្សរកាត់ ភាសាខ្មែរ

| | |
|---|---|
| ផ.ស.ស | ផលិតផលក្នុងស្រុកសរុប |
| ច.ណ.រ | ចំណាយចរន្ត |
| ច.ណ.ធ | ចំណាយមូលធន |
| ច.ណ.ព | ចំណូលសារពើពន្ធ |

## បញ្ជីអក្សរកាត់ ភាសាអង់គ្លេស

(Real GDP)    Real Gross Domestic Product

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា នៃការស្រាវជ្រាវ

ចាប់តាំងពីដើមឆ្នាំ២០២០ ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ នៅលើពិភពលោកបានជះឥទ្ធិពល អវិជ្ជមាននិងបញ្ហាប្រឈមនានាដល់សុខភាពប្រជាជន និងសេដ្ឋកិច្ចពិភពលោក។ ក្នុងបរិបទជំងឺកូវីដ-១៩នេះ បណ្តាប្រទេសនានាលើពិភពលោបានផ្អាកនូវសកម្មភាពសេដ្ឋកិច្ចនិងពាណិជ្ជកម្ម របស់ខ្លួនដែលធ្វើឱ្យប្រជា ជនជាច្រើនបានបាត់បង់ការងារ ប្រាក់ចំណូលធ្លាក់ចុះ ធ្លាក់នៅក្នុងភាពក្រីក្រឡើងវិញជាពិសេសសម្រាប់ប្រជាជនដែលទើបតែរួចផុតពីបន្ទាត់នៃភាពក្រីក្រ។ កម្ពុជាក៏មិនអាចគេចផុតពីការរីករាលដាលនៃជំងឺកូវីដ-១៩ និងបញ្ហាសេដ្ឋកិច្ចដែលបណ្តាលមកពីការផ្អាកនូវសកម្មភាពសេដ្ឋកិច្ចក្នុងប្រទេស និងពាណិជ្ជកម្មអន្តរជាតិនោះ ទេ។ នៅក្នុងឆ្នាំ២០១៩ សេដ្ឋកិច្ចកម្ពុជាសម្រេចបាននៅក្នុងអត្រាកំណើនជាមធ្យម ៧.១% ដែលអត្រាមួយនេះ ស្ថិតនៅក្នុងរង្វង់នៃអត្រាកំណើនសេដ្ឋកិច្ច២ទសវត្សកន្លងមកជាមធ្យម ៧% ក្នុងមួយឆ្នាំ និងផលិតផលក្នុង ស្រុកសរុបសម្រាប់មនុស្សម្នាក់ៗ (GDP Per Capita) កើនដល់ ១,៧00 ដុល្លារអាមេរិក។ ការរីករាលដាលនៃ ជំងឺកូវីដ-១៩ បានធ្វើឱ្យកំណើនសេដ្ឋកិច្ចកម្ពុជាបានធ្លាក់ចុះក្នុងអត្រាអវិជ្ជមានមួយក្នុងឆ្នាំ២០២០ គឺ -៣.១% ដែលកម្ពុជាមិនធ្លាប់ប្រទះក្នុងរយៈពេលជាង២ទសវត្សកន្លងមកហើយផលិតផលក្នុងស្រុកសរុបសម្រាប់ មនុស្សម្នាក់ៗធ្លាក់ចុះមកត្រឹម ១,៦៥៣ ដុល្លារអាមេរិកវិញ។ នៅក្នុងឆ្នាំ២០២១ សេដ្ឋកិច្ចកម្ពុជាបានចាប់ផ្តើម ងើបឡើងវិញសន្សឹមៗ ដោយសម្រេចបាននូវអត្រាកំណើនសេដ្ឋកិច្ច ៣.0% និងផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗឡើងដល់ ១,៦៥៩ ដុល្លារអាមេរិក។

ក្នុងបរិបទវិបត្តិសេដ្ឋកិច្ចជាសាកលបែបនេះរាជរដ្ឋាភិបាលកម្ពុជាបានខិតខំដាក់ចេញនូគោលនយោបាយចម្រុះក្នុងនោះមានគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយសារពើពន្ធព្រមទាំងវិធានការកែទម្រង់នានាដើម្បីដោះស្រាយនូវបញ្ហាសេដ្ឋកិច្ចព្រមទាំងស្តារឡើងវិញនូវកំណើនសេដ្ឋកិច្ច។ បន្ថែមពីលើ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវអនុក្រឹត្យបន្ថែមព្រមច្បាប់ពាក់ព័ន្ធនានាទាក់ទងនឹងការអនុគ្រោះពន្ធនិងការកាត់បន្ថចំណាយមិចាំបាច់មួយចំនួនហើយបង្វែរថវិកាទាំងនោះសម្រាប់ចំណាយសម្រាប់វិស័យសុខាភិបាលជាតម្រូវការចាំបាច់

ក្នុងការទប់ស្កាត់ជំងឺកូវីដ១៩។ ជាពិសេសទៀតរាជរដ្ឋាភិបាលកម្ពុជាបានអនុម័តចំណាយនៅក្នុងការទិញវ៉ាក់សាំងការពារជំងឺកូវីដ១៩ជាច្រើន។ សម្រាប់ផ្តល់ជូនប្រជាពលរដ្ឋទាំងមូលនៅក្នុងប្រទេសទទួលបាននូវវ៉ាក់សាំងដោយឥតគិតថ្លៃ។ ចំពោះវិស័យ ដែលទទួលរងផលប៉ះពាល់ និងអ្នកធ្វើការក្នុងវិស័យទាំងនោះដែលទទួលរងផលប៉ះពាល់ពីការបិទខ្ទប់ក្នុងអំឡុងពេលរីករាលដាលនៃជំងឺ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ការអនុគ្រោះពន្ធ និងកាតព្វកិច្ចលើកលែងពន្ធមួយចំនួនដើម្បីលើកទឹកចិត្តនៅក្នុងផលិតកម្មឡើងវិញ និងផ្តល់នូវថវិកាជាកញ្ចប់សម្រាប់អ្នកទាំងនោះ។

គោលនយោបាយសារពើពន្ធត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជាតាមរយៈច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈ សម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំដើម្បីធានាបាននូវចំណូលថវិកាជាតិចំណាយថវិកាជាតិនិងការគ្រប់គ្រងបំណុលសាធារណៈ ក្នុងកម្រិតមួយសមស្របតាមស្ថានភាពសេដ្ឋកិច្ចជាក់ស្តែងរបស់កម្ពុជាជារៀង រាល់ឆ្នាំ។ នៅក្នុងឆ្នាំ២០២១ ការគ្រប់គ្រងថវិកាជាតិនៅមានឱនភាពថវិកានៅឡើយដោយចំណាយថវិការដ្ឋសរុបនៅតែធំជាងចំណូលថវិការដ្ឋសរុប តែបញ្ហានេះមិនមែនជាហានិភ័យសម្រាប់កម្ពុជានោះទេ។ រាជរដ្ឋាភិបាលបានខិតខំដាក់គោលនយោបាយ និងយុទ្ធសាស្ត្រនានាក្នុងការប្រមូលចំណូលនិងចំណាយតាមវិស័យឱ្យមានប្រសិទ្ធភាពជាពិសេសនោះ គឺយុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈយុទ្ធសាស្ត្រកៀងគរចំណូលមធ្យម ២០១៤-២០១៨ និងយុទ្ធសាស្ត្រកៀងគរចំណូល ២០១៩-២០២៣។ ចំណែកការគ្រប់គ្រងបំណុលសាធារណៈកម្ពុជារាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ដែលធ្វើឱ្យបំណុលសាធារណៈនៅកម្ពុជានៅតែស្ថិតនៅក្នុងកម្រិតចីរភាព និងហានិភ័យទាបនៅឡើយ។

---

*ប្រភព៖ នាយកដ្ឋានថវិកានីយកម្ម នៃអគ្គនាយកដ្ឋានថវិកា របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ថវិកាសង្ខេបឆ្នាំ២០២២, ទំព័រ៥-១៨*
*អង្គការទិន្នន័យអំពីការអភិវឌ្ឍ (ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០) លោកនាយករដ្ឋមន្ត្រីអំពាវនាវឱ្យក្រសួងកាត់បន្ថយចំណាយចំពេលចំណូលពន្ធទាប[https://opendevelopmentcambodia.net/km/news/prime-minister-calls-for-ministries-to-cut-spending-amid-lower-tax-revenue/#!/story=post-141801] (អានថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៣)*

## ២. ចំណោទបញ្ហា នៃការស្រាវជ្រាវ

ដោយមើលឃើញពីសារៈសំខាន់នៃគោលនយោបាយសារពើពន្ធរួមមានចំណាយសាធារណៈ ក៏ដូចជាចំណូលសារពើពន្ធរបស់រាជរដ្ឋាភិបាលចំពោះការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាដូច្នេះវាពិតជាបង្កើន ការចំណាយ របស់រាជរដ្ឋាភិបាល និងការប្រមូលចំណូលសារពើពន្ធបានជះឥទ្ធិពលកម្រិតណានៅក្នុង ការអភិវឌ្ឍ និងកសាង កំណើនសេដ្ឋកិច្ចកម្ពុជានាពេលកន្លងមក។

ចំពោះការសិក្សាពី "គោលនយោបាយសារពើពន្ធមកលើសេដ្ឋកិច្ចប្រទេសកម្ពុជា" នេះយើងនឹងធ្វើការបកស្រាយនូវសំណួរសំខាន់ៗដូចខាងក្រោម៖

១. តើគោលនយោបាយសារពើពន្ធមានសារៈសំខាន់យ៉ាងដូចម្តេចចំពោះសេដ្ឋកិច្ចកម្ពុជា?
២. តើអតិផរណាមានឥទ្ធិពល និងទំនាក់ទំនងបែបណាមកលើកំណើនសេដ្ឋកិច្ចកម្ពុជា?
៣. តើការអនុវត្តគោលនយោបាយសារពើពន្ធរបស់រាជរដ្ឋាភិបាលសព្វថ្ងៃមានឥទ្ធិពលអ្វីខ្លះ មកលើសេដ្ឋកិច្ចកម្ពុជា ?

## ៣. គោលបំណង នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះផ្តោតលើគោលបំណង ៣យ៉ាងធំៗ ដូចខាងក្រោម៖

១. សិក្សាពីសារៈសំខាន់នៃគោលនយោបាយសារពើពន្ធមកលើសេដ្ឋកិច្ចកម្ពុជានាពេលកន្លងមកនិង បច្ចុប្បន្ន។
២. សិក្សាពីស្ថានភាពសេដ្ឋកិច្ចកម្ពុជា និងការអនុវត្តគោលនយោបាយសារពើពន្ធនៅប្រទេសកម្ពុជា។

---

*ប្រភព៖ ទីស្តីការគណៈរដ្ឋមន្ត្រី (ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០) សម្រង់ប្រសាសន៍សម្តេចតេជោ ហ៊ុន សែន, ពិធីប្រកាសដាក់ឱ្យដំណើរការជា ផ្លូវការ - កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលជំងឺ កូវីដ ១៩ - [https://pressocm.gov.kh/archives/66496] (អានថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២៣)*

៣. បង្ហាញពីទំនាក់ទំនង និងឥទ្ធិពលនៃការអនុវត្តឧបករណ៍គោលនយោបាយសារពើពន្ធរបស់រាជរដ្ឋាភិបាលកម្ពុជារួមមានចំណាយចរន្តចំណាយមូលធន និងចំណូលសារពើពន្ធព្រមទាំងឥទ្ធិពលនៃអតិផរណាមកលើ កំណើនសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលកន្លងមកនេះ។

## ៤. ទំហំ និងដែនកំណត់ នៃការស្រាវជ្រាវ

ចំពោះវិសាលភាពនៃការស្រាវជ្រាវលើសារណាបញ្ចប់ការសិក្សានេះគឺផ្តោតសំខាន់តែលើលករដែលមានឥទ្ធិពលលើកំណើនសេដ្ឋកិច្ចកម្ពុជាចំនួនតែបួនគឺ ចំណាយចរន្ត ចំណាយមូលធន ចំណូលសារពើពន្ធ និងអតិផរណា ដែលនឹងវិភាគត្រឹមតែទំនាក់ទំនងនិងភាពសំខាន់របស់វានៅក្នុងការកសាងសេដ្ឋកិច្ចជាតិកម្ពុជាតែប៉ុណ្ណោះ។ ចំពោះដែនកំណត់នៃការស្រាវជ្រាវនេះវិញគឺត្រូវបានពិនិត្យមើលទិន្នន័យត្រឹមតែរយៈពេល១៧ឆ្នាំចុងក្រោយដែលផ្តោតសំខាន់លើការប្រែប្រួលនៃផលិតផលក្នុងស្រុកសរុបពិតតែប៉ុណ្ណោះគឺចាប់ពីឆ្នាំ២០០៧-២០២៣។

## ៥. សារៈសំខាន់ នៃការស្រាវជ្រាវ

អត្ថបទស្រាវជ្រាវនេះនឹងផ្តល់ជាប្រយោជន៍ដល់សិស្សនិស្សិតក្នុងការសិក្សាស្វែងយល់បន្ថែម និងកាន់តែស៊ីជម្រៅថែមទៀត នៅក្នុងមុខវិជ្ជាម៉ាក្រូសេដ្ឋកិច្ច ជាពិសេសសិក្សាកាន់តែលម្អិតអំពីគោលនយោបាយ សារពើពន្ធរបស់រាជរដ្ឋាភិបាលកម្ពុជាទាំងផ្នែកទ្រឹស្តី ទាំងផ្នែកអនុវត្ត។ នៅក្នុងការសិក្សាមួយនេះ នឹងមានការ ពន្យល់លម្អិតបន្ថែមអំពីឥទ្ធិពលនៃការចំណាយសាធារណៈរបស់រដ្ឋាភិបាល និងចំណូលសារពើពន្ធមកលើ កំណើនសេដ្ឋកិច្ចកម្ពុជានារយៈកាលជាងមួយទសវត្សចុងក្រោយនេះដោយឈរមើលលើទ្រឹស្តីគោល នយោបាយសារពើពន្ធ រួមទាំងការផ្តល់អនុសាសន៍មួយចំនួនបន្ថែមទៀតដល់រដ្ឋាភិបាលដើម្បីធ្វើឱ្យការដាក់ ចេញនិងការអនុវត្តគោលនយោបាយសារពើពន្ធរួមមានការប្រមូលចំណូល និងចំណាយរដ្ឋាភិបាលឱ្យកាន់តែ មានប្រសិទ្ធភាពក្នុងគោលបំណងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា និងសម្រេចឱ្យបាននូវគោលដៅក្នុងការក្លាយជា ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ បន្ទាប់ពីជួបវិបត្តិសេដ្ឋកិច្ចដោយសារការរីករាលដាល នៃជំងឺកូវីដ១៩។ នឹងសម្របតាមចក្ខុវិស័យនៃ យុទ្ធសាស្ត្របញ្ចកោណ ក្នុងគោលដៅចង់សម្រេចឲ្យប្រទេសកម្ពុជាក្លាយជាប្រទេសដែរមានចំណូលខ្ពស់ត្រឹមឆ្នាំ ២០៥០ ខាងមុខ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

- **ប្រភពទិន្នន័យ**

ឯកសារស្រាវជ្រាវមួយនេះចងក្រងឡើងដោយប្រើទិន្នន័យ កម្រិត២ ឬ (Secondary Data) ដែលត្រូវបានដកស្រង់ចេញពីប្រភពគេហទំព័រផ្លូវការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ ព្រមទាំងឯកសារស្រាវជ្រាវ ផ្សេងៗទៀតដែលចងក្រងដោយសាស្ត្រាចារ្យនានា និងអ្នកសិក្សាជំនាន់មុនផងដែរ។

---

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងរញ្ញវត្ថុ*

*ប្រភព៖ ធនាគារជាតិនៃកម្ពុជា*

*ប្រភព៖ ធនាគារពិភពលោក*

*ប្រភព៖ មូលនិធិរូបិយវត្ថុអន្តរជាតិ*

# ជំពូកទី ១

## រំលឹកទ្រឹស្តី( ទ្រឹស្តីគោលនយោបាយសារពើពន្ធ )

### ១.១.និយមន័យ

#### ១.១.២.គោលនយោបាយសារពើពន្ធ

គោលនយោបាយសារពើពន្ធ គឺជាការប្រើប្រាស់នូវឧបករណ៍ពីរធំៗរួមមានការចំណាយ និងចំណូលសារពើពន្ធដែលមានឥទ្ធិពលមកលើសេដ្ឋកិច្ចជាតិ ដើម្បីជំរុញកំណើននិងរក្សាស្ថេរភាពសេដ្ឋកិច្ចជាតិ កាត់បន្ថយភាពក្រីក្រ ព្រមទាំងអភិវឌ្ឍប្រទេសជាតិឲ្យបានរីកចម្រើន។ តួនាទីនិងគោលបំណងរបស់គោលនយោបាយសារពើពន្ធទទួលបានការចាប់អារម្មណ៍ពីសេដ្ឋវិទូនានា និងរដ្ឋាភិបាលក្នុងអំឡុងពេលជួបវិបត្តិសេដ្ឋកិច្ច ពោលគឺពេលដែររដ្ឋាភិបាលចេញអន្តរាគមន៍ក្នុងសេដ្ឋកិច្ចដើម្បីរក្សាស្ថេរភាពប្រព័ន្ធហិរញ្ញវត្ថុចាប់ផ្តើមកំណើនសេដ្ឋកិច្ចឡើងវិញ ព្រមទាំងស្រាយនូវផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ចសម្រាប់ក្រុមអ្នកងាយរងគ្រោះ។

#### ១.១.៣.លោក (ADAM SMITH & MATHUS)

នៅមុនវិបត្តសេដ្ឋកិច្ច(The Great Economic Depression) ឆ្នាំ ១៩២៩ ការអនុវត្តប្រព័ន្ធសេដ្ឋកិច្ច ទីផ្សារសេរីបានកំហិតតួនាទីរបស់រដ្ឋាភិបាលនៅក្នុងសេដ្ឋកិច្ច។ សេដ្ឋវិទូក្លាស៊ិករួមមានលោកអាដាម ស្មីត, ដេវីដ រីការដូ, ចន ស្ទូត មើល, និងថូម៉ាស់ រ៉ូបឺត ម៉ាលទូស បានបង្កើតទ្រឹស្តីក្លាស៊ីកដែលលើកកម្ពស់ទស្សនទាន សេដ្ឋកិច្ចទីផ្សារសេរី។ តាមទស្សនៈសេដ្ឋកិច្ចទីផ្សារសេរី ទីផ្សារអាចធ្វើស្វ័យកែតម្រូវបានយ៉ាងឆាប់រហ័ស ប្រសិនបើទីផ្សារនោះដំណើរការដោយសេរី និងគ្មានឧបសគ្គ ហើយសេដ្ឋកិច្ចនឹងធ្វើដំណើរការល្អបំផុតប្រសិនបើ តួនាទីរបស់រដ្ឋនៅក្នុងសេដ្ឋកិច្ចត្រូវបានរឹតត្បិត។ ម្យ៉ាងទៀតទ្រឹស្តីក្លាស៊ិកបញ្ជាក់ថាការផ្គត់ផ្គង់ជាអ្នកកំណត់ តម្រូវការនៅក្នុងសេដ្ឋកិច្ច ហើយបម្រែបម្រួលនៃការផ្គត់ផ្គង់នឹងបំពេញដោយបម្រែបម្រួលនៃតម្រូវការ។ ជារួម តាមទ្រឹស្តី ក្លាស៊ីក តួនាទីចម្បងរបស់រដ្ឋគឺធានាដំណើរការដោយសេរីនៃទីផ្សារដោយប្រើប្រាស់, អនុវត្តទ្រឹស្តី លើកកម្ពស់ការផ្គត់ផ្គង់(Supply-Side Theory), និងការធានាតុល្យភាពថវិកា (Budget balance) ដែលក្នុង នោះរួមមានការបង្កើតនិងលើកកម្ពស់ប្រព័ន្ធច្បាប់ការពារយ័ន្តការទីផ្សារ ការប្រកួតប្រជែងដោយសេរីនៅក្នុងសេដ្ឋកិច្ច ព្រមទាំងដោះស្រាយភាពអសកម្មនៅក្នុងទីផ្សារជាដើម។

## ១.២.ឧបករណ៍គោលនយោបាយសារពើពន្ធ

ក្នុងការអនុវត្តគោលនយោបាយសារពើពន្ធ រដ្ឋាភិបាលតែងប្រើប្រាស់នូវឧបករណ៍ពីរធំៗគឺ ចំណូល សារពើពន្ធ និងចំណាយរដ្ឋាភិបាលដើម្បីជំរុញនូវតម្រូវការរួមនៅក្នុងសេដ្ឋកិច្ច កាត់បន្ថយនូវបញ្ហានិកម្មភាព ព្រម ទាំងរក្សាស្ថេរភាពនៃកំណើនសេដ្ឋកិច្ច និងកាត់បន្ថយនូវភាពក្រីក្រជាដើម។ រដ្ឋាភិបាលប្រមូលពន្ធ និងអាករ ផ្សេងៗពីសកម្មភាពសេដ្ឋកិច្ចដែលជាប្រភពចំណូលដ៏សំខាន់សម្រាប់ប្រទេសនីមួយៗ ហើយរដ្ឋាភិបាលបានប្រើ ប្រាស់ចំណូលទាំងអស់នោះជាមូលដ្ឋាននៅក្នុងចំណាយសាធារណៈសម្រាប់ការអភិវឌ្ឍប្រទេស។ នៅក្នុងគោលនយោបាយសារពើពន្ធ ឧបករណ៍សំខាន់ពីរដែលប្រើគឺការចំណាយរបស់រដ្ឋាភិបាល និងការដាក់ពន្ធ ។

១. សកម្មភាពចំណាយរបស់រដ្ឋាភិបាលនឹងរួមបញ្ចូលពីរប្រភេទដូចជា ការចំណាយលើលទ្ធកម្មទំនិញ និងសេវាកម្ម ព្រមទាំងការចំណាយលើការផ្ទេរប្រាក់

- ការចំណាយលើការទិញទំនិញ និងសេវាកម្ម ៖ ពោលគឺរដ្ឋាភិបាលប្រើប្រាស់ថវិកាទិញសព្វាវុធ និងបរិក្ខារ សាងសង់ផ្លូវ ស្ពាន និងការងារហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ព្រមទាំងបើកប្រាក់បៀវត្សរ៍ដល់មន្ត្រីរាជការ ។ ការចំណាយរបស់រដ្ឋាភិបាលលើទំនិញ និងសេវាកម្មកំណត់ទំហំពាក់ព័ន្ធនៃវិស័យសាធារណៈក្នុងផលិតផលក្នុងស្រុកសរុប (GDP) បើធៀបនឹងវិស័យឯកជន។នៅពេលដែលរដ្ឋាភិបាលបង្កើន ឬបន្ថយការចំណាយលើការទិញទំនិញ និងសេវាកម្ម វានឹងប៉ះពាល់ដល់តម្រូវការសរុប។
- ការចំណាយលើការផ្ទេរប្រាក់ ៖ ទាំងនេះគឺជាប្រាក់ឧបត្ថម្ភរបស់រដ្ឋាភិបាលប្រើសម្រាប់អ្នកទទួលផលគោលនយោបាយដូចជាជនក្រីក្រ ឬក្រុមដែលងាយរងគ្រោះផ្សេងទៀតនៅក្នុងសង្គម។ ការចំណាយលើការផ្ទេរប្រាក់មានផលប៉ះពាល់ដោយប្រយោលទៅលើតម្រូវការសរុប តាមរយៈប៉ះពាល់ដល់ប្រាក់ចំណូលផ្ទាល់ខ្លួន និងការប្រើប្រាស់។ ដូច្នោះហើយ នៅពេលដែលរដ្ឋាភិបាលបង្កើនការចំណាយផ្ទេរប្រាកការប្រើប្រាស់ផ្ទាល់ខ្លួននឹងកើនឡើង។

២. ពន្ធមានច្រើនប្រភេទដូចជា ពន្ធលើប្រាក់ចំណូលសាជីវកម្ម ពន្ធលើប្រាក់ចំណូលផ្ទាល់ខ្លួន ពន្ធលើតម្លៃបន្ថែម ពន្ធប្រើប្រាស់ពិសេស ពន្ធអចលនទ្រព្យ... ។ នៅក្នុងសេដ្ឋកិច្ចជាទូទៅពន្ធនឹងមានផលប៉ះ

ពាល់តាមពីរវិធីយ៉ាង។ ទីមួយ ពន្ធកាត់បន្ថយប្រាក់ចំណូលដែលអាចប្រើប្រាស់បានរបស់បុគ្គលម្នាក់ៗ ដោយហេតុនេះនាំឱ្យមានការថយចុះនៃការចំណាយរបស់បុគ្គលលើការប្រើប្រាស់ទំនិញ និងសេវាកម្ម។ នេះបណ្តាលឱ្យតម្រូវការសរុបធ្លាក់ចុះ ហើយ GDP ធ្លាក់ចុះ។ មួយវិញទៀត ពន្ធប៉ះពាល់ដល់តម្លៃទំនិញ និងសេវាកម្ម និងបង្ខូចថ្លៃ នឹងធ្វើឲ្យប៉ះពាល់ដល់អាកប្បកិរិយា និងការលើកទឹកចិត្តរបស់បុគ្គលក្នុងការប្រើប្រាស់ទំនិញ៕

### **១.២.១.ចំណូលថវិការដ្ឋ**

ស្ថានភាពចំណូលថវិការដ្ឋ ក្នុងក្របខណ្ឌនៃគោលដៅខាងលើ រាជរដ្ឋាភិបាលត្រូវបង្កើនចំណូលសរុបថវិការដ្ឋ ឬ ចំណូលសរុបថវិកាជាតិ ឱ្យស្មើនឹង ២៦ ៧៥៩ ៩៩៦ លានរៀល ក្នុងនោះចំណូលចរន្តថ្នាក់ជាតិ ឱ្យស្មើនឹង ១៩ ៥៩៣ ១១១ លានរៀល (ដែលរួមមាន ចំណូលសារពើពន្ធ ១៦ ៨៧៩ ០០០ លាន រៀល និង ចំណូលមិនមែនសារពើពន្ធ ២ ៧១៤ ១១១ លានរៀល)។ ដោយឡែកសម្រាប់ចំណូលមូលធនថវិការដ្ឋ ត្រូវបានគ្រោងចំនួន ៥ ៧៦៦ ៩១៧ លានរៀល, ត្រូវជា ៥,២៥% នៃផសស គឺមានកំណើន ១៥,៩% ធៀបនឹងច្បាប់ឆ្នាំ ២០១៨ ក្នុងនោះចំណូលមូលធនដោយហិរញ្ញប្បទាន ពីក្រៅប្រទេស ស្មើនឹងប្រមាណ ២០% នៃចំណាយថវិការដ្ឋសរុបឆ្នាំ ២០១៩ ប៉ុណ្ណោះ។

## ក្រាហ្វិកទី១៖ គម្រងចំណូលថវិការរដ្ឋ




ចំណូលមូលធន ត្រូវសម្រេចឱ្យបានចំនួន ៥ ៧៦៦ ៩១៧ លានរៀល ក្នុងនោះចំណូលមូលធនក្នុងប្រទេស ១៩៣ ១៤៩ លានរៀល ចំណូលមូលធនក្រៅប្រទេស ៥ ៥៧៣ ៧៦៨ លានរៀល។

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

*ប្រភព៖ ថវិកាសង្ខេបឆ្នាំ២០១៩ ទំព័រទី១១*




## តារាងទី១៖ ចំណូលថវិការឆ្នាំ ២០២១-២០២២

| ចំណូលថវិកា (ឯកតា÷ លានរៀល) | ២០២១ | | ២០២២ | |
|---|---|---|---|---|
| | ច្បាប់ | % ផ.ស.ស. | ច្បាប់ | % ផ.ស.ស. |
| សរុបចំណូលថវិការដ្ឋ ឬ ថវិកាជាតិ | 27,768,742 | 24.10% | 32,676,130 | 26.32% |
| · ថ្នាក់ជាតិ | 26,250,336 | 22.78% | 30,544,366 | 24.60% |
| · ថ្នាក់ក្រោមជាតិ | 1,518,406 | 1.32% | 2,131,764 | 1.72% |
| ១. ចំណូលចរន្តថវិការដ្ឋ | 21,224,389 | 18.42% | 24,289,107 | 19.56% |
| ក. ចំណូលសារពើពន្ធថវិការដ្ឋ | 18,570,323 | 16.12% | 21,811,132 | 17.57% |
| · ថ្នាក់ជាតិ | 17,520,000 | 15.21% | 20,227,005 | 16.29% |
| · ថ្នាក់ក្រោមជាតិ | 1,050,323 | 0.91% | 1,584,127 | 1.28% |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

*ប្រភព៖ ថវិការសង្ខេបឆ្នាំ២០១៩ ទំព័រទី១*

## តារាងទី២៖ ចំណូលថវិការឆ្នាំ ២០២២

| ចំណូលថវិកា (ឯកតា÷ លានរៀល) | ២០២១ | | ២០២២ | |
|---|---|---|---|---|
| | ច្បាប់ | % ផ.ស.ស. | ច្បាប់ | % ផ.ស.ស. |
| ១. ចំណូលមិនមែនសារពើពន្ធថវិការដ្ឋ | 2,654,066 | 2.30% | 2,477,975 | 2.00% |
| · ថ្នាក់ជាតិ | 2,185,983 | 1.90% | 1,930,338 | 1.55% |
| · ថ្នាក់ក្រោមជាតិ | 468,083 | 0.41% | 547,637 | 0.44% |
| ២. ចំណូលមូលធនថវិការដ្ឋ | 6,544,353 | 5.68% | 8,387,023 | 6.75% |
| · ក្នុងប្រទេស | 221,203 | 0.19% | 1,305,259 | 1.05% |
| · ក្រៅប្រទេស | 6,323,150 | 5.49% | 7,081,764 | 5.70% |

---

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

*ប្រភព៖ ថវិការសង្ខេបឆ្នាំ២០១៩ ទំព័រទី១១*

## ក្រាហ្វិក២៖ ចំណូលថវិការឆ្នាំ ២០២២




### ១.២.២.ចំណាយរដ្ឋាភិបាល

ចំណាយរដ្ឋាភិបាលបានបែងចែកជាពីរផ្នែកធំៗគឺ ចំណាយចរន្ត និងចំណាយមូលធន។

១.២.២.១. ចំណាយចរន្ត

ចំណាយចរន្ត ជាចំណាយដែលរដ្ឋាភិបាលត្រូវចំណាយជាប្រចាំសម្រាប់ទ្រទ្រង់កិច្ចប្រតិបត្តិការរដ្ឋបាល ជារៀងរាល់ថ្ងៃដែលរួមមាន ចំណាយបន្ទុកបុគ្គលិក ចំណាយប្រតិបត្តិការ និងចំណាយបន្ទុកហិរញ្ញវត្ថុ ព្រមទាំង ចំណាយផ្សេងៗទៀតជាដើម។ ចំណាយបន្ទុកបុគ្គលិក ជាចំណាយលើប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់ ឧបត្ថម្ភផ្សេងៗ ប្រាក់វិភាជន៍សង្គម វិភាគទានសង្គម និងប្រាក់អត្ថប្រយោជន៍សង្គមផ្សេងៗ។ ចំណែកចំណាយ ប្រតិបត្តិការ ជាចំណាយលើការទិញទំនិញ ការជួសជុលថែទាំ និងការជួលសេវា ដើម្បីទទួលនូវមធ្យោបាយនឹង សេវាផ្សេងៗ បម្រើឱ្យសកម្មភាពរបស់រដ្ឋ។ ចំណាយបន្ទុកហិរញ្ញវត្ថុ ជាចំណាយលើការប្រាក់ និងបន្ទុកពាក់ព័ន្ធ ផ្សេងៗនៃបំណុលសាធារណៈក្នុងប្រទេស និងក្រៅប្រទេស។ ក្រៅពីចំណាយបន្ទុកបុគ្គលិក ចំណាយប្រតិបត្តិការ នឹងចំណាយបន្ទុកហិរញ្ញវត្ថុ រដ្ឋាភិបាលបានចំណាយដើម្បីអន្តរាគមន៍ផ្នែកសង្គម សេដ្ឋកិច្ច វប្បធម៌ ចំណាយលើ ការផ្តល់

អត្ថប្រយោជន៍សង្គម ចំណាយឧបត្ថម្ភធនទៅគ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ ការ ផ្ដល់អំណោយ ចំណាយឧបត្ថម្ភធនផ្សេងៗទៀត ព្រមទាំងចំណាយលើពន្ធនិងអាករដែលបង់ដោយរដ្ឋ និង ចំណាយមិនទាន់បានគ្រោងទុកផ្សេងៗទៀត។"

ចំណាយចរន្ត ជាចំណាយដែលចូលរួមជាមួយប្រតិបត្តិការសេដ្ឋកិច្ចប្រចាំថ្ងៃហើយការប្រែប្រួល ចំណាយចរន្តរបស់រដ្ឋាភិបាលមានភទ្ធិពលដោយផ្ទាល់ជាមួយតម្រូវការគ្រួសារ។ ដោយសារតែតម្រូវការគ្រួសារ ប្រែប្រួលអាស្រ័យទៅនឹងប្រាក់ចំណូលបន្ទាប់ពីបង់ពន្ធ នោះសម្រាប់បុគ្គលិករបស់រដ្ឋាភិបាលទទួលបានប្រាក់ ចំណូលពីរដ្ឋាភិបាល កាលណារដ្ឋាភិបាលតំឡើងប្រាក់បៀវត្សឬមានប្រាក់ឧបត្ថម្ភបន្ថែមផ្សេងៗ នោះចំណូល របស់គ្រួសារកើនឡើង ហើយតម្រូវការរបស់គ្រួសារឬការប្រើប្រាស់កើនឡើង។ ម្យ៉ាងទៀត ចំណាយឧបត្ថម្ភធន ដែលជាចំណាយចរន្តសម្រាប់សហគ្រាសសាធារណៈឬសហគ្រាសឯកជន បានជំរុញនូវសហគ្រាសទាំងនោះ ឱ្យមានប្រតិបត្តិការសេដ្ឋកិច្ច។ កាលណារដ្ឋាភិបាលផ្ដល់ឧបត្ថម្ភធនដល់សហគ្រាសឯកជន នោះមានឥទ្ធិពល ពីរធំៗ (១)សហគ្រាសបង្កើនប្រតិបត្តិការផលិតទំនិញនៅក្នុងសេដ្ឋកិច្ចតាមរយៈការបន្ថែមកម្លាំងពលកម្មដែល កាត់បន្ថយនូវបញ្ញានិកម្មភាពឬរក្សាផលិតកម្មរបស់ខ្លួនឱ្យនៅដដែល ដោយមិនកាត់បន្ថយនូវកម្លាំងពលកម្ម ដែលធ្វើឱ្យមានការកើនឡើងនូវនិកម្មភាពក្នុងសេដ្ឋកិច្ចនោះទេ។ (២)ឧបត្ថម្ភធនសម្រាប់សហគ្រាស អាចធ្វើឱ្យ ថ្លៃដើមសហគ្រាសផ្ទាល់មានការថយចុះ ហើយជាលទ្ធផលទំនិញនិងសេវាកម្មនៅក្នុងទីផ្សារថយចុះ បម្រើ បម្រាស់នៅក្នុងសេដ្ឋកិច្ចកើនឡើង។ តាមភេនស៍ កាលណាធាតុផ្សំរបស់តម្រូវការរួមកើនឡើងរួមមាន ចំណាយរដ្ឋាភិបាល ចំណាយគ្រួសារ នោះសេដ្ឋកិច្ចនឹងកើនឡើង ហើយវិបត្តិនឹងត្រូវបានដោះស្រាយ។ ដូចនេះពេលដែល ចំណាយចរន្តកើនឡើង តម្រូវការរួមនៅក្នុងសេដ្ឋកិច្ចកើនឡើង ធាតុចេញឬផលិតផលក្នុងស្រុកសរុបនៅក្នុង សេដ្ឋកិច្ចនឹងកើនឡើង។

១.២.២.២. ចំណាយមូលធន

ចំណាយមូលធន ជាចំណាយដែលរដ្ឋាភិបាលប្រើប្រាស់សម្រាប់ការវិនិយោគ និងការទូទាត់បំណុល។ ចំណាយវិនិយោគជាចំណាយលើការទទួលបាននូវទ្រព្យសកម្មរយៈពេលវែងទាំងរូបី និង អរូបី ព្រមទាំងទ្រព្យ សកម្មហិរញ្ញវត្ថុរយៈពេលវែងដែលជាចំណាយដើម្បីបង្កើនចំណូលសម្រាប់រដ្ឋនា

ពេលអនាគត។ ជាទូទៅ ចំណាយវិនិយោគរបស់រដ្ឋាភិបាលរួមមាន ការសាងសង់ស្ពាន ការសាងសង់សាលារៀន មន្ទីរពេទ្យ វិនិយោគលើ វិស័យអប់រំ វិស័យសុខាភិបាល ព្រមទាំងការវិនិយោគលើទ្រព្យអរូបីដូចជាដីធ្លី និងទ្រព្យសកម្មហិរញ្ញវត្ថុរួមមាន មូលបត្រកម្មសិទ្ធិជាដើម។

ចំណាយមូលធន ជាឧបករណ៍សារពើពន្ធដែលមានឥទ្ធិពលដល់សេដ្ឋកិច្ចជាតិទាំងក្នុងរយៈពេលខ្លី និងរយៈពេលវែង។ នៅក្នុងរយៈពេលខ្លី រដ្ឋាភិបាលចំណាយទៅលើការវិនិយោគ រួមមានសាងសង់ស្ពាន សាង សង់សាលារៀន មន្ទីរពេទ្យ វិនិយោគលើវិស័យអប់រំ សុខាភិបាល ចំណាយនោះនឹងក្លាយទៅជាចំណូលសម្រាប់ អ្នកធ្វើការនៅក្នុងវិស័យទាំងនោះ រួមមានបុគ្គលិកបម្រើការងារក្នុងវិស័យសាងសង់ បុគ្គលិកក្នុងវិស័យសុខា ភិបាល ក៏ដូចជាអ្នកលក់ទំនិញពាក់ព័ន្ធនានាជាដើម។ នៅពេលចំណូលកើនឡើង នោះតម្រូវការទំនិញនិងសេវា កម្មនៅក្នុងសេដ្ឋកិច្ចកើនឡើង ហើយផាតុចេញឬផលិតផលសរុបនៅក្នុងសេដ្ឋកិច្ចកើនឡើង។ ម្យ៉ាងវិញទៀត នៅក្នុងរយៈពេលវែង ការវិនិយោគលើវិស័យអប់រំបានជំរុញនូវការអភិវឌ្ឍធនធានមនុស្សក្នុងសង្គម ផលិតភាពរួម របស់កម្លាំងពលកម្មក្នុងទីផ្សារពលកម្មកើនឡើង ជំរុញកំណើនសេដ្ឋកិច្ច។ ចំពោះការវិនិយោគលើវិស័យហេដ្ឋា រចនាសម្ព័ន្ធ វិស័យសុខាភិបាល បានសម្រួលដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន និងប្រតិបត្តិការសេដ្ឋកិច្ច ប្រចាំថ្ងៃ។ កាលណាហេដ្ឋារចនាសម្ព័ន្ធសាធារណៈរួមមានស្ពាន ថ្នល់កើនឡើង មានការអភិវឌ្ឍនិងគុណភាព នោះដំណើរការសេដ្ឋកិច្ចការដឹកជញ្ជូនមានភាពឆាប់រហ័ស សកម្មភាពសេដ្ឋកិច្ចមមាញឹក ចំណាយផលិតកម្ម និងចំណាយនៅក្នុងការដឹកជញ្ជូនថយចុះ។ កាលណា វិស័យសុខាភិបាលរឹងមាំ ប្រជាជនក្នុងស្រុកមានជំនឿ ចិត្ត អត្រាអាយុសង្ឃឹមរស់កើនឡើង ប្រជាជនមិនចំណាយទៅលើវិស័យសុខាភិបាលក្រៅប្រទេស។ ដូចនេះកាលណាចំណាយមូលធនឬចំណាយវិនិយោគរបស់រដ្ឋាភិបាលកើនឡើង សេដ្ឋកិច្ចនឹងកើនឡើងទាំងក្នុងរយៈពេលខ្លីនិងក្នុងរយៈពេលវែង។

**១.២.៣.បំណុលសាធារណៈ**

បំណុលសាធារណៈ គឺជាបំណុលរបស់រដ្ឋាភិបាលដែលខ្ចីពីបណ្តាដៃគូអភិវឌ្ឍន៍នានាតាមរយៈកិច្ចព្រម ព្រៀងនានា និងកម្ចីក្នុងស្រុកតាមរយៈការបោះផ្សាយនូវបណ្ណបំណុលរបស់រដ្ឋ។ ជាទូទៅ បំណុលសាធារណៈ របស់រដ្ឋកើតមានឡើងនៅពេលដែលរដ្ឋមានឱនភាពថវិកា ឬពេលដែលរដ្ឋាភិបា

លចង់អនុវត្តនូវគម្រោងណា មួយដែលទាមទារថវិកាខ្ពស់។ ឱនភាពថវិកា ការរៀបចំផែនការហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាលនីមួយៗតែងតែជួបនូវ ហើយរដ្ឋាភិបាលត្រូវការកម្ចីពីបណ្តាដៃគូអភិវឌ្ឍន៍នានា និងកម្ចីក្នុងស្រុកដើម្បីបង្គ្រប់នូវចំណាយ របស់ខ្លួន។ 15 ដើម្បីអនុវត្តគោលនយោបាយសារពើពន្ធបាន រដ្ឋអាចប្រើប្រាស់នូវកម្ចីជាឧបករណ៍មួយបន្ថែម ទៀត។ កាលណារដ្ឋាភិបាលចង់បង្កើនការចំណាយរបស់ខ្លួនដើម្បីជំរុញសេដ្ឋកិច្ចជាតិ ក៏ដូចជាដោះស្រាយវិបត្តិ សេដ្ឋកិច្ចបណ្តាលមកពីការថយចុះនូវតម្រូវការរួម ហើយការប្រមូលចំណូលរបស់រដ្ឋមានកម្រិត នោះរដ្ឋាភិបាល អាចខ្ចីពីដៃគូកម្ចីនានា ឬកម្ចីក្នុងស្រុក។ កាលណារដ្ឋាភិបាលចង់កាត់បន្ថយតម្រូវការរួមក្នុងសេដ្ឋកិច្ចដើម្បីកាត់ បន្ថយនូវអតិផរណា រដ្ឋាភិបាលអាចកាត់បន្ថយចំណាយសាធារណៈ តាមរយៈការកាត់បន្ថយនូវកម្ចីមួយចំនួន និងអាចបោះផ្សាយនូវបណ្ណបំណុលរដ្ឋដើម្បីប្រមូលចំណូលពីគ្រួសារ និងសហគ្រាស។

១.២.៣.១. បំណុលខាងក្រៅ

បំណុលខាងក្រៅ គឺជាបំណុលសាធារណៈដែលរដ្ឋាភិបាលខ្ចីពីបណ្តាប្រទេសជាដៃគូ និងស្ថាប័នអន្តរ ជាតិនានាដែលជាដៃគូអភិវឌ្ឍន៍។ កម្ចីពីបណ្តាប្រទេសជាដៃគូ គឺជាកម្ចីពីបណ្តាប្រទេសធំៗរួមមានប្រទេសចិន សហរដ្ឋអាមេរិក ក្នុងគោលបំណងដើម្បីបង្គ្រប់នូវចំណាយវិនិយោគគម្រោងមួយចំនួន។ ចំណែកកម្ចីពីស្ថាប័ន អន្តរជាតិនានា រួមមានធនាគារពិភពលោក មូលនិធិហិរញ្ញវត្ថុអន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ីជាដើម គឺជាកម្ចី ដែលស្ថាប័នទាំងនោះអនុញ្ញាតិ និងផ្តល់ឱ្យ ដើម្បីជួយជំរុញនូវការអភិវឌ្ឍសេដ្ឋកិច្ចរបស់បណ្តាប្រទេសនានា លើពិភពលោក។

១.២.៣.២. បំណុលក្នុងស្រុក

បំណុលក្នុងស្រុក គឺជាបំណុលសាធារណៈដែលរដ្ឋាភិបាលខ្ចីពីស្ថាប័នឯកជនក្នុងស្រុករួមមាន ធនាគារឯកជន និងប្រជាពលរដ្ឋជាដើម។ រដ្ឋាភិបាលអាចខ្ចីកម្ចីក្នុងស្រុកតាមរយៈការបោះផ្សាយនូវសញ្ញាបណ្ណរយៈពេលខ្លី និងសញ្ញាបណ្ណរយៈពេលវែងដើម្បីប្រមូលនូវចំណូលសម្រាប់ការអភិវឌ្ឍ និងអនុវត្តនូវនយោបាយសារពើពន្ធយ៉ាងមានប្រសិទ្ធភាព។ នៅពេលរដ្ឋបោះផ្សាយសញ្ញាបណ្ណសាធារណៈជនអាចទិញនូវបំណុលរដ្ឋជាមួយនឹងការទូទាត់សងពីរដ្ឋវិញនៅក្នុងរយៈពេលកំណត់ណាមួយ។ នៅពេលរដ្ឋបោះផ្សាយសញ្ញាបណ្ណនោះរដ្ឋបានប្រមូលចំណូលពីគ្រួសារ ដែលកាត់បន្ថយតម្រូវការគ្រួសារក្នុងសេដ្ឋកិច្ចដើម្បីកាត់បន្ថយតម្រូវការសរុបក្នុងគោលបំណងកាត់បន្ថយនូវអតិផរណាក្នុងសេដ្ឋ

កិច្ច។ នៅពេលរដ្ឋចង់បង្កើនតម្រូវការរួមនៅក្នុងសេដ្ឋកិច្ចរដ្ឋអាចប្រកាសប្រមូលទិញមកវិញនូវបណ្ណ បំណុលមុនកាលកំណត់ដែលពេលនោះចំណូលរបស់គ្រួសារនឹងកើនឡើងព្រោះគេនឹងលក់នូវសញ្ញាបណ្ណឱ្យរដ្ឋាភិបាលវិញ។ កាលណាចំណូលរបស់គ្រួសារកើនឡើងតម្រូវការគ្រួសារកើនឡើងជាលទ្ធផលសេដ្ឋកិច្ចនឹងកើនឡើង។

## ១.៣.ការអនុវត្តគោលនយោបាយសារពើពន្ធ (ឧត្តមមានុវត្តន៍អន្តរជាតិ)

មានករណីសិក្សាស្រាវជ្រាវជាច្រើនទៅលើឥទ្ធិពលនៃការដាក់ចេញ និងការអនុវត្តនូវគោលនយោបាយសារពើពន្ធមកលើកំណើនសេដ្ឋកិច្ចក្នុងបណ្ដាប្រទេសជាច្រើនដោយអ្នកសិក្សាជាច្រើន និងប្រើប្រាស់គំរូផ្សេងៗនៅក្នុងការសិក្សាវិភាគបន្ថែមពីលើការសិក្សាទ្រឹស្ដី។

ប្រអប់ទី១៖ ករណីសិក្សាពីឥទ្ធិពលនៃចំណាយសាធារណៈលើកំណើនសេដ្ឋកិច្ចសម្រាប់ប្រទេស ចំនួន១៨ ក្នុង Organization for Economic Co-operation and Development (OECD) (F. Ozlem Alper 25 Mehmet Demiral, 2016) ករណីសិក្សាមួយនេះផ្ដោតតែឥទ្ធិពលនៃចំណាយសាធារណៈ មកលើកំណើនសេដ្ឋកិច្ចនៃប្រទេសចំនួន១៨ ក្នុង Organization for Economic Co-operation and Development ( OECD)។ ចំណាយសាធារណៈដែលប្រើប្រាស់នៅក្នុងការសិក្សាមួយនេះ ផ្ដោតតែទៅលើចំណាយសម្រាប់វិស័យចំនួនបីធំៗគឺ ចំណាយទៅលើវិស័យអប់រំចំណាយទៅលើវិស័យសុ ខាភិបាល និងចំណាយទៅលើវិស័យសង្គមកិច្ច ជាអថេរឯករាជ្យ។ អថេរមិនឯករាជ្យ គឺផលិតផលក្នុងស្រុក សរុបសម្រាប់មនុស្សម្នាក់ៗ សម្រាប់វាស់វែងពីកំណើនសេដ្ឋកិច្ច។ វិធីសាស្ត្រប្រើប្រាស់ទៅក្នុងការសិក្សាមួយ នេះគឺ Feasible Generalized Least Square (FGLS) ដែលប្រើប្រាស់ទិន្នន័យចាប់ពីឆ្នាំ២០០២ ដល់ឆ្នាំ ២០១៣ សម្រាប់ប្រទេសចំនួន១៨ ក្នុង ០៩៨០។ ជាលទ្ធផលនៃការសិក្សាបានបង្ហាញថា អថេរទាំងបី រួម មានចំណាយទៅលើវិស័យអប់រំ ចំណាយទៅលើវិស័យសុខាភិបាល និងចំណាយទៅលើវិស័យសង្គមកិច្ច បានចូលរួមនៅក្នុងការកសាងកំណើនសេដ្ឋកិច្ចសម្រាប់ប្រទេសទាំង១៨ ក្នុង CECD ដែលបានលើកយកមកសិក្សា។

ប្រអប់ទី២៖ ករណីសិក្សាពីឥទ្ធិពលនៃគោលនយោបាយសារពើពន្ធលើកំណើនសេដ្ឋកិច្ចឥណ្ឌូនេស៊ី(Fanny Oktiva Denovis, 2014) មានការសិក្សាមួយផងដែរពីឥទ្ធិពលនៃគោលនយោបាយសារពើពន្ធលើកំណើនសេដ្ឋកិច្ចឥណ្ឌូនេស៊ី ដោយប្រើប្រាស់ទិន្នន័យសិក្សាចាប់ពីឆ្នាំ

២០០២ ដល់ឆ្នាំ ២០១២ សរុបចំនួន១០ឆ្នាំ។ ការសិក្សាមួយនេះប្រើប្រាស់វិធីសាស្ត្រគំរូ Ordinary Least Square (OLS) ដែលអថេរឯករាជ្យនៅក្នុងការសិក្សាមួយានេះរួមមានចំណាយចរន្តចំណាយអភិវឌ្ឍន៍ និងពន្ធលើប្រាក់ ចំណូល។ ជាលទ្ធផលនៃការសិក្សា មេគុណតម្រែតម្រង់ IR (Coefficient of Determination) នៃទំនាក់ទំនងរវាងអថេរឯករាជ្យ និងអថេរមិនឯករាជ្យស្មើនឹង ៩៩២ ភាគរយ ដែលបង្ហាញថាគោលនយោបាយសារពើពន្ធមានឥទ្ធិពលខ្លាំងមកលើកំណើនសេដ្ឋកិច្ចប្រទេសឥណ្ឌូនេស៊ី។ ជាសន្និដ្ឋានចំណាយរដ្ឋាភិបាលរួមមានចំណាយចរន្តចំណាយអភិវឌ្ឍន៍ និងពន្ធលើប្រាក់ចំណូលមានឥទ្ធិពលវិជ្ជមានមកលើកំណើនសេដ្ឋកិច្ចឥណ្ឌូនេស៊ីដែលមានន័យថាកាលណាចំណាយចរន្តចំណាយអភិវឌ្ឍន៍ និងពន្ធលើប្រាក់ចំណូលកើនឡើងនោះកំណើនសេដ្ឋកិច្ចឥណ្ឌូនេស៊ីនឹងកើនឡើងខ្ពស់។

ប្រអប់ទី៣៖ ករណីសិក្សាពីឥទ្ធិពលនៃគោលនយោបាយសារពើពន្ធលើកំណើនសេដ្ឋកិច្ចកម្ពុជា (SEAN Monorith, YIM Chanmary, ២០២០) ការសិក្សាមួយនេះផ្តោតលើឥទ្ធិពលនៃគោលនយោបាយសារពើពន្ធលើកំណើនសេដ្ឋកិច្ចកម្ពុជាចាប់ពីឆ្នាំ១៩៩៤ ដល់ឆ្នាំ២០១៩ សរុបចំនួន២៦ ឆ្នាំ។ ការសិក្សានេះក៏ផ្តោតផងដែរទៅលើប្រភេទគោលនយោបាយសារពើពន្ធដែលរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញជាគោលនយោបាយសារពើពន្ធពង្រីកឬគោលនយោបាយសារពើពន្ធបង្រួម។ អ្នកស្រាវជ្រាវផ្តោតលើ វិធីសាស្ត្រ ការសន្និដ្ឋាន Bayesian ដែលផ្អែកលើ Bayesian Model Averaging (BMA) និង Markov Chain Monte Carlo (MCMC) ដែលមានអថេរចូលរួមនៅក្នុងការសិក្សាដូចជាផលិតផលក្នុងស្រុកសរុបពិតឱនភាពថវិកាជាតិបំណុលសាធារណៈហិរញ្ញប្បទានក្រៅប្រទេសអត្រាប្តូរប្រាក់មានតែនាម និងការនាំចេញ។ ជាលទ្ធផលអថេរទាំងអស់នេះមានឥទ្ធិពល និងទំនាក់ទំនងវិជ្ជមានមកលើកំណើនសេដ្ឋកិច្ចនៃកម្ពុជា និងអាចសន្និដ្ឋានបានថាគោលនយោបាយសារពើពន្ធនៅកម្ពុជាអនុវត្តបែបជាគោលនយោបាយរួមនិងស្ថិរភាព។ នៅពេលដែលឱនភាពថវិកាជាតិបំណុលសាធារណៈហិរញ្ញប្បទានក្រៅប្រទេសអត្រាប្តូរប្រាក់មានតែនាម និងការនាំចេញកើនឡើងដើម្បីជម្រុញសេដ្ឋកិច្ចក្នុងពេលជួបវិបត្តិពេលនោះគោលនយោបាយសារពើពន្ធជាគោលនយោបាយពង្រីក។ បន្ទាប់ពីវិបត្តិនោះទៅរាជរដ្ឋាភិបាលកម្ពុជាដាក់ចេញនូវ គោលនយោបាយសារពើពន្ធបង្រួមដើម្បីកាត់បន្ថយនូវសកម្មភាពសេដ្ឋកិច្ចក្នុងពេលដែលសកម្មភាពសេដ្ឋកិច្ចកំពុងតែមានសន្ទុះកើនឡើងខ្លាំងពេក។

# ជំពូកទី ២

## ស្ថានភាពសេដ្ឋកិច្ច និងគោលនយោបាយសារពើពន្ធនៅកម្ពុជា

### ២.១.ការវិវត្តថ្មីៗ នៃសេដ្ឋកិច្ចកម្ពុជា

ក្រោយពីធ្លាក់ចុះកំណើនដោយសារជំងឺកូវីដ-១៩ សេដ្ឋកិច្ចរបស់កម្ពុជាកំពុងងើបឡើងវិញ ដោយមានការទ្រទ្រង់ពីវិស័យនាំចេញដែលនៅមានភាពរឹងមាំ។ ប៉ុន្តែ កម្ពុជានៅតែប្រឈមមុខនឹងឧបសគ្គច្រើនទៀតនៅក្នុងសេដ្ឋកិច្ចសកលលោក ខណៈដែលសកម្មភាពពាណិជ្ជកម្មពិភពលោកមានកំណើនយឺត។

ធនាគារពិភពលោកបានកែសម្រួលឡើងវិញនូវការព្យាករអំពីកំណើនផ.ស.សពិតរបស់កម្ពុជា នឹងមាន ៤,៨ភាគរយ ក្នុងឆ្នាំ២០២២ ដោយឃើញថា សេដ្ឋកិច្ចកំពុងមានសកម្មភាពងើបឡើងវិញជាទូទៅ។ ការនាំចេញទំនិញសម្លៀកបំពាក់, ទំនិញធ្វើដំណើរ និងទំនិញស្បែកជើង នៅមានសកម្មភាពរស់រវើកគួរឱ្យកត់សម្គាល់ដដែល។ ការរកចំណូលពីវិស័យសេវាកម្ម ពិសេសពីផ្នែកធ្វើដំណើរនិងទេសចរណ៍ ក៏មានភាពប្រសើរឡើងដែរ ក្រោយពីរាជរដ្ឋាភិបាលបានដាក់ចេញយុទ្ធសាស្ត្រ "រស់នៅជាមួយកូវីដ-១៩" នាចុងឆ្នាំកន្លងទៅ។

ក្រាហ្វិកទី៣៖ សូចនាករម៉ាក្រូសេដ្ឋកិច្ច




ការវាយតម្លៃសេដ្ឋកិច្ចកម្ពុជាចុងឆ្នាំ២០២២

*ប្រភព៖ បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជាឆ្នាំ ២០២២ (The World Bank) **សូចនាការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

**២.១.១.ផលិតផលក្នុងស្រុកសរុប** (GDP)

ផលិតផលក្នុងស្រុកសរុបពិតមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដែលបង្ហាញពីភាព រីកចម្រើន និងរឹងមាំនៃការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។ ចាប់តាំងពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៩ ផលិតផលក្នុងស្រុក សរុបពិតបានកើនឡើងពី ១៤,៦៧០.៣៤ លានដុល្លារ ដល់ ២៣.៧៦០.០៦ លានដុល្លារ។ នៅក្នុងឆ្នាំ២០២០ ផលិតផលក្នុងស្រុកសរុបពិតថយចុះ ៣.១% មកត្រឹម ២៣,០២ ពាន់លានដុល្លារ ដែលបណ្តាលមកពីការបិទ ខ្ទប់សកម្មភាពសេដ្ឋកិច្ចព្រោះតែជំងឺកូវី១៩។ ការថយចុះនៃផលិតផលក្នុងស្រុកសរុបពិតនេះ បណ្តាលមកពីការ ថយចុះនៃវិស័យទេសចរណ៍ ដោយកម្ពុជាពឹងផ្អែកយ៉ាងខ្លាំងលើភ្ញៀវទេសចរអន្តរជាតិ ហើយជាមួយនឹងការរឹត បន្តឹងការធ្វើដំណើរ និងការបិទព្រំដែន ចំនួនភ្ញៀវទេសចរបានធ្លាក់ចុះយ៉ាងខ្លាំង។ បន្ថែមទៀត ការធ្លាក់ចុះយ៉ាង ខ្លាំងនៃការបញ្ជាទិញពីអឺរ៉ុប និងអាមេរិកខាងជើង បានធ្វើឱ្យរោងចក្រសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និង ស្បែកជើង (GTF) ប្រហែល ១ ភាគ៣ បានបិទទ្វារ ចំណែកកំណើននៃការផលិតកង់ និងគ្រឿងអេឡិចត្រូនិកបាន ជំរុញឱ្យការនាំចេញផលិតផលក្រៅពីទំនិញកាត់ដេររបស់កម្ពុជាកើនឡើង ៣០,៣ភាគរយ ឆ្នាំលើឆ្នាំ ក្នុងឆមាស ទីមួយនៃឆ្នាំ២០២០″។ ផលិតផលក្នុងស្រុកសរុបបានកើនឡើងមកវិញ ៣.០% នៅឆ្នាំ២០២១ ដែលមានចំនួន ២៣.៧២១.២៦ ពាន់លានដុល្លារ តែចំនួននេះនៅតែមានទំហំតូចជាង ឆ្នាំ២០១៩។ ការងើបឡើងមកវិញនៃ ផលិតផលក្នុងស្រុកក្នុងឆ្នាំ២០២១ បណ្តាលមកពីកម្លាំងជំរុញនៃគោលនយោបាយគាំទ្ររបស់រាជរដ្ឋាភិបាល ការកើនឡើងនៃតម្រូវការក្រៅស្រុកដែលធ្វើឲ្យផលិតកម្មទំនិញឧស្សាហកម្ម និងកសិកម្មកើនឡើង លើកលែងតែវិស័យសេវាកម្មនៅតែបន្តថយចុះ។

GDP Per Capita គឺសំដៅដល់ផលិតផលក្នុងស្រុកសរុបរបស់ មនុស្សម្នាក់ៗដែលអាចផលិតបាន ឬរកបានក្នុង១ ឆ្នាំ។ ជាទូទៅ ដើម្បីអាចរកផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់ៗនៅ ក្នុងប្រទេសមួយបាន គេត្រូវយកផលិតផលក្នុងស្រុកសរុប (Real GDP) នៃប្រទេសនោះ ចែកនឹងចំនួនប្រជាជនសរុប ដែលមាននៅក្នុងប្រទេសនោះ។

ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗនេះ ត្រូវបានគេ ប្រើដើម្បីពិនិត្យមើលពីកម្រិតជីវភាពនការរស់នៅរបស់បូរ ជាជននៅក្នុងប្រទេសនោះ។ វាក៏បានបង្ហាញផងដែរថា តើ ប្រជាជននៅក្នុងប្រទេសនោះ ទទួលបានផ្លែផ្កាប៉ុណ្ណាពីកំណើនសេដ្ឋកិច្ច? ម៉្យាង វាក៏ត្រូវបានប្រសើដើម្បីពិនិ

ត្យមមើលពី អំណាចទិញ និងប្រៀបធៀបពីផលសេដ្ឋកិច្ចពីប្រទេសមួយទៅ ប្រទេសមក្អួយដែលទទួលបានផងដែរ។

ឧទាហរណ៍៖ ក្នុងគ្រួសារមួយសមាជិក៥នាក់។ សមាជិកទី១រក់បាន ១០០០$ ក្នុងមួយឆ្នាំ។ សមាជិកទី២ និងទី៣ រកបាន ១៥០០$ ក្នុងមួយឆ្នាំ ហើយសមាជិកទី៤ រកបាន ៥០០$ក្នុងមួយឆ្ន ចាំចំណែកសមាជិកទី៥ គឺគ្មានចំណូលទេ។ ដូច្នេះយើងអាចរកចំណូលជាមធ្យមដែលមនុស្សម្នាក់ៗនៅក្នុង គ្រួសារនេះទទួលបាន គឺ ៣០០០$/៥ = ៦០០$ ក្នុងសមាជិក ម្នាក់ៗក្នុងមួយឆ្នាំ គិតទាំងអ្នកអត់ចចំណូលផងដែរ។

ក្រាហ្វិកទី៤៖ (GDP Per Capita)




ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗ (GDP Per Capita) កម្ពុជា(គិតតាមដុល្លារអាមេរិក)

*ប្រភព៖ ADB (2022) ទស្សនៈវិស័យអភិវឌ្ឍអាស៊ី - ប្រទេសកម្ពុជា Pps//www.adb.org/sites/default/Nes related AD02022-Cambodia-Chapter-Khmer 5,po(អានថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣*

**២.១.២.ការវិនិយោគ** (Investment)

ក្នុងឆ្នាំ ២០២៣ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានអនុម័តគម្រោងថ្មីចំនួន ២៤៧ និងគម្រោងពង្រីកផលិតកម្មចំនួន ២១ ហើយក្នុងនោះគម្រោងវិនិយោគចំនួន ៧១ ត្រូវបានបណ្តាក់ទុនវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។ គម្រោងទាំងនេះមានទុនវិនិយោគសរុបប្រមាណជិត ៤.៩ ពាន់លានដុល្លារអាមេរិក និងអាចបង្កើតកាងារបានប្រមាណ ៣០៧០០០ កន្លែង។ ចំនួនគម្រោងវិនិយោគក្នុងវិស័យឧស្សាហកម្មបានចូលរួមចំណែកដល់ទៅប្រមាណ ៩២% នៃចំនួនវិនិយោគសរុប ខណៈទុនវិនិយោគប្រមាណ ៤៦% បានមកពីវិស័យនេះ។ ដោយឡែកវិស័យហេដ្ឋារចនាសម្ព័ន្ធ និងផ្សេងៗដែលមានតែប្រមាណ ២.៦% នៃចំនួនគម្រោងវិនិយោគសរុប បានចូលរួមចំណែកដល់ទៅប្រមាណ ៤៤% នៃទុនវិនិយោគសរុប ដោយសារចរិតនៃការវិនិយោគក្នុងវិស័យនេះត្រូវការទុនវិនិយោគច្រើន។ ជារួម រំហូរទុនវិនិយោគឯកជននៅឆ្នាំ ២០២៣ មានការកើនឡើងគួរឲ្យកត់សម្គាល់ ក្នុងរង្វង់ប្រមាណ ២២% ធៀបនឹងឆ្នាំ ២០២២។

❖ ជាការកត់សម្គាល់ គម្រោងវិនិយោគលេចធ្លោប្រចាំឆ្នាំ ២០២៣ រួមមាន៖

- វិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម
- វិស័យឧស្សាហកម្ម
- វិស័យទេសចរណ៍
- វិស័យហេដ្ឋារចនាសម្ព័ន្ធ និងផ្សេងៗ៕

## ក្រាហ្វិកទី៥៖ ប្រភពទុនវិនិយោគ




## ក្រាហ្វិកទី៦៖ គម្រោងវិនិយោគតាមវិស័យ




---

*ប្រភព៖ សេចក្តីប្រកាសព័ត៌មាន (ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា) COUNCIL FOR THE DEVELOPMENT OF CAMBODIA*
*ថ្ងៃពុធ ៧រោច ខែមិគសិរ ឆ្នាំថោះបញ្ចស័ក ព.ស ២៥៦៧*
*រាជធានីភ្នំពេញ ថ្ងៃទី៣ ខែមករា ឆ្នាំ២០២៤*

### ២.១.៣.ពាណិជ្ជកម្មអន្តរជាតិ ( International Trade )

ខាងក្រោមនេះ ជាទិន្នន័យពាណិជ្ជកម្ម នាំចេញរបស់កម្ពុជា ជាមួយដៃគូសំខាន់ៗ គិតត្រឹត ១០ខែ ដើមឆ្នាំ២០២០-២០២១។

**តារាងទី៣៖ ឯកតា គិតជាដុល្លារ (លានដុល្លារសហរដ្ឋអាមេរិក)**

| លរ. | ទិសដៅនាំចេញ | រយៈពេល១០ខែដើម ឆ្នាំ២០២០ | | | រយៈពេល១០ខែដើម ឆ្នាំ២០២១ | | | បម្រែបម្រួល (%) | | |
|---|---|---|---|---|---|---|---|---|---|---|
| | | នាំចេញ | នាំចូល | ទំហំពាណិជ្ជកម្ម | នាំចេញ | នាំចូល | ទំហំពាណិជ្ជកម្ម | នាំចេញ | នាំចូល | ទំហំពាណិជ្ជកម្ម |
| **១** | **ពិភពលោក** | **១៤ ៥៥០** | **១៤ ៦២៤** | **២៩ ១៧៤** | **១៤ ២៨៦** | **២៣ ០៦០** | **៣៧ ៣៤៦** | ▼ **២%** | ▲ **៥៨%** | ▲ **២៨%** |
| ២ | អាម៉េរិក | ៤ ៣២៨ | ១៩៦ | ៤ ៥២៣ | ៦ ០៧៥ | ២៧៨ | ៦ ៣៥៣ | ▲ ៤០% | ▲ ៤២% | ▲ ៤០% |
| ៣ | ជប៉ុន | ៨៧៤ | ៥២៤ | ១ ៣៩៨ | ៩២០ | ៥២៩ | ១ ៤៤៩ | ▲ ៥% | ▲ ១% | ▲ ៤% |
| ៤ | ចិន | ៨២០ | ៥ ៦២៦ | ៦ ៤៤៦ | ១ ២២២ | ៧ ៧៦០ | ៨ ៩៨២ | ▲ ៤៩% | ▲ ៣៨% | ▲ ៣៩% |
| **៥** | **ចក្រភពអង់គ្លេស** | **៧០០** | **៤២** | **៧៤២** | **៥៩៩** | **៤៧** | **៦៤៥** | ▼ **១៥%** | ▲ **១១%** | ▼ **១៣%** |
| ៦ | កាណាដា | ៦០៤ | ៤៨ | ៦៥២ | ៧៩០ | ៣២ | ៨២២ | ▲ ៣១% | ▼ ៣៣% | ▲ ២៦% |
| ៧ | កូរ៉េ | ១៥២ | ៤២៦ | ៥៧៨ | ១៥៧ | ៤៨១ | ៦៣៨ | ▲ ៣% | ▲ ១៣% | ▲ ១០% |
| ៨ | អូស្ត្រាលី | ១១៣ | ៦៣ | ១៧៦ | ១៥១ | ៨៩ | ២៣៩ | ▲ ៣៤% | ▲ ៤០% | ▲ ៣៦% |
| ៩ | ឥណ្ឌា | ៥២ | ១០៦ | ១៥៧ | ១០០ | ១៤៤ | ២៤៤ | ▲ ៩៣% | ▲ ៣៧% | ▲ ៥៥% |
| ១០ | នូវែលសេឡង់ | ១១ | ១២ | ២៣ | ១៣ | ១២ | ២៥ | ▲ ២០% | ▲ ១% | ▲ ១០% |
| **១១** | **អាស៊ាន** | **៣ ៤៩៦** | **៥ ៨០៨** | **៩ ៣០៤** | **៩៦០** | **១០ ៣៨៩** | **១១ ៣៤៩** | ▼ **៧៣%** | ▲ **៧៩%** | ▲ **២២%** |
| | ថៃ | ៥៩១ | ២ ៣២០ | ២ ៩១១ | ២៨៩ | ២ ៧៤២ | ៣ ០៣១ | ▼ ៥១% | ▲ ១៨% | ▲ ៤% |
| | វៀតណាម | ២៨០ | ២ ១៣០ | ២ ៤១១ | ៤០៩ | ២ ៥៣០ | ២ ៩៣៩ | ▲ ៤៦% | ▲ ១៩% | ▲ ២២% |
| **១២** | **សហភាពអឺរ៉ុប (EU)** | **២ ៥៨៥** | **៥៦២** | **៣ ១៤៨** | **២ ៦១៩** | **៨៦៤** | **៣ ៤៨២** | ▲ **១%** | ▲ **៥៤%** | ▲ **១១%** |
| **១៣** | **សហភាពសេដ្ឋកិច្ច អឺរ៉ុបអាស៊ី- (EAEU)** | **៤៣** | **១១** | **៥៤** | **៤៦** | **៣៩** | **៨៤** | ▲ **៦%** | ▲ **២៤៦%** | ▲ **៥៦%** |
| **១៤** | **ប្រទេសផ្សេងៗ** | **៧៧២** | **១ ១៩៩** | **១ ៩៧១** | **៦៣៥** | **២ ៣៩៥** | **៣ ០៣១** | ▼ **១៨%** | ▲ **១០០%** | ▲ **៥៤%** |

**តារាងទី៤៖ ស្ថិតិនាំចេញទំនិញសំខាន់ៗ (ឯកតា៖ លានដុល្លារអាមេរិក)**

| លរ. | មុខទំនិញផ្សេងទៀត | រយៈពេល១០ខែដើម ឆ្នាំ២០២០ | រយៈពេល១០ខែដើម ឆ្នាំ២០២១ | បម្រែបម្រួល | |
|---|---|---|---|---|---|
| | | | | ទឹកប្រាក់ | (%) |
| ១ | សម្លៀកបំពាក់ | ៦ ០៩៩ | ៦ ៥៣៨ | ▲ ៤៣៩ | ▲ ៧% |
| ២ | ស្បែកជើង | ៩២២ | ១ ១១៤ | ▲ ១៩១ | ▲ ២១% |
| ៣ | សម្ភារៈធ្វើដំណើរ | ៧៧៥ | ១ ១៧៩ | ▲ ៤០៤ | ▲ ៥២% |
| ៤ | ម៉ាស៊ីនបរិធាន និងសម្ភារៈអគ្គិសនី | ៦០១ | ៨៥០ | ▲ ២៤៩ | ▲ ៤១% |
| ៥ | កង់ | ៤២៦ | ៥១៤ | ▲ ៨៧ | ▲ ២១% |
| ៦ | អង្ករ | ៣៦៥ | ៣២៦ | ▼ ៣៩ | ▼ ១១% |
| ៧ | គ្រឿងសង្ហារឹមនិងបរិធានបំភ្លឺ | ៥៥៥ | ៧៧៦ | ▲ ២២១ | ▲ ៤០% |
| ៨ | កៅស៊ូក្រែប | ១៩៥ | ៣២៩ | ▲ ១៣៤ | ▲ ៦៩% |
| ៩ | ស្ករអំពៅ | ៣២ | ៤២ | ▲ ១០ | ▲ ៣២% |
| ១០ | បន្លែនិងផ្លែឈើ | ១១០ | ១៦៧ | ▲ ៥៧ | ▲ ៥១% |
| ១១ | មុខទំនិញផ្សេងទៀត | ៤ ៤៧០ | ២ ៤៥៣ | ▼ ២ ០១៦ | ▼ ៤៥% |
| **សរុប៖** | | **១៤ ៥៥០** | **១៤ ២៨៦** | ▼ **២៦៤** | ▼ **២%** |

## តារាងទី៤៖ ស្ថិតិនាំចូលទំនិញសំខាន់ៗ (ឯកតា៖ លានដុល្លារអាមេរិក)

| ល.រ. | មុខទំនិញផ្សេងទៀត | រយៈពេល១០ខែដើមឆ្នាំ២០២០ | រយៈពេល១០ខែដើមឆ្នាំ២០២១ | បម្រែបម្រួល | |
|---|---|---|---|---|---|
| | | | | ទឹកប្រាក់ | (%) |
| ១ | វាយនភ័ណ្ឌ | ៣ ៥៣៣ | ៤ ៤១២ | ▲ ៨៨០ | ▲ ២៥% |
| ២ | សម្ភារៈសំណង់ | ៨០២ | ១ ០៦៣ | ▲ ២៦១ | ▲ ៣៣% |
| ៣ | ដែក | ៣២១ | ៣២៦ | ▲ ៤ | ▲ ១% |
| ៤ | ស៊ីម៉ង់ត៍ | ៥៩ | ៤០ | ▼ ១៩ | ▼ ៣៣% |
| ៥ | ទឹកបរិសុទ្ធ | ២៦០ | ២២៥ | ▼ ៣៥ | ▼ ១៣% |
| ៦ | ស្រាបៀរ និងស្រាចំរុះ | ១៤ | ៨ | ▼ ៦ | ▼ ៤២% |
| ៧ | រថយន្ត | ៩០១ | ៩៧៧ | ▲ ៧៦ | ▲ ៨% |
| ៨ | ផលិតផលឱសថ | ៣១៩ | ៦១៤ | ▲ ២៩៥ | ▲ ៩២% |
| ៩ | ជីកសិកម្ម និងថ្នាំ | ២៧៦ | ៣៩០ | ▲ ១១៤ | ▲ ៤១% |
| ១០ | គ្រឿងអេឡិចត្រូនិច និងសម្ភារៈអគ្គិសនី | ១ ៩០៧ | ២ ០១៤ | ▲ ១០៨ | ▲ ៦% |
| ១១ | មុខទំនិញផ្សេងទៀត | ៦ ២៣២ | ១២ ៩៩១ | ▲ ៦ ៧៥៩ | ▲ ១០៨% |
| **សរុប៖** | | **១៤ ៦២៤** | **២៣ ០៦០** | ▲ **៨ ៤៣៦** | ▲ **៥៨%** |

## ក្រាហ្វិកទី៖ ៧ ស្ថិតិនាំចេញ និង ស្ថិតិនាំចូល







---

*ប្រភព៖ របាយការណ៍ បូកសរុបលទ្ធផលការងារពាណិជ្ជកម្មឆ្នាំ២០២១-២០២២ (ទំព័រទី៨)*

*ប្រភព៖ របាយការណ៍ បូកសរុបលទ្ធផលការងារពាណិជ្ជកម្មឆ្នាំ២០២១-២០២២ (ទំព័រទី៩)*

*ប្រភព៖ របាយការណ៍ បូកសរុបលទ្ធផលការងារពាណិជ្ជកម្មឆ្នាំ២០២១-២០២២ (ទំព័រទី១០)*

# តារាងទី៥៖ ស្ថិតិនាំចេញ ២០២២-២០២៣

| បរិយាយ | ខែសីហា ឆ្នាំ២០២២ | ខែសីហា ឆ្នាំ២០២៣ | កំណើន (+/-)% |
|---|---|---|---|
| អាមេរិក | 779,573,102 | 968,693,549 | 24.26 |
| អង់គ្លេស | 102,102,097 | 90,708,867 | - 11.16 |
| សហគមអឺរ៉ុប | 343,881,053 | 307,415,132 | -10.60 |
| កាណាដា | 106,919,714 | 68,191,932 | -36.22 |
| អាស៊ាន | 412,742,336 | 298,393,087 | -27.70 |
| ជប៉ុន | 125,337,147 | 118,494,952 | -5.46 |
| ចិន | 105,175,229 | 119,925,326 | 14.02 |
| អូស្ត្រាលី | 18,494,115 | 12,835,778 | -30.60 |
| ឥណ្ឌា | 16,216,116 | 19,089,228 | 17.72 |
| ណូវ៉ែលហ្សេឡង់ | 2,553,016 | 1,078,529 | -57.75 |
| អារ៉ាប៊ីសាអូឌីត | 4,669,610 | 4,350,240 | -6.84 |
| កូរ៉េ | 21,052,174 | 23,667,844 | 12.42 |
| បណ្តាប្រទេសផ្សេងៗក្នុងពិភពលោក | 76,837,404 | 60,491,688 | -21.27 |
| សរុប | 2,115,553,112 | 2,093,336,151 | -1.05 |

---

*ប្រភព៖ នាយកដ្ឋាននាំចេញ នាំចូល៖ តួលេខនាំចេញនេះ ជាតួលេខដែលទទួលបាន ក្រោមការផ្តល់ វិញ្ញាបនបត្របញ្ជាក់ដើមកំណើត ទំនិញ ៦ តួលេខអាជ្ញាបណ្ណនាំចេញមានទឹកប្រាក់សុបប្រមាណ171,434.00 ដុល្លាអាមេរិក ប្រភព៖ នាយកដ្ឋាននាំចេញ នាំចូល*

*ប្រភព៖ តួលេខអាជ្ញាបណ្ណនាំចេញមានទឹកប្រាក់សុបប្រមាណ171,434.00 ដុល្លាអាមេរិក ប្រភព៖ នាយកដ្ឋាននាំចេញ នាំចូល*

*ប្រភព៖ តួលេខលិខិតបញ្ជាក់ការនាំចេ ញត្បូងពេជ្រ មិនទាន់កែ ច្នៃ មានទឹកប្រាក់សុបប្រ មាណ1,212,014.00ដុល្លាអាមេរិក ប្រភព៖ នាយកដ្ឋាននាំចេញ នាំចូល*

*ប្រភព៖ តួលេខលិខិតបញ្ជាក់ការនាំចូលត្បូងពេជ្រមិនទាន់កែច្នៃមានទឹកប្រាក់សុបប្រមាណ 11,422,415.00ដុល្លាអាមេរិក ប្រភព៖ នាយកដ្ឋាននាំចេញ នាំចូល*

ផលិតផលនាំចេញពីប្រទេសកម្ពុជាទៅបណ្តាលប្រទេស ក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងពាណិជ្ជកម្មសេរី (Cambodia Export Under FTA and GSP/MFN Shame)។

**តារាងទី៦៖ តារាងប្រៀបតម្លៃផលិតផលការនាំចេញពីកម្ពុជាទៅបណ្តាលប្រទេស ក្រោមប្រព័ន្ធ អនុគ្រោះពន្ធពាណិជ្ជកម្ម និងពាណិជ្ជកម្មសេរីលើទីផ្សារពិភពលោក**

| ប្រទេស | ប្រភេទទំនិញ | ខ្នាត | ខែតុលា ឆ្នាំ២០២៣ | ខែវិច្ឆិកា ឆ្នាំ២០២៣ | កំណើន (+/-)% |
|---|---|---|---|---|---|
| លើទីផ្សារពិភពលោក | សំលៀកបំពាក់ | DOZ | 569,896,804 | 574,639,981 | 0.01 |
| | វាយនភ័ណ្ឌ | N/A | 6,943,761 | 5,300,150 | -0.24 |
| | ស្បែកជើង | PRS | 72,632,844 | 105,791,342 | 0.46 |
| | កាបូបធ្វើដំណើរ | DOZ | 105,094,808 | 136,289,893 | 0.30 |
| | កង់ | SET | 26,495,192 | 28,979,591 | 0.09 |
| | អង្ករ | N/A | 62,392,553 | 134,719,636 | 1.16 |
| | ទំនិញកសិកម្ម | - | 103,938,369 | 173,240,222 | 0.67 |
| | ផលិតផលផ្សេងៗ | N/A | 621,604,458 | 753,205,303 | 0.21 |

*ប្រភព៖ នាយកដ្ឋាននាំចេញ នាំចូល៖ តួលេខនាំចេញនេះ ជាតួលេខដែលទទួលបានក្រោមការផ្តល់វិញ្ញាបនបត្របញ្ជាក់ដើម កំណើត ទំនិញ។*

| បរិយាយ | ខែតុលា ឆ្នាំ២០២៣ | ខែវិច្ឆិកា ឆ្នាំ២០២៣ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|
| អាមេរិក | 639,168,457 | 696,384,136 | 57,215,679 | 8.95 |
| អង់គ្លេស | 53,994,509 | 63,379,911 | 9,385,402 | 17.38 |
| សហគមន៍អឺរ៉ុប | 274,133,487 | 248,525,473 | -25,608,014 | -9.34 |
| កាណាដា | 60,700,819 | 72,104,993 | 11,404,174 | 18.79 |
| អាស៊ាន | 245,389,372 | 434,440,495 | 189,051,123 | 77.04 |
| ជប៉ុន | 87,733,475 | 98,857,378 | 11,123,903 | 12.68 |
| ចិន | 104,476,982 | 129,804,258 | 25,327,276 | 24.24 |
| អូស្ត្រាលី | 13,081,402 | 12,562,029 | -519,373 | -3.97 |
| ឥណ្ឌា | 22,246,769 | 51,053,144 | 28,806,375 | 129.49 |
| ណូវែលហ្សេឡង់ | 1,160,804 | 1,611,593 | 450,789 | 38.83 |
| អារ៉ាប់រួមអេមីរ៉ាត | 4,771,794 | 8,774,479 | 4,002,685 | 83.88 |
| កូរ៉េ | 13,077,635 | 21,647,544 | 8,569,909 | 65.53 |
| បណ្តាប្រទេសផ្សេងៗក្នុងពិភពលោក | 49,063,285 | 73,020,683 | 23,957,398 | 48.83 |
| សរុប | 1,568,998,789 | 1,912,166,117 | 343,167,328 | 21.87 |

*ប្រភព៖ នាយកដ្ឋាននាំចេញនាំចូល៖ តួលេខនាំចេញនេះ ជាតួលេខដែលទទួលបាន ក្រោមការផ្តល់វិញ្ញាបនបត្របញ្ជាក់ ដើមកំណើតទំនិញ។*

**២.១.៤.ចំណាយរដ្ឋាភិបាល និងចំណូលរដ្ឋាភិបាល**

ប៉ុន្មានឆ្នាំចង់ក្រោយនេះ របាយការណ៍របស់ក្រសួងសេដ្ឋកិច្ចបានបង្ហាញថាការចំណាយរបស់រដ្ឋាភិបាលឃើញថាមានការកើនឡើងទៅតាមដំណាក់កាលពីមួយឆ្នាំទៅមួយឆ្នាំ នៃតម្រូវការជាក់ស្តែងដែរការកើនឡើងនេះស្របទៅនឹងការកើនឡើងនៃផលិតផលក្នុងស្រុកសរុប ផងដែរ។ ក៏ប៉ុន្តែយើងឃើងថាក្នុងកំឡុងនៃការរីករាតត្បាត នៃជំងឺសកល កូវីដ-១៩ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាក៏បានទទួលផលប៉ះពាល់ដែរ ទាំងនេះអាចឆ្លុះបញ្ចាំឲ្យឃើងថាគោលនយោបាយសារពើពន្ធរបស់របស់ថាភិបាលក្នុងការបង្កើនចំណាយពីមួយឆ្នាំទៅមួយឆ្នាំគឺសម្រាប់ដោះស្រាយបញ្ហាភាពជាប់គាំង ឬបញ្ហាយឺតយ៉ាវដែរបានកើតឡើងនៅក្នុងសេដ្ឋកិច្ចជាក់ស្តែង និងដើម្បីអោយមានភាពស្របគ្នានៃការអភិវឌ្ឍន៍ផងដែរ។

**២.១.៥.អតិផរណា**

អតិផរណាជាមធ្យមក្នុងឆ្នាំ២០១៨ (៣.១១%) ទាបជាងឆ្នាំ២០១៩មានកម្រិតត្រឹម ៣.២៤% និងឆ្នាំ ២០១៧ (៣.៤៤%) បណ្តាលមកពីការថមថយកំណើនថ្លៃក្រុមអាហារក្នុងឆ្នាំ ២០១៨ ដែរមាន ២.៥ មកត្រឹម ២.១% ក្នុងឆ្នាំ២០១៩។ ដោយឡែកនៅក្នុងឆ្នាំ ២០២០ ស្ថានភាពអតិផរណាបន្តធ្លាក់ចុះគួរឲ្យកត់សម្គាល់ក្នុងអត្រា -0.៦៧% ទាបជាងឆ្នាំ ២០១៩ ដោយសារតែបណ្តាលមកពីផលប៉ះពាល់នៃវិបត្តិនៃ ជំងឺរីករាលត្បាត កូវីដ-១៩ និងគ្រោះទឹកជំនន់ទឹកភ្លៀងដែរបានធ្វើឲ្យថមថយដំណើរការនៃការផ្គត់ផ្គង់សម្រាប់តម្រូវការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាជនបើទោះបីជាក្រុមទំនិញនិងសេវពាក់ព័ន្ធនិងប្រេងឥន្ធនៈបានធ្លាក់ថ្លៃអតិថរណាមានភាពខុសគ្នាខ្លាំងជាមួយនិងឆ្នាំ ២០១៩ ក៏ដោយ។ ចំណែកអតិផរណានៅឆ្នាំ ២០២២ ត្រូវបានកើនឡើងដល់ ៥.៤% បណ្តាលមកពីការកើនឡើងនៃ ថ្លៃថាមពលដោយសារឥទ្ធិពលនៃការបន្ថែមលើកំណើនតម្រូវការក្នុងស្រុកនៅពេលស្ថានភាពប្រសើរឡើង។ ប្រទេសកម្ពុជាមានអត្រាអតិផរណាទាបបំផុតបន្ទាប់ពីឆ្នាំ ២០២០ នោះគឺឆ្នាំ២០២៣ មានចំនួន ២.១% ធ្លាក់ចុះពី ៥.៤% បើធៀបនិងឆ្នាំ ២០២២ ដោយសារផលិតផលសំខាន់ៗ មួយចំនួនទាក់ទងនិងប្រេងឥន្ធនៈ និងឧស្ម័នបានធ្លាក់ចុះវិញ។

ក្រុមអ្នកជំនាញបានអះអាងថាអត្រាអតិផរណាទាំបក៏ឆ្លុះបញ្ចាំងពីភាពល្អប្រសើរនៃផលិតលផលក្នុងស្រុកដោយកម្ពុជាបានក្លាយជាប្រទេសសំខាន់ក្នុងការផ្គត់ផ្គង់គ្រឿងបរិក្ខា បរិភោគនៅលើទីផ្សារក្នុងតំបន់ និងសកល។ ទោះបីសេដ្ឋកិច្ចដែរបណ្តាលមកពីសង្គ្រាមរវាងអ៊ុយក្រែន និងរ៉ុស្ស៊ីក៏ដោយដែរបនាកំពុងបន្ត និងការប្រកួតប្រជែងភូមសាស្ត្រនយោបាយនៅក្នុងចំណោមប្រទេសមហាអំណាចក៏បានជំរុញឲ្យតម្លៃស្បៀងអាហារកើនឡើងតិចតួចប៉ុណ្ណោះ ជាពិសេសការធ្លាក់ចុះតម្លៃប្រេងឆៅដែរធ្វើឲ្យតម្លៃម្ហូបអាហារផ្សេងទៀតធ្លាក់ចុះយ៉ាងខ្លាំង។

**ក្រាហ្វិកទី៨៖ អត្រាអតិផរណា ជាមធ្យមប្រចាំឆ្នាំ**




## ២.២.ស្ថានភាពទូទៅនៃគោលនយោបាយសារពើពន្ធ

### ❖ ស្ថានភាពអតិផរណានៅកម្ពុជា

នៅក្នុងឆ្នាំ២០២១ អតិផរណារួមបន្តមានស្ថិរភាព និងស្ថិតក្នុងកម្រិតជាមធ្យម ១.២៩% ប្រហាក់ប្រហែលនឹងឆ្នាំ២០២០ (-0.៦៧ %)។ ស្ថិរភាពអតិផរណាក្នុងឆ្នាំ២០២១ បណ្តាលមកពីការថមថយល្បឿននៃថ្លៃក្រុមម្ហូបអាហារ និងការកើនឡើងវិញនៃថ្លៃក្រុមទំនិញ និងសេវាពាក់ព័ន្ធនឹង ប្រេងឥន្ធនៈ (ដោយប្តូរ ស្ថានភាពបរិត្តផរណាក្នុងឆ្នាំ២០២០ មកជាអតិផរណាក្នុងឆ្នាំ២០២១វិញ)។

### ❖ ស្ថានភាពហិរញ្ញវត្ថុសាធារណៈ

- ចំណូលថវិកាជាតិ

នៅក្នុងផែនការថវិកាជាតិសម្រាប់អនុវត្តឆ្នាំ២០២១ គោលដៅបង្កើនចំណូលសរុបថវិកាជាតិ ត្រូវ សម្រេចបាន ២៧.៧៦៨.៧៤២ លានរៀល ហើយក្នុងនោះចំណូលក្នុងប្រទេសថវិការដ្ឋស្មើនឹង ២១.៤៤៥,៥៩២ លានរៀល ត្រូវជា ១៨.១៨% នៃផ.ស.ស។ គ្រោងចំណូលចរន្តថវិកាថ្នាក់ជាតិសរុប មាន ចំនួន ១៩.៧០៥.៩៨៣ លានរៀល ដែលក្នុងនោះចំណូលពន្ធដារស្មើនឹង ៤១% នៃចំណូលចរន្ត ថ្នាក់ជាតិ សរុប ចំណូលបានពីពន្ធគយស្មើនឹង ៤៨% (ទាំងពន្ធដារ និងពន្ធគយ ស្មើនឹង ១៧,៥២០,000 លានរៀល) និងចំណូលមិនមែនសារពើពន្ធស្មើនឹង២.១៨៥,៩៨៣លានរៀល ត្រូវជា ១១% នៃចំណូលចរន្តថ្នាក់ជាតិ សរុប។ ចំណូលចរន្តថវិកាថ្នាក់ក្រោមជាតិមានចំនួន ១,៥១៨.៤០៦ លានរៀល។ ចំណែកចំណូលមូលធន ថវិការដ្ឋ ត្រូវបានគ្រោងទុកសរុបចំនួន ៦,៥៤៤,៣៥៣ លាន រៀល មានកំណើន 0.៧% ធៀបនឹងច្បាប់ឆ្នាំ ២០២០ ដែលក្នុងនោះ ចំណូលមូលធនក្នុងប្រទេសស្មើ នឹង២២១,២០៣ លានរៀល និងចំណូលមូលធន ក្រៅប្រទេសស្មើនឹង ៦,៣២៣.១៥០ លានរៀល។ គ្រោងចំណូលថវិកាជាតិឆ្នាំ២០២១ មានការកើនឡើង ដោយសារតែការងើបឡើងវិញនៃសកម្មភាព សេដ្ឋកិច្ចបន្ទាប់ពីការបិទខ្ទប់ក្នុងបរិបទកូវីដ១៩ ព្រមទាំងការ អនុវត្តនូវយុទ្ធសាស្ត្រគៀងគរចំណូលក្នុង ឆ្នាំ២០១៩-២០២៣ ដែលផ្តោតនៅក្នុងការប្រមូលចំណូលពន្ធដារ ចំណូលពន្ធគយ និងចំណូលមិន មែនសារពើពន្ធនានាដែលអនុញ្ញាតឱ្យការប្រមូលចំណូលនៅក្នុងឆ្នាំ ២០២១ ទទួលបាននូវប្រសិទ្ធ ភាព តម្លាភាព និងយុត្តិធម៌។

- ចំណាយថវិកាជាតិ

សម្រាប់ឆ្នាំ ២០២១ ចំណាយសរុបថវិការជាតិ ឬចំណាយសរុបថវិកាជាតិ ត្រូវបានគ្រោង ចំនួន ៣២ ០០៩៧៤២ លានរៀល ត្រូវជា ២៧,១៤% នៃ ផសស គឺថយចុះ ៤,0% ធៀបនឹងច្បាប់ឆ្នាំ ២០២០ ដែលក្នុងនោះ(១)-ចំណាយចរន្តថវិការដ្ឋមានចំនួន១៨៧៥១ ០៤១ លានរៀល ត្រូវជា ១៥,៩0% នៃ ផសស គឺថយចុះ ៥,៤% ធៀបនឹងច្បាប់ឆ្នាំ ២០២០ និង (២)- ចំណាយមូលធនថវិកា រដ្ឋមានចំនួន ១៣ ២៥៨ ៧០១ លានរៀល ត្រូវជា ១១,២៤% នៃ ផសស គឺថយចុះ ១,៩% ធៀបនឹង ច្បាប់ ឆ្នាំ ២០២០។

## ក្រាហ្វិកទី៩៖ ចំណាយចរន្ត និងចំណាយមូលធន




---

* ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ថវិការសង្ខេបឆ្នាំ២០២២ ទំព័រទី២៦

## ក្រាហ្វិកទី១០៖ ចំណាយចរន្តថ្នាក់ជាតិ




- ឱនភាពថវិកាជាតិ

តាមការគ្រោងទុក ថវិកាចរន្តអាចសម្រេចបាននូវអតិរេក(ចំណូលចរន្តធំជាងចំណាយចរន្ត) ហើយ រក្សាបានក្នុងកម្រិតប្រមាណ ២.១០% នៃផ.ស.ស ប៉ុន្តែកម្ពុជាអាចជួបនូវឱនភាពថវិកាសរុប ដែលស្មើនឹង -៨.៨៦% នៃផ.ស.ស។ ឱនភាពថវិកាសរុបនេះនឹងត្រូវបានបំពេញដោយហិរញ្ញប្បទាន ក្រៅប្រទេសក្នុងទំហំ ៤.៦៣% នៃផ.ស.ស មូលនិធិទ្រទ្រង់ថវិកាប្រមាណ ០.៧៣% នៃផ.ស.ស និង ប្រាក់បញ្ញើរបស់រាជរដ្ឋា ភិបាលក្នុងទំហំ ៣.៦០% នៃផ.ស.ស។

### តារាងទី៧៖ តារាងតុល្យភាពថវិការរដ្ឋ

| តារាងតុល្យភាពថវិការរដ្ឋ | | | | | |
|---|---|---|---|---|---|
| សូចនាករ | ២០២០ | ២០២១ | | ២០២២ | |
| | អនុវត្ត | ច្បាប់ | អនុវត្ត | ច្បាប់ | ប៉ាន់ស្មាន |

| *ផសស(លានរៀល)* | *១០៩០៦១៩០៧* | *១១០ ៥០៥ ៩១៦* | | *១២៤១៦១៦២៥ (*)* | *១២០៣១២៤៧៧ (**)* |
|---|---|---|---|---|---|
| *ចំណូលក្នុងប្រទេស(% ផសស)* | *២១,៨១%* | *១៩,៤១%* | *២០,៦៥%* | *២០,៦១%* | *២១,២៧%* |
| *-ចំណូលចរន្ត (% ផសស)* | *២១,៦៤%* | *១៩,២១%* | *២០,៦០%* | *១៩,៥៦%* | *២០,១៩%* |
| *ចំណាយសរុបថវិការដ្ឋ (% ផសស)* | *២០,៨០%* | *២៨,៩៧%* | *៣១,០៣%* | *២៧,៩៥%* | *២៨,៨៥%* |
| *-ចំណាយចរន្ត (% ផសស)* | *១៧,២៥%* | *១៦,៩៧%* | *១៩,៥៣%* | *១៦,៧៩%* | *១៧,៣៣%* |
| *អតិរេកចរន្ត (% ផសស)* | *៤,៣៩%* | *២,២៤%* | *១,០៧%* | *២,៧៧%* | *២,៨៦%* |
| *ឱនភាពសរុប (% ផសស)* | *-៧,០០%* | *-៩,៥៦%* | *-១០,៣៧%* | *-៧,៣៤%* | *-៧,៥៨%* |

**សម្គាល់៖**

- *(*) ផសស តាមថ្លៃបច្ចុប្បន្ន ដែរបានព្យាករណ៏ក្នុងឆ្នាំ២០២១ សម្រាប់ការរៀបចំច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២*

- *(**) ផសស តាមថ្លៃបច្ចុប្បន្ន ផ្អែកលើក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២២(ពាក់កណ្តាលឆ្នាំ២០២២)*

## ២.៣.ការអនុវត្តគោលនយោបាយសារពើពន្ធនៅកម្ពុជា

### ២.៣.១.អគ្គនាយកដ្ឋានគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានគោលនយោបាយ ជាអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ប្រកាសនេះ មានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅ

នៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គ នាយកដ្ឋានគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។អគ្គនាយកដ្ឋានគោលនយោបាយ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំ និងតាមដានការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់រយៈពេលខ្លី, រយៈពេលមធ្យម និងរយៈពេលវែង។
- សិក្សា និងវាយតម្លៃការវិវត្តសេដ្ឋកិច្ចជាតិទាំងមូល ជាពិសេស វិស័យធំៗ សូចនាករម៉ាក្រូសេដ្ឋ កិច្ច និង ហិរញ្ញវត្ថុសំខាន់ៗ ដើម្បីដាក់ចេញនូវគោលនយោបាយ, យុទ្ធសាស្ត្រ និងអនុសាសន៍ ជូនថ្នាក់ដឹកនាំក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- រៀបចំ, តាមដាន និងវិភាគការអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីចំណូល និងចំណាយសាធារណៈ ហើយផ្អែកលើមូលដ្ឋាននេះ លើកជាយោបល់ និងស្នើវិធានការជូន ថ្នាក់ដឹកនាំក្រសួងអំពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យមានប្រសិទ្ធភាព, តម្លាភាព, តុល្យភាព និងគណនេយ្យភាព។
- រៀបចំក្របខ័ណ្ឌសារពើពន្ធរយៈពេលមធ្យម (MTFF) និងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូ សេដ្ឋកិច្ច និ គោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់រៀបចំថវិកាប្រចាំឆ្នាំ
- រៀបចំ និងវិភាគតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ (TOFE) និងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (GFS)។
- សម្របសម្រួល និងតាមដានការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រជាតិនានា ជាមួយស្ថា ប័នជាតិ។
- តាមដាន, វិភាគ និងវាយតម្លៃលើការអនុវត្ត និងការប្រព្រឹត្តទៅនៃហិរញ្ញវត្ថុសាធារណៈ។
- រៀបចំក្របខ័ណ្ឌសារពើពន្ធរយៈពេលមធ្យម និងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយ ហិរញ្ញវត្ថុសាធារណៈ ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការ គ្រប់គ្រងប្រចាំឆ្នាំនីមួយៗ ទទួលបន្ទុកក្នុងការពិភាក្សា ផ្លាស់ប្តូរយោបល់បច្ចេកទេស និងគោល នយោបាយ ជាមួយស្ថាប័នពាក់ព័ន្ធ, ដៃគូ- អភិវឌ្ឍន៍ និងអង្គការហិរញ្ញវត្ថុអន្តរជាតិ ស្តីពីការអនុ វត្តម៉ាក្រូសេដ្ឋកិច្ច, ទស្សនវិស័យ និងហានិភ័យនានា។

- ផ្សព្វផ្សាយសកម្មភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលរៀបចំឡើង ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទទួលបន្ទុកសម្របសម្រួល និងតាមដានការអនុវត្តយុទ្ធសាស្ត្រជាតិ និងគោលនយោបាយសេដ្ឋកិច្ចផ្សេងៗ។
- ស្រាវជ្រាវ, វិភាគគោលនយោបាយប្រចាំឆ្នាំ និងចងក្រងជាឯកសារពាក់ព័ន្ធនឹងវិស័យម៉ាក្រូសេដ្ឋកិច្ច, សារពើពន្ធ និងមិនមែនសារពើពន្ធ និងវិស័យសំខាន់ៗ ទៅតាមកម្មវិធី និងការណែនាំរបស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។
- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ។

## ២.៤.ឧបករណ៍គោលនយោបាយសារពើពន្ធនៅកម្ពុជា

### ២.៤.១.ចំណូលសារពើពន្ធ

ចំណូលសារពើពន្ធគឺជាពន្ធអាករនិងសិទ្ធិដែលត្រូវបានបង្វែរជាកាតព្វកិច្ចទៅឲ្យរដ្ឋ។ ចំណូលសារពើពន្ធ រួមមានចំណូលបានមកពី ពន្ធនិងអាករក្នុងប្រទេស និង ពន្ធនិងអាករលើពាណិជ្ជកម្មក្រៅប្រទេស និងចំណូលសារពើពន្ធដទៃទៀត។

ក. ចំណូលពីពន្ធ និងអាករក្នុងប្រទេស (អគ្គនាយកដ្ឋានពន្ធដារ)

ចំណូលពីពន្ធ និងអាករក្នុងប្រទេស ដែលប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ រួមមានៈ ពន្ធលើប្រាក់ចំណូល គឺជាបំណុលរបស់បុគ្គលនិវាសនជនចំពោះប្រាក់ចំណូលប្រភពកម្ពុជា និងប្រាក់ចំណូលប្រភពបរទេស និងរបស់បុគ្គលអនិវាសនជនចំពោះប្រាក់ចំណូលប្រភពកម្ពុជា។

ពន្ធលើប្រាក់បៀវត្ស គឺជាពន្ធប្រចាំខែ កំណត់លើប្រាក់បៀវត្សដែលបានទទួលក្នុងក្របខណ្ឌនៃការបំពេញសកម្មភាពបំរើការងារ។

អាករលើតម្លៃបន្ថែម (VAT) គឺជាប្រភេទពន្ធប្រយោល ដែលគិតទៅលើតម្លៃបន្ថែមរបស់ផលិតផល ដែលបានឆ្លងកាត់ ដំណាក់កាលនីមួយៗនៃផលិតកម្ម។ ពន្ធនេះត្រូវបានយកទៅលើដំណាក់កាលនីមួយៗនៃផលិតកម្ម ឬការធ្វើចរាចរផលិតផល គឺចាប់តាំងពីនៅជាវត្ថុធាតុដើមរហូតដល់ការប្រើប្រាស់។

អាករពិសេសលើទំនិញ និងសេវាមួយចំនួន ជាប្រភេទពន្ធប្រយោល ដែលត្រូវបានយកចំពោះប្រភេទទំនិញ និងសេវាមួយចំនួន ពន្ធនេះត្រូវបានបូកបញ្ចូលក្នុងតម្លៃទំនិញ និងសេវា ហើយអ្នកប្រើប្រាស់បង់ចូលរដ្ឋនៅពេលអ្នកប្រើប្រាស់ទិញទំនិញ ឬសេវានោះ។

ពន្ធកាត់ទុកទូទៅ គឺជាពន្ធដែលត្រូវបានកាត់ទុកដោយអ្នកជាប់ពន្ធនិវាសនជនលើការទូទាត់មួយចំនួនដែលធ្វើឡើងជាសាច់ប្រាក់ ឬជាវត្ថុឱ្យទៅអ្នកជាប់ពន្ធនិវាសនជន និងអនិវាសន ជន។ អ្នកជាប់ពន្ធនិវាសនជនប្រកបអាជីវកម្មទាំងអស់ត្រូវប្រមូលពន្ធកាត់ទុក។

ពន្ធលើចំណេញមូលធន គឺជាពន្ធដែលអ្នកជាប់ពន្ធមានកាតព្វកិច្ចត្រូវបង់ជូនអគ្គនាយកដ្ឋានពន្ធដា នៅពេលមានការផ្ទេរកម្មសិទ្ធិ ឬចាត់ចែងកម្មសិទ្ធិ លើមូលធនរបស់ខ្លួន។

អាករសម្រាប់បំភ្លឺសាធារណៈ ជាអាករមួយប្រភេទដែលត្រូវកំណត់លើគ្រប់ដំណាក់កាល នៃការផ្គត់ផ្គង់សុរាមេរ័យ និងបារី បន្ទាប់ពីបាននាំចូល ឬ ផលិតផលិតផលជាប់អាករ ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជាប្រយោជន៍ដល់ថវិកាថ្នាក់ក្រោមជាតិសម្រាប់បំភ្លឺសាធារណៈ ដែលពាក្យ "ផលិតផលជាប់អាករ" សំដៅដល់ សុរាមេរ័យ និងបារី ។

អាករលើការស្នាក់នៅ គឺត្រូវបានកំណត់ និងប្រមូលលើការស្នាក់នៅក្នុងសណ្ឋាគារ ដែលជាប់ពន្ធក្នុងបរស្វ័យប្រកាស សម្រាប់ជាគុណប្រយោជន៍ថវិកាថ្នាក់ក្រោមជាតិ។ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទពន្ធប៉ាតង់ ជាពន្ធកំណត់លើផលរបរសរុបប្រចាំឆ្នាំ ដែលត្រូវបង់ក្នុងកំឡុងពេលចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ។

ពន្ធលើដីធ្លីមិនបានប្រើប្រាស់ គឺប្រមូលចំពោះអចលនទ្រព្យទាំងឡាយណាដែលត្រូវបានចាត់ទុកជា "ដីធ្លីមិនបានប្រើប្រាស" ។

ពន្ធប្រថាប់ត្រា ត្រូវបានប្រមូលចំពោះ ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចនទ្រព្យ ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន និងការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់មធ្យោបាយដឹកជញ្ជូន ឬយានយន្តគ្រប់ប្រភេទ, ការផ្ទេរចំណែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុន, កិច្ចសន្យាផ្គត់

ផ្គង់ទំនិញ ឬសេវា ដែលប្រើប្រាស់ថវិការដ្ឋ, លិខិតមានលក្ខណៈគតិយុត្តិជាអាទិ៍ លិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងលិខិតស្តីពីការបិទក្រុមហ៊ុន។

ពន្ធតែមប្រឹសារពើពន្ធ អនុវត្តលើប័ណ្ណប្រកាសពាណិជ្ជកម្ម ស្លាកអាជីវម្ម (យីហោ) ផ្ទាំងអក្សរផ្ទាំងរូបភាព ក្នុងគោលបំណងផ្សាយពាណិជ្ជកម្ម ឬគូសភ្ជាប់នឹងមធ្យោបាយដឹកជញ្ជូននានា។

ពន្ធលើអចលនទ្រព្យ ជាប្រភេទពន្ធប្រចាំឆ្នាំមួយ ដែលត្រូវប្រមូលចំពោះអចលនទ្រព្យណាដែលមានតម្លៃលើសពី ១០០.០០០.០០០ (មួយរយលាន) រៀល និងមានទីតាំងស្ថិតនៅក្នុងភូមិសាស្ត្ររដ្ឋបាលរាជធានី និងរដ្ឋបាលក្រុងនៃខេត្តនានា ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**២.៤.២.ចំណូលមិនមែនសារពើពន្ធ**

ចំណូលមិនមែនសារពើពន្ធ សំដៅដល់ចំណូលដែលទទួលបានមកពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ចំណូលពីសហគ្រាសសាធារណៈ ភារកម្មសាធារណៈ និងអង្គភាពហិរញ្ញវត្ថុដទៃទៀត ចំណូលពីសេវាសាធារណៈ ចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្ម វៀរលែងតែការពិន័យនិងការដាទណ្ឌកម្មពាក់ព័ន្ធនិងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀត។

ចំណូលមិនមែនសារពើពន្ធត្រូវបានបែងចែក ដូចខាងក្រោម៖

ក. ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ

ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ មានជាអាទិ៍៖

ចំណូលពីការលក់ ការដូរ ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ជាចំណូលដែលទទួលបានមកពីការលក់ ការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ជាចលនទ្រព្យ និងអចលទ្រព្យ។

ចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ ជាចំណូលដែលទទួលបានមកពីថ្លៃជួល ភាគចំណែក និងការបែងចែកផលចំណេញ ដូចមានចែងក្នុងកិច្ចសន្យា ឬកិច្ចព្រមព្រៀងនៃការជួលទ្រព្យសម្បត្តិរដ្ឋជាចលនទ្រព្យ និង/ឬអចលនទ្រព្យដែលមានដូចជា៖

- ការជួលដីនិងអគារ ជាចំណូលដែលទទួលបានមកពីការជួលដីទំនេររបស់រដ្ឋ ឬការជួលដីមានអគារដែលជាការជួលដីនិងអគារទាំងមូលរបស់រដ្ឋ។

• ការជួលអគារ ឬសំណង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ជាចំណូលដែលទទួលបានមកពីការជួលផ្នែកនៃអគារ ឬសំណង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ជាអាទិ៍ ការជួលការិយាល័យ ការជួលអាហារដ្ឋាន កន្លែងផ្សព្វផ្សាយ កន្លែងលក់ដូរ ឬសំណង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។

• ការជួលសម្ភារៈបរិក្ខា មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រ ជាចំណូលដែលទទួលបានមកពីការជួលសម្ភារៈ មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្ររបស់រដ្ឋ ជាអាទិ៍ បរិក្ខារបច្ចេកទេសនិងឧស្សាហកម្ម យានយន្ត ម៉ាស៊ីនស្ទូច ត្រាក់ទ័រ។

• ការជួលទ្រព្យសម្បត្តិរដ្ឋ ជាចលនទ្រព្យ និងអចលទ្រព្យ ដទៃទៀត។

• ចំណូលពីសម្បទានសេវាសាធារណៈ ចែកចេញជាពីចំណូលពីគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន និងចំណូលពីសម្បទានគ្រប់គ្រងសេវាសាធារណៈ ដែលមានដូចខាងក្រោម៖

• ចំណូលពីគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ជាចំណូលដែលទទួលបានមកពីគម្រោងវិនិយោគ ដូចមានកំណត់ក្នុងលិខិតគតិយុត្តិបង្កើតចំណូលមិនមែនសារពើពន្ធពាក់ព័ន្ធនឹងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងការផ្គត់ផ្គង់សេវាសាធារណៈ។

• ចំណូលពីសម្បទានគ្រប់គ្រងសេវាសាធារណៈ ជាចំណូលដែលទទួលបានពីការប្រគល់សិទ្ធិជូនបុគ្គលឯកជន ដើម្បីធ្វើអាជីវកម្មលើទ្រព្យសម្បត្តិរដ្ឋ ឬសេវាសាធារណៈដែលពុំមែនជាសេវាអធិបតេយ្យរបស់រដ្ឋ តាមរយៈលិខិត គតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ក្នុងគោលដៅបម្រើសេវាសាធារណៈជូនដល់សាធារណជន ប្រកបដោយ ប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព ដែលមានជាអាទិ៍ ផ្សារ កំពង់ចម្លង ចំណតយានជំនិះ ចំណតជលយាន មជ្ឈមណ្ឌល បែងចែកផលនេសាទ សត្តឃាតដ្ឋាន អនាម័យសត្វ ទីកន្លែងដាក់សំរាម សេវាអនាម័យ និងការរៀបចំសណ្តាប់ធ្នាប់ សាធារណៈ ។ ចំណូលនេះ ត្រូវបានកំណត់ក្នុង ទម្រង់ជាការបែងចែកផល ដែលរដ្ឋនឹងទទួលបានចំណូលអាស្រ័យទៅតាមកំណើនអាជីវកម្មរបស់បុគ្គលឯកជន។

ចំណូលពីធនធានធម្មជាតិជាចំណូលដែលទទួលបានមកពីការចាត់ចែងលើធនធានធម្មជាតិ ជាអាទិ៍ សម្បទាន រ៉ែ ចំណូលពីប្រេងកាត សម្បទានដីសេដ្ឋកិច្ច ផល-អនុផលព្រៃឈើ ផលពីនេសាទ ធនធានកម្រ និងធនធានធម្មជាតិ ដទៃទៀត តាមរយៈលិខិតគតិយុត្តបង្កើតចំណូលមិនមែន

សារពើពន្ធ ក្នុងទម្រង់ជាកម្រៃសួយសារ ឬការបង់ថ្លៃឈ្នួល ឬបុព្វលាភ ឬភាគចំណែករបស់រដ្ឋ ឬការបែងចែកផល ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ជាធរមាន។ ចំណូលផ្សេងៗទៀតដែលមានចែងក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ។

**២.៤.៣.ចំណាយសាធារណៈ**

រាជរដ្ឋាភិបាលកម្ពុជា បានបែងចែកចំណាយសាធារណៈជាពីរផ្នែកធំៗគឺ ចំណាយចរន្ត និង ចំណាយ មូលធន ។ ចំណាយចរន្តរួមមានចំណាយបន្ទុកបុគ្គលិក និងចំណាយមិនមែនបន្ទុកបុគ្គលិក។ រាជរដ្ឋាភិបាល កម្ពុជាបានដាក់ចេញនូវគោលនយោបាយតំឡើងប្រាក់បៀវត្សសម្រាប់មន្ត្រីរាជការដែលធ្វើឱ្យស្ថានភាពប្រាក់ បៀវត្សអប្បបរមាកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ឱ្យសមស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលរយៈ ពេលវែង ជាពិសេសនោះគឺក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នាឆ្នាំ២០៣០ វៀរលែងតែនៅក្នុង ឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជាបន្តរក្សាប្រាក់បៀវត្សអប្បបរមាឱ្យនៅស្មើកម្រិតឆ្នាំ២០២០។ ចំណាយមិនមែន បន្ទុកបុគ្គលិក រួមមានចំណាយវិស័យសង្គមកិច្ច ចំណាយវិស័យរដ្ឋបាលទូទៅ ចំណាយវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ និងចំណាយវិស័យសេដ្ឋកិច្ច។ ចំណាយវិស័យសង្គមកិច្ច នៅតែជា ចំណាយអាទិភាពទីមួយសម្រាប់រាជរដ្ឋាភិបាលក្នុងរយៈពេលកន្លងមកនេះ ដោយផ្តោតទៅលើក្រសួងចំនួនបីគឺ ក្រសួងអប់រំយុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសុខាភិបាល សមស្របតាមគោលនយោបាយរយៈពេលវែងរបស់រាជរដ្ឋាភិបាល។ ចំណាយមូលធន ជាចំណាយវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលជាវិស័យសំខាន់មួយសម្រាប់រាជរដ្ឋាភិបាលកម្ពុជាផងដែរ ហើយចំណាយមូល ធននេះប្រែប្រួល និងកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំអាស្រ័យនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ចំណាយចរន្ត និងចំណាយមូលធន ប្រែប្រួលអាស្រ័យទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលទាំង ក្នុងរយៈពេលខ្លី និងក្នុងរយៈពេលវែង ក៏ប៉ុន្តែជាទូទៅរាជរដ្ឋាភិបាលកម្ពុជាខិតខំនៅក្នុងការបង្កើនចំណាយ សាធារណៈដើម្បីចូលរួមចំណែកនៅក្នុងការអភិវឌ្ឍជាតិឱ្យកាន់តែមានប្រសិទ្ធភាព។ ចំណាយត្រូវបានវិភាជឱ្យសមស្របទៅតាមគោលនយោបាយអភិវឌ្ឍជាតិរបស់រាជរដ្ឋាភិបាល ព្រមទាំងស្ថានភាពសេដ្ឋកិច្ច សង្គម ការអភិវឌ្ឍពីមួយឆ្នាំទៅមួយឆ្នាំហើយអនុម័តឱ្យអនុវត្តតាម

ច្បាប់ ស្តីពីហិរញ្ញវត្ថុសាធារណៈសម្រាប់ការគ្រប់គ្រង ប្រចាំឆ្នាំ និងបទប្បញ្ញត្តិផ្សេងៗអាស្រ័យទៅលើស្ថានភាពជាក់ស្តែងនៃបរិបទសេដ្ឋកិច្ច សង្គមកម្ពុជា និងសកល ភាវូបនីយកម្ម។

## ២.៥.យុទ្ធសាស្ត្រកៀងគរចំណូល

ក្រោយពីប្រទេសកម្ពុជា បានឆ្លងកាត់ដំណាក់កាលប្រែប្រួលដ៏ច្រើនសន្ធឹកសន្ធាប់នៅក្នុងរយៈពេលជាងពីរទសវត្សន៍កន្លងទៅនេះ។ ប្រទេសយើងបានបញ្ចប់ទៅដោយជោគជ័យនូវដំណាក់កាលអន្តរកាលឆ្លងពីរសេដ្ឋកិច្ចផែនការមកជាសេដ្ឋកិច្ចទីផ្សារ ពីរដ្ឋមួយដែលមានគណៈបក្សតែមួយ មកកាន់ប្រព័ន្ធមួយមានពហុបក្ស និងអភិបាលកិច្ចមួយដែលមានលក្ខណៈប្រជាធិបតេយ្យសេរី ពីប្រទេសមួយមានសង្គ្រាម និងវិបត្តិនយោបាយ មកជាប្រទេសមួយមានសុខសន្តិភាពពេញលេញ និងប្រកបដោយចីរភាព។ កម្ពុជាបានបញ្ចប់ជាស្ថាពរនូវទំព័រប្រវត្តិសាស្ត្រខ្មៅងងឹតពីអតីតកាលថ្មីៗរបស់ខ្លួនហើយបោះជំហានទៅរកអនាគតមួយដ៏ភ្លឺស្វាងត្រចះត្រចង់។ យើងបានបិទចោលទាំងស្រុងនូវទំព័រប្រវត្តិសាស្ត្រដ៏ជូចត់ដែលពោរពេញដោយចលាចល អំពើហិង្សា កលិយុគ និងប្រទូស្តរាយ។ព្រឹត្តិការណ៍នេះមិនមែនកើតឡើងដោយឯកឯងនោះទេ។ វាគឺជាលទ្ធផលនៃការគិតគូរទុកជាមុន ដោយដាក់ចេញនូវយុទ្ធសាស្ត្រ និងគោលនយោបាយ ព្រមទាំងកិច្ចខិតខំប្រឹងប្រែងយ៉ាងស្វិតស្វាញ ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រ និងគោលនយោបាយនេះ៕

យ៉ាងណាមិញ ចក្ខុវិស័យប្រកបដោយមហិច្ឆតានេះ និងចលនានៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ឲ្យប្រកបដោយចីរភាពក្នុងបរិការណ៍ថ្មី ទាមទារឲ្យរាជរដ្ឋាភិបាលកម្ពុជាត្រូវតែមានលទ្ធភាព និងសមត្ថភាពខ្ពស់ ទាំងធនធានមនុស្ស និងមូលធន ក្នុងការបន្តលើកិច្ចខិតខំប្រឹងប្រែងការងាររបស់ខ្លួន។ ហេតុនេះ រាជរដ្ឋាភិបាលត្រូវរិះរកមធ្យោបាយ និងយុទ្ធសាស្ត្រឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ដើម្បីកៀរគរចំណូលឲ្យអស់លទ្ធភាព អស់សក្តានុពល និងមានភាពស័ក្តិសិទ្ធក្នុងគោលដៅបង្កើនភាពជាម្ចាស់ក្នុងការងាររបស់ខ្លួន សម្រាប់ទ្រទ្រង់ និងឆ្លើយតបយ៉ាងសមស្របទៅនឹងកំណើន នៃតម្រូវការចំណាយក្នុងគោលដៅសម្រេចឲ្យបាននូវការអភិវឌ្ឍវិស័យអាទិភាពនានា ដូចបានគូសបញ្ជាក់នៅក្នុង **យុទ្ធសាស្ត្រ ចតុកោណ-ដំណាក់កាលទី៣ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៤-២០១៨** ជា

ពិសេសធានាឲ្យបាននូវកំណើនសេដ្ឋកិច្ចជាមធ្យមប្រចាំឆ្នាំ ៧% ឲ្យប្រកបដោយចីរភាព បរិយាបន្ន សមធម៌ និងធន់នឹងវិបត្តិ។

### ២.៥.១.យុទ្ធសាស្ត្រកៀងគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨

យុទ្ធសាស្ត្រកៀងគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ដែរជាផ្នែកមួយនៃការបន្តពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ។ យុទ្ធសាស្ត្រនេះផ្តោតលើគោលការណ៍សំខាន់ចំនួន៤ គឺៈ

១). ប្រមូលឲ្យអស់លទ្ធភាពនូវសក្តានុពលប្រមូលចំណូលដែលមាននាពេលបច្ចុប្បន្ន។

២). មិនបង្កើតប្រភេទពន្ធថ្មី។

៣). មិនដំឡើងអត្រាពន្ធ និងអាករលើកតែក្នុងករណីប៉ះប៉ូវដល់បាត់ចំណូល និងការការពារសុខភាព និងការពារបរិស្ថាន។

៤). ធានាឲ្យបាននូវភាពងាយស្រួល សមធម៌ និងយុត្តិធម៌ ព្រមទាំងធានាប្រសិទ្ធភាព តម្លាភាព

និងគណនេយ្យភាពក្នុងការគ្រប់គ្រង និងការប្រមូលចំណូលការពង្រឹងនូវរដ្ឋបាលចំណូលរបស់ អគ្គនាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើងដើម្បីប្រមូលពន្ធនិងអាករក្នុងស្រុក និងចូលរួមក្នុងការរៀបចំគោលនយោបាយសារពើពន្ធ, សេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រមូលពន្ធ និងអាករ។ កន្លងមក អគ្គនាយកដ្ឋានពន្ធដារបានធ្វើការកែទម្រង់ពេញលេញសំខាន់ៗចំនួន ២ លើក លើប្រព័ន្ធពន្ធដារ គឺនៅឆ្នាំ ១៩៩៤ និងឆ្នាំ ១៩៩៧ ព្រមទាំងការកែទម្រង់ បន្ទាប់បន្សំមួយចំនួនទៀតលើគោលនយោបាយសារពើពន្ធ និងរដ្ឋបាលសារពើ- ពន្ធ។ ជាមួយនឹងការកែទម្រង់ទាំងនេះ ការប្រមូលចំណូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងរយៈពេល ១២ ឆ្នាំ ចុងក្រោយនេះមានការកើនឡើងគួរឱ្យកត់សម្គាល់ ដោយមានអត្រាកំណើនមធ្យមប្រចាំឆ្នាំប្រមាណជាង ២០% (រូបភាព ២)។ ចំណូលពន្ធដារសរុបរបស់អគ្គនាយកដ្ឋានពន្ធដារធៀបនឹង ផសស បានកើនឡើងប្រមាណ ៣ ដង គឺពី ១,៩% នៅឆ្នាំ ២០០២ ដល់ ៥,៨% នៅឆ្នាំ ២០១៣។ ចំណូលពន្ធដារគិតជាសមាមាត្រនៃចំណូលពន្ធសរុបបានកើនពី ២៧% នៅឆ្នាំ ២០០២ ដល់ ៤៦% នៅឆ្នាំ ២០១៣។

សមិទ្ធផលទាំងនេះសម្រេចបានដោយសារកំណើនខ្ពស់របស់ប្រភេទពន្ធសំខាន់ៗដូចជា អាករលើតម្លៃ បន្ថែមក្នុងស្រុក, ពន្ធលើប្រាក់ចំណេញ, អាករពិសេសក្នុងស្រុក, ពន្ធលើប្រាក់បៀវត្សរ៍, និងចំណូលពន្ធពីថ្នាក់ក្រោម ជាតិ។ ក្នុងចំណោមប្រភេទពន្ធទាំងអស់ ដែលប្រមូលដោយអគ្គនាយក ដ្ឋានពន្ធដារ អាករលើតម្លៃបន្ថែមក្នុងស្រុក និង ពន្ធលើប្រាក់ចំណេញបានរួមចំណែកប្រមាណជាង ៦២% នៃចំណូលពន្ធសរុបរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងឆ្នាំ ២០១៣។ ប្រភេទពន្ធទាំងនេះត្រូវបាន រំពឹងថានឹងបន្តល្បឿនកំណើនក្នុងរយៈពេលមធ្យមខាងមុខ ដោយសារកំណើន សេដ្ឋកិច្ចខ្ពស់, កំណែ ទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែ ទម្រង់ ជាបន្តបន្ទាប់ទៀតរបស់អគ្គនាយកដ្ឋានពន្ធដារនាពេលអនាគត។

អគ្គនាយកដ្ឋានពន្ធដារគ្រប់គ្រងការប្រមូលពន្ធតាមមុខងារ និងតាមប្រភេទអ្នកជាប់ពន្ធ។ ការគ្រប់គ្រង តាមមុខងារត្រូវបានបែងចែកជាមុខងារប្រតិបត្តិការស្នូល ដែលរួមមាន : (១)- ការចុះបញ្ជី អ្នកជាប់ពន្ធ, (២)- ការផ្តល់ សេវាអ្នកជាប់ពន្ធ, (៣)- ការចាត់ចែងលិខិតប្រកាស, (៤)- ការធ្វើសវនកម្ម និង (៥)- ការប្រមូលបំណុលពន្ធ និង បណ្តឹងតវ៉ា និងមុខងារគាំទ្រ ដែលរួមមាន: (១) ការពង្រឹងការ គ្រប់គ្រង និងរចនាសម្ព័ន្ធ (២)- ការគ្រប់គ្រង ធនធានមនុស្ស និង (៣)- បច្ចេកវិទ្យាព័ត៌មាន។

ជាមួយគ្នានេះ អ្នកជាប់ពន្ធត្រូវបានបែងចែកជាបីប្រភេទគឺ អ្នកជាប់ពន្ធធំ, អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ ពន្ធតូច។ អ្នកជាប់ពន្ធតំសំដៅដល់សហគ្រាស ដែលជាគម្រោងវិនិយោគមានលក្ខណៈ សម្បត្តិគ្រប់គ្រាន់, សាខា ក្រុមហ៊ុនបរទេស និងសហគ្រាសផ្សេងទៀត ដែលមានផលរបរប្រចាំឆ្នាំចាប់ ពី ១.០០០ លានរៀលឡើងទៅ។ នៅឆ្នាំ ២០១៣ អ្នកជាប់ពន្ធធំទាំងនេះ គឺជាប្រភពចំណូលពន្ធដារ ប្រមាណជា ៨០% នៃចំណូលពន្ធសរុបរបស់អគ្គនាយក ដ្ឋានពន្ធដារ។ ចំណូលពន្ធដែលប្រមូលបាន ពីអ្នកជាប់ពន្ធធំជាងគេទាំង ១០០ ក្រុមហ៊ុនមានសមាមាត្រជាង ៦០% នៃ ចំណូលពន្ធសរុបរបស់អគ្គ នាយកដ្ឋានពន្ធដារ។

អ្នកជាប់ពន្ធមធ្យម គឺសំដៅដល់អ្នកជាប់ពន្ធដែលមានផលរបរប្រចាំឆ្នាំលើសពី ៥០០ លាន រៀល ចំពោះការផ្គត់ផ្គង់ទំនិញ, ផលរបរលើសពី ២៥០ លានរៀលចំពោះការផ្គត់ផ្គង់សេវា ឬផលរបរ

លើសពី ១២៥ លាន រៀល ចំពោះការផ្គត់ផ្គង់ទំនិញ និងសេវាជាមួយរដ្ឋ។ នៅឆ្នាំ ២០១៣ អ្នកជាប់ពន្ធមធ្យមទាំងនេះជាប្រភពចំណូលពន្ធ ប្រមាណ ១៩,៣% នៃចំណូលពន្ធសរុបរបស់អគ្គនាយកដ្ឋានពន្ធដារ។ អ្នកជាប់ពន្ធតូច គឺសំដៅដល់អ្នកជាប់ពន្ធម៉ៅការ ដែលមិនស្ថិតនៅក្នុងអ្នកជាប់ពន្ធធំ និងមធ្យម និងជាប្រភពចំណូលពន្ធប្រមាណ ១,៧% នៃចំណូលសរុបរបស់អគ្គ នាយកដ្ឋានពន្ធដារ។

ជាលទ្ធផល យុទ្ធសាស្ត្រគៀងគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ទទួលបានលទ្ធផលគួរជាទី មោទនៈ។ ចំណូលចរន្តសរុបបានកើនឡើងពី ១៥,៥% នៃផ.ស.សក្នុងឆ្នាំ២០១៣ ទៅ ២២,0% នៃផ.ស.សក្នុង ឆ្នាំ២០១៨។ កំណើននៃចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធនេះ បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងគោលនយោបាយសារពើពន្ធ ព្រោះចំណូលគ្រប់គ្រាន់អនុញ្ញាតិឱ្យរាជរដ្ឋាភិបាលកម្ពុជាសម្រេចនូវការអនុវត្តយុទ្ធ សាស្ត្រចតុកោណដំណាក់កាលទី៣ រួមមានសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងអត្រាជាមធ្យម មួយឆ្នាំ កាត់បន្ថយភាពក្រីក្រ បង្កើនការងារជូនប្រជាពលរដ្ឋ លើកកម្ពស់វិស័យសាធារណៈជាដើម។

### ២.៥.២.យុទ្ធសាស្ត្រគៀងគរចំណូលឆ្នាំ ២០១៩-២០២៣

យុទ្ធសាស្ត្រគៀរគរចំណូល ២០១៩-២០២៣ ជាការបន្តកែទម្រង់ជាយុទ្ធសាស្ត្រ មួយដំណាក់កាលទៀត ដែលកាន់តែមុតស្រួច និងកាន់តែស៊ីជម្រៅ ក្នុងការលើកកម្ពស់សមត្ថភាពរដ្ឋបាលប្រមូលចំណូល, ការបន្តពង្រឹង អភិបាលកិច្ច, ការលើកកម្ពស់គុណភាព, ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃសេវា និងការរៀបចំគោលនយោបាយ សារពើពន្ធ និងមិនមែនសារពើពន្ធ សំដៅលើកកម្ពស់បរិយាកាសធុរកិច្ច, ពង្រឹងភាពប្រកួតប្រជែង និងជំរុញការធ្វើ ពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច និយាយជារួម និងជាឧបករណ៍នៃគោលនយោបាយរបស់រាជរដ្ឋាភិបាលមួយយ៉ាងសំខាន់ ក្នុងការបន្តគៀរគរចំណូលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ដើម្បីបំពេញតម្រូវការហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលសម្រាប់ការអនុវត្តវិធានការកែទម្រង់នានា ជាពិសេសរួមចំណែកក្នុងការអនុវត្តឱ្យចេញជាផ្លែផ្កានូវ កម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ និយាយដោយឡែក ។ យុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងដោយ ប្រកាន់ខ្ជាប់នូវអភិក្រមចំនួន ៤ គឺ÷ (១) ធានាចីរភាពកំណើនសេដ្ឋកិច្ច, (២) រក្សាបាននូវចីរភាពចំណូលដែលឈាន ទៅដល់កម្រិតឧត្តមានុពល, (៣) ធានានូវយុត្តិធម៌ក្នុងការ

អនុវត្តគោលនយោបាយសារពើពន្ធ និងមិនមែនសារពើពន្ធ ព្រមទាំងការប្រមូលចំណូល និង (៤) ធានានូវសមធម៌សង្គម ដើម្បីចូលរួមចំណែកបន្ធូរបន្ថយបន្ទុកពន្ធដល់ប្រជាជន មានចំណូលទាប, បង្កើនសុទ្ធាលភាពប្រជាពលរដ្ឋ និងរក្សាការពារបរិស្ថាន ។

ជារួម យុទ្ធសាស្ត្រនេះមានចក្ខុវិស័យប្រែក្លាយប្រព័ន្ធចំណូលរដ្ឋឱ្យមានលក្ខណៈទំនើប ដែលអាចឆ្លើយតបទៅ នឹងបរិការណ៍នៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជាក្នុងដំណាក់កាលប្រែប្រួលថ្មីមួយទៀត ដោយធ្វើទំនើបភាវូបនីយកម្ម រដ្ឋបាល និងគោលនយោបាយចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ស្របតាមគោលដៅរួមរបស់រាជរដ្ឋាភិបាល គឺ កសាងប្រព័ន្ធរដ្ឋបាលសាធារណៈមួយដែលកាន់តែមានភាពស្អាតស្អំ, ឆ្លាតវៃ និងមានសមត្ថភាពខ្លាំងពូកែ ដើម្បី សម្រេចឱ្យបាននូវឋានៈជាប្រទេសមាន ចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០ ។ ជាងនេះទៅទៀត យុទ្ធសាស្ត្រ នេះបានកំណត់គោលដៅ ២ សំខាន់ៗគឺៈ (១) ប្រមូលចំណូលចរន្តសរុបឱ្យកើនបានយ៉ាងតិច ១,៣ ពិន្ទុភាគរយនៃ ផ.ស.ស. ជាមធ្យមក្នុងមួយឆ្នាំ និង (២) បង្កើនគុណភាពសេវា និងផលិតភាពក្នុងការផ្តល់សេវាគ្រប់ប្រភេទនៃរដ្ឋបាល ប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ។

យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ កំណត់ទស្សនវិស័យវែងឆ្ងាយក្នុងការធ្វើទំនើបភាវូបនីយកម្ម រដ្ឋបាល និងគោលនយោបាយចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ដោយបន្តផ្តោតសំខាន់លើការកសាងរដ្ឋបាល មួយ ដែលមានសមត្ថភាពរឹងមាំ ដើម្បីរួមចំណែកគាំទ្រការងារកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធី កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ សម្រាប់រយៈពេល ៥ ឆ្នាំទៅមុខ យុទ្ធសាស្ត្រកៀរគរចំណូលនេះ នឹងបន្ត ផ្តោតលើការបង្កើនសមត្ថភាពស្ថាប័ន និងធនធានមនុស្ស, ការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងស្របតាមបរិការណ៍ អភិវឌ្ឍន៍ថ្មី, ការពង្រឹងប្រសិទ្ធភាពនៃការសម្របសម្រួលរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ, ការកែសម្រួលនិងដាក់ចេញថ្មីនៃវិធានការគោលនយោបាយដោះស្រាយបញ្ហាប្រឈម, ការបន្តធ្វើវិចារណកម្មគោលនយោបាយសារពើពន្ធ និង មិនមែន សារពើពន្ធ ដើម្បីធានាសង្គតិភាពជាមួយនឹងទិសដៅការកែទម្រង់ និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ជាពិសេសដាក់ចេញ និងផ្សារភ្ជាប់នូវវិធានការដែលមានចរិតយុទ្ធសាស្ត្រជាមួយនឹងសូចនាករសមិទ្ធកម្មគន្លឹះ ដើម្បី ងាយស្រួលត្រួតពិនិត្យ និងវាយតម្លៃ ។

ក្នុងរយៈពេល ៥ ឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្ត យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេល មធ្យម ២០១៤-២០១៨ ប្រកបដោយសមិទ្ធកម្មដ៏ល្អ ទាំងទិដ្ឋភាពការប្រមូលចំណូល, ការកែលំម្អវប្បធម៌បង់ពន្ធ និង ការពង្រឹងរដ្ឋបាលសារពើពន្ធ និងមិនមែនសារពើពន្ធ ។ ជាការពិតណាស់ លទ្ធផលដ៏ត្រចះត្រចង់នៃការអនុវត្ត យុទ្ធសាស្ត្រ កៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ មិនអាចកាត់ផ្តាច់ចេញពីកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួង-ស្ថាប័ន ពាក់ព័ន្ធនឹងការគ្រប់គ្រង និងប្រមូលចំណូល, កិច្ចសហការល្អនិងការចូលរួមពីវិស័យឯកជន ព្រមទាំងដៃគូអភិវឌ្ឍន៍ ។

ក្នុងស្មារតីនេះ ក្នុងនាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាស្ថាប័នដឹកមុខក្នុងការអនុវត្ត និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់, វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ក្នុងការរួមគ្នាសម្រេចបានជោគជ័យដ៏ធំមួយក្នុងការអនុវត្ត យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ និងសូមជំរុញលើកទឹកចិត្តផ្តល់ការគាំទ្រ និងបន្តរួមគ្នាអនុវត្ត ដោះស្រាយបញ្ហាប្រឈមនានាប្រកបដោយបុរសកម្ម និងការតស៊ូក្នុងការជំនះនូវឧបសគ្គ ដើម្បីឱ្យសម្រេចបាននូវចក្ខុវិស័យ, គោលបំណង និងគោលដៅនៃយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ សំដៅចូលរួមគាំទ្រដល់ការអភិវឌ្ឍកម្ពុជានៅក្នុងដំណាក់កាលថ្មី ។

ការអនុវត្តយុទ្ធសាស្ត្រនេះប្រកបដោយប្រសិទ្ធភាព នឹងចូលរួមឆ្លើយតបទៅការកើនឡើងតម្រូវការគុណភាពសេវាអ្នកជាប់ពន្ធកាន់តែខ្ពស់, ការធានាបានសមធម៌សង្គម និងចីរភាពកំណើនចំណូលក្នុងការបំពេញតម្រូវការហិរញ្ញវត្ថុកាន់តែច្រើនសម្រាប់ការអភិវឌ្ឍរបស់កម្ពុជា ដូចដែលបានកំណត់ក្នុង យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ។

## ២.៦.ការអនុវត្តគោលនយោបាយសារពើពន្ធក្នុងកំឡុងពេលវិបត្តិជំងឺកូវីដ១៩

ក្នុងអំឡុងពេលជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយជាបន្ទាន់ដើម្បី ជួយប្រជាជនដែលងាយរងគ្រោះ ព្រមទាំងជួយទ្រទ្រង់វិស័យដែលរងផលប៉ះពាល់ខ្លាំងពីវិបត្តិជំងឺកូវីដ១៩នេះ។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវវិធានការសារពើពន្ធរួមមាន ធ្វើវិចារណកម្មចំណាយនិងពង្រឹងប្រសិទ្ធភាព ចំណាយថវិកាជាតិ អនុគ្រោះនូវកាតព្វកិច្ចសារពើពន្ធមួយចំនួន និងកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ក្រោយ ពេលបិទខ្ទប់ ក្នុងគោលដៅសំដៅស្តារនិងជំរុញកំណើនសេដ្ឋកិច្ច ជាពិសេសធានាបាននូវចីរភាពនៃភាពស៊ាំ សង្គម-សេដ្ឋកិច្ច។

ក្នុងលិខិតលេខ ១៣១៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អ្នកបង់ពន្ធដែលបានចុះបញ្ជីនៅខេត្ត សៀមរាបហើយបើកអាជីវកម្មទាក់ទងនឹងសណ្ឋាគារ ប្រចាំខែទាំងអស់ក្នុងរយៈពេល ៤ និងផ្ទះសំណាក់នឹងត្រូវបានអនុគ្រោះទៅលើការបង់ពន្ធ ខែ គិតចាប់ពីខែកុម្ភៈ ឆ្នាំ២០២០ ដល់ខែឧសភា ឆ្នាំ២០២០ ចំណែកឧស្សាហ កម្មនៅក្នុងវិស័យកាត់ដេរ សម្លៀកបំពាក់ ស្បែកជើង និងកាបូបត្រូវបានលើកលែងពន្ធក្នុងរយៈពេលចាប់ពី ៦ខែ ដោយសារបញ្ហាខ្សែសង្វាក់ផ្គត់ផ្គង់ដែលបណ្តាលមកពីកូវីដ-១៩។ រាជរដ្ឋាភិបាលកម្ពុជាបានបន្តការអនុវត្តនូវ វិធានការបន្ថែម ដើម្បីបន្តគ្រប់គ្រងផលប៉ះពាល់លើវិស័យសំខាន់ៗ ក្នុងការស្តារ និងជំរុញកំណើនសេដ្ឋកិច្ច កម្ពុជាក្នុងអំឡុង និងក្រោយវិបត្តិកូវីដ-១៩ រហូតដល់ចំនួន១០ ជុំ ចាប់តាំងពីដើមឆ្នាំ២០២០ រហូតដល់ដំណាច់ ឆ្នាំ២០២១ ដែលបន្តអនុគ្រោះទៅលើវិស័យដែលទទួលរងផលប៉ះពាល់រួមមានវិស័យកាត់ដេរ-វាយនភណ្ឌ, ស្បែកជើង, ផលិតផលធ្វើដំណើរ, កាបូប វិស័យទេសចរណ៍ និងវិស័យអាកាសចរ។ សម្រាប់រោងចក្រដែលបិទ ទ្វារ និងសម្រាប់កម្មករនិយោជិកដែលត្រូវបានព្យួរពីការងារ រដ្ឋាភិបាលនឹងផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៤០ ដុល្លារ ហើយម្ចាស់រោងចក្រនឹងត្រូវផ្តល់ប្រាក់ ៣០ ដុល្លារបន្ថែមទៀតសរុបចំនួន ៧០ ដុល្លារក្នុងមួយខែសម្រាប់ម្នាក់ៗ។ ចំពោះសណ្ឋាគារ, ផ្ទះសំណាក់, ភោជនីយដ្ឋាន និងក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ ដែលបានចុះបញ្ជីជាមួយអគ្គ នាយកដ្ឋានពន្ធដារ និងមានសកម្មភាពអាជីវកម្ម នៅក្នុងរាជធានីភ្នំពេញ, ខេត្តសៀមរាប, ខេត្តព្រះសីហនុ, ខេត្ត កែប, ខេត្តកំពត, ក្រុងបាវិត និងក្រុងប៉ោយប៉ែត សម្រាប់រយៈពេលបន្តបន្ទាប់និងបន្ត៣ខែបន្ថែមទៀត ពីខែតុលា ដល់ ខែធ្នូ ឆ្នាំ២០២១ តែត្រូវបំពេញកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធអាករ និងប្រើប្រាស់ប្រព័ន្ធអនឡាញ សម្រាប់គ្រប់គ្រងអាករលើតម្លៃបន្ថែម(E-VAT) ជារៀងរាល់ខែ ក្នុងអំឡុងពេលនៃការលើកលែងនេះ។ កម្ពុជាក៏ បានចាប់ផ្តើមកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រួសារក្រីក្រ និងងាយរងគ្រោះចំនួនជិត ២,៣ លាននាក់ ដោយរាជ រដ្ឋាភិបាលត្រូវចំណាយប្រហែល ២៥ លានដុល្លារក្នុងមួយខែ ចាប់តាំងពីខែមិថុនា ឆ្នាំ២០២០ និងបន្តរហូតដល់ ដំណាច់ឆ្នាំ ២០២២ ដោយបន្តពិនិត្យ និងវាយតម្លៃរៀងរាល់៣ខែម្តង។

ចាប់តាំងពីដើមខែមីនា ឆ្នាំ២០២០មក រដ្ឋាភិបាលបានរៀបចំប្រាក់កម្ចីពិសេសតាមរយៈធនាគារអភិវឌ្ឍ ន៍ជនបទ និងកសិកម្ម (ARDB) ចំនួន ៥០ លានដុល្លារ សម្រាប់វិស័យកសិកម្មរួមមានការចិញ្ចឹមសត្វ ការដាំដុះបន្លែ ផ្លែឈើ ការធ្វើវារីវប្បកម្ម និងការកែច្នៃផលិតផលកសិកម្មជាច្រើន។

នៅខែមេសា ឆ្នាំ២០២០រាជរដ្ឋាភិបាលបានបង្កើតជាគម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច ១។ មូលនិធិគម្រោងសហហិរញ្ញប្បទានមានទំហំទឹកប្រាក់សរុបចំនួន រាជរដ្ឋាភិបាលបានចាក់បញ្ចូលទឹកប្រាក់ចំនួន បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍ ។ នៅខែមេសា ឆ្នាំ២០២០ រាជរដ្ឋា និងមធ្យម (SMEs) ដំណាក់កាលទី ១០០ លានដុល្លារអាមេរិក ដែលក្នុងនោះ ៥០ លានដុល្លារតាមរយៈធនាគារសហគ្រាសធុនតូច និងមធ្យម ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល និងទឹកប្រាក់ចំនួន ៥០ លានដុល្លារទៀតត្រូវបានចាក់បញ្ចូលពី គ្រឹះស្ថានហិរញ្ញវត្ថុឯកជនដែលចូលរួមមានចំនួន ៣៣ ស្ថាប័ន។

ក្នុងសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ០០៤ សហវ.អថ រាជរដ្ឋាភិបាលកម្ពុជា សម្រេចធ្វើវិចារណកម្មចំណាយសម្រាប់ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ក្នុងគោលដៅសន្សំ ធនធាន បង្វែរថវិកាសម្រាប់វិស័យអាទិភាព និងទប់ទល់ផលប៉ះពាល់អវិជ្ជមានមកលើសេដ្ឋកិច្ច សង្គម។ ក្នុងឆ្នាំ ២០២១ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចរក្សាកម្រិតប្រាក់បៀវត្សរ៍អប្បបរមារបស់មន្ត្រីរាជការ និងកម្លាំងប្រដាប់ អាវុធឱ្យនៅថេរដូចឆ្នាំ២០២០ ដោយសារតែភាពមិនច្បាស់លាស់នៃជំងឺកូវីដ-១៩ ក្នុងគោលបំណងរក្សាទុកថវិកា សម្រាប់វិស័យចាំបាច់ផ្សេងៗ។ រាជរដ្ឋាភិបាលកម្ពុជាបានកាត់បន្ថយចំណាយមិនចាំបាច់មួយចំនួនផ្សេងទៀត សម្រាប់ចំណាយថវិកាថ្នាក់ជាតិលើសម្ភារៈការិយាល័យ សម្ភារៈប្រើប្រាស់ សម្ភារៈនិងបរិក្ខារបច្ចេកទេសមិនមែន ព័ត៌មានវិទ្យា និងសម្ភារៈនិងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យាជាដើម និងលើកលែងវិចារណកម្មចំណាយចរន្ត សម្រាប់ក្រសួងសុខាភិបាល ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ។ ចំណែកថវិកាថ្នាក់ក្រោមជាតិ មិនត្រូវបាន ធ្វើវិចារណកម្មថវិកាចំណាយនោះទេ។

*ប្រភព៖ 51 Fresh News (ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២) មន្ត្រី៖ មូលនិធិ៥០លានដុល្លាររបស់រដ្ឋាភិបាល តាមរយៈ ARDB សម្រាប់ជួយវិស័យកសិកម្មផ្តល់កម្ចីការប្រាក់ទាបជូនកសិករជិតអស់ហើយ។*
*[https://freshnewsasia.com/index.php/en/business/253853- 2022-08-16-03-32-17.html] (អានថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ២០២៣)*

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, សេចក្តីប្រកាសព័ត៌មានស្តីពីការដាក់ឲ្យដំណើរការ "គម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុន តូច និងមធ្យម*

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២១) សារាចរណែនាំស្តីពីវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយថវិកា ថ្នាក់ជាតិសម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១*

# ជំពូកទី ៣

## ការវិភាគ និងបកស្រាយលទ្ធផលនៃការស្រាវជ្រាវ

### ៣.១.លទ្ធផលនៃការស្រាវជ្រាវ

តារាងទី៨៖ ការបង្ហាញពីទំនាក់ទំនង នៃអរថេរនីមួយ/Correlations

| | ផ.ស.សពិត (Real GDP) | ចំណាយចរន្ត (CUREX) | ចំណាយមូលធន (CAPEX) | ចំណូលសារពើពន្ធ (TR) | អតិផរណា (IFR) |
|---|---|---|---|---|---|
| ផ.ស.សពិត (Real GDP) | ១.<br>១៥ | | | | |
| ច.ណ.រ (CUREX) | 0.៩៨១៥*<br>0.0000<br>១៥ | ១.<br>១៥ | | | |
| ច.ណ.ធ (CAPEX) | 0.៨0៥៩*<br>0.000៣<br>១៥ | 0.៨៦៦0*<br>0.0000<br>១៥ | ១<br>១៥ | | |
| ច.ណ.ព(TR) | 0.៩៨៦១<br>0.0000<br>១៥ | 0.៩៧២៣*<br>0.0000<br>១៥ | 0.៧៨៥៨*<br>0.000៥<br>១៥ | ១<br>១៥ | |

| | | | | | |
|---|---|---|---|---|---|
| អតិផរណា (IFR) | -0.៤៧៦៦<br>0.0៧២៥<br>១៥ | -0.៤៧៦<br>0.0៧២៩<br>១៥ | -0.៦៦៦0*<br>0.00៦៧<br>១៥ | -0.៤១៤១<br>0.១២៤៩<br>១៥ | ១<br><br>១៥ |

តារាង Correlations ខាងលើបានបង្ហាញពីទំនាក់ទំនងរវាងអថេរឯករាជ្យរួមមានចំណាយចរន្ត ចំណាយមូលធន ចំណូលសារពើពន្ធ អត្រាអតិផរណា និងអថេរមិនឯករាជ្យគឺផលិតផលក្នុងស្រុកសរុបពិត។ តាមតារាងនេះ ចំណាយចរន្ត ចំណាយមូលធន និងចំណូលសារពើពន្ធ មានទំនាក់ទំនងវិជ្ជមានខ្លាំងជាមួយនឹង ផលិតផលក្នុងស្រុកសរុបពិត ត្រង់កម្រិតហានិភ័យ ៥% ដូចគ្នាទាំងអស់ ដែលមានន័យថា កាលណាចំណាយ ចរន្ត ចំណាយមូលធន និងចំណូលសារពើពន្ធកើនឡើង នោះផលិតផលក្នុងស្រុកសរុបពិតនឹងកើនឡើងផងដែរ ឬកាលណាចំណាយចរន្ត ចំណាយមូលធន និងចំណូលសារពើពន្ធថយចុះ នោះផលិតផលក្នុងស្រុកសរុបពិត នឹងថយចុះវិញដែរ។ ចំណែកអត្រាអតិផរណាមានទំនាក់ទំនងអវិជ្ជមានជាមួយនឹងផលិតផលក្នុងស្រុកសរុបពិត តែមិនស្ថិតនៅត្រង់កម្រិតហានិភ័យ ១% ៥% និង១0% នោះទេ មានន័យថា កាលណាអត្រាអតិផរណាកើន ឡើង នោះផលិតផលក្នុងស្រុកសរុបពិតថយចុះ ឬពេលអត្រាអតិផរណាថយចុះ នោះផលិតផលក្នុងស្រុកសរុបពិតកើនឡើង។

ដោយសារតែទិន្នន័យមានតម្លៃធំ ធ្វើឱ្យលទ្ធផលនៃការវិភាគមានកំហុសមួយចំនួន ដូចនេះការប្រើ ប្រាស់លោការីតនៅក្នុងការសិក្សាអាចសម្រួលឱ្យទំនាក់ទំនងរវាងអថេរនីមួយ ឱ្យកាន់តែមានភាពល្អប្រសើរ និង សុក្រឹត។ នោះសមីការវិភាគរីហ្គ្រេសស្យុងខាងលើទាញបាន៖

$lnRGDP_1 = Bo + B_1lnCUREX, + B_2lnCAPEX, + B3lnTR, + B_1IFR_1 + \epsilon,$ (សមីការទី២)

បន្ទាប់ពីយើងបានបំលែងទិន្នន័យទៅជាតម្លៃលោការីតរួចហើយ នោះយើងបានតារាងខាងក្រោមដែលបង្ហាញពីការសង្ខេបទាំងមូលសម្រាប់សមីការវិភាគរីហ្គ្រេសស្យុង (Multiple Linear Regression) ទៅលើឥទ្ធិ ពលនៃចំណាយថវិការដ្ឋចរន្ត ចំណាយថវិការដ្ឋមូលធន ចំណូលសារពើពន្ធ និងអត្រាអតិផរណាមកលើ ផលិតផលក្នុងស្រុកសរុបពិត។

## តារាងទី៩៖ លទ្ធផល នៃការវិភាគឥទ្ធិពលចំណាយចរន្ត ចំណាយមូលធន ចំណាយសារពើពន្ធ និងអត្រាអតិផរណា មកលើផលិតផលក្នុងស្រុកសរុបពិត

| Soure | Ss | df | MS |
|---|---|---|---|
| Model | 1.00052665 | 4 | .250131663 |
| Residual | .002700757 | 10 | .00270076 |
| Total | 1.00322741 | 4 | .071659101 |

Number of obs = 15

F (4, 10) = 926.15

Prob > F = 0.0000

R-squared = 0.9973

Adj R-squared = 0.9962

Root MSE = .01643

| InRGDP | Coef. | Std. Err. | t | P>I t I | (95% conf. | Interval) |
|---|---|---|---|---|---|---|
| InCUTEX | .0400782 | .0244465 | 1.64 | 0.132 | -.0143919 | .0945483 |
| InCAPEX | -0.163071 | .0264127 | -0.62 | 0.551 | -.0751582 | .042544 |
| InTR | .3854563 | .0238075 | 16.19 | 0.000 | .3324090 | .4385028 |
| InflationRate | -.0043269 | .0023459 | -1.84 | 0.095 | -.0095539 | .0009001 |

| | | | | | | |
|---|---|---|---|---|---|---|
| _cons | 6.886265 | .160144 | 43.00 | 0.000 | 6.529442 | 7.243088 |

រង្វាស់ស្ថិតិជាច្រើនបានបង្ហាញនៅក្នុងតារាងលទ្ធផលនៃគំរូ Multiple Linear Regression ខាងលើ រួមមាន តារាងANOVA, តារាង Model Fit, និងតារាង Parameter Estimation។

តារាង ANOVA ត្រូវបានបង្ហាញនៅផ្នែកខាងឆ្វេងលើ ដោយក្នុងនោះរួមមានផលបូកការេសរុប (Sum of Squares, SS), ចំនួនដឺក្រេសេរី (Degree of Freedoms, df) និងមធ្យមនៃផលបូកការេ (Mean of Squares, MS)។ ផលបូកការេសរុប (SS) បង្ហាញពីការប្រែប្រួលនៅក្នុងការវិភាគនេះ ហើយការប្រែប្រួលនេះ កើតមានឡើងពីការប្រែប្រួលដែលអាចពន្យល់បាន (Model) និងការប្រែប្រួលដែលមិនអាចពន្យល់បាន (Residual)។ តាមតារាងខាងលើ ការប្រែប្រួលសរុបស្មើនឹង ១.០០៣២២៧៤១ ដែលការប្រែប្រួលនេះស្មើនឹង១,០០០៥២៧ អាចពន្យល់បានដោយអថេរឯករាជ្យឬ Model នេះផ្ទាល់ ចំណែក 0.00២៧ ទៀតនៃការប្រែ ប្រួលនៅក្នុងការសិក្សា ជាការប្រែប្រួលបណ្តាលមកពី Residual ដែលការប្រែប្រួលនេះមិនអាចពន្យល់បាន។

Model fit គឺជាតារាងដែលបង្ហាញពីភាពដែលអាចទទួលយក Multiple Linear Regression Model នៅក្នុងការសិក្សា ហើយវាស្ថិតនៅខាងស្តាំដៃនៃតារាងខាងលើ។ Prob > F គឺជាតម្លៃ P-Value នៃ Model ដែលប្រើប្រាស់សម្រាប់តេស្តទៅលើ R-Squared ដើម្បីបង្ហាញពីលទ្ធភាពនៃការទទួលយក Model ដែលយក មកសិក្សា។ ជាទូទៅ តម្លៃរបស់ P-Value ត្រូវតែតូចជាង ៥% ដើម្បីបង្ហាញថា Model អាចយកមកសិក្សាបា ន។ តាមតារាងខាងលើ កម្រិត Prob > F = 0% តូចជាង ៥% នោះមានន័យថា Multiple Linear Regression Model ដែលយកមកសិក្សាអាចទទួលយកបាន។

R-squared បង្ហាញពីភាពស៊ីគ្នានៃទិន្នន័យដែលយកមកសិក្សា ដែលមានទម្រង់ជាបន្ទាត់ ហើយតម្លៃ របស់វាត្រូវបានកំណត់ពី 0ភាគរយ ដល់ ១០០ភាគរយ។ តម្លៃ R-squared ស្មើ 0% មានន័យថា អថេរមិនឯក រាជ្យ មិនត្រូវបានពន្យល់ដោយអថេរឯករាជ្យនៅក្នុង Model នោះទេ ហើយ

តម្លៃ R-squared ស្មើ ១00% មាន ន័យថាអថេរមិនឯករាជ្យ ត្រូវបានពន្យល់ដោយអថេរឯករាជ្យទាំងស្រុងនៅក្នុងម៉ូដែល។ តាមតារាងខាងលើ តម្លៃ R-squared ស្មើនឹង 0.៩៩៧៣ ឬ ៩៩.៧៣% ដែលមានន័យថា ៩៩.៧៣% នៃការប្រែប្រួលនៃអថេរមិនឯក រាជ្យ ត្រូវបានបកស្រាយឬពន្យល់ដោយអថេរឯករាជ្យ។ ចំណែក Adjusted R-squared (Adj R-squared) បង្ហាញពីបម្រែបម្រួលនៃការពន្យល់អថេរមិនឯករាជ្យ ប្រសិនបើគេបន្ថែមអថេរឯករាជ្យនៅក្នុងការសិក្សា។ តម្លៃ Adjusted R-squared ស្មើនឹង 0.៩៩៦២ ឬ៩៩.៦២% មានន័យថា នៅពេលគេប្រែប្រួលដីក្រេសេរី នោះ មេគុណតម្រែតម្រង់ស្មើនឹង ៩៩.៦២%។

## ៣.២.ការប្រៀបធៀប និងផ្ទៀងផ្ទាត់លទ្ធផលស្រាវជ្រាវ ( Robustness check )

Robustness Check គឺជាវិធីសាស្ត្រនៅក្នុងគំរូ Ordinary Least Square (OLS) ឬ Multiple Linear Regression (MLS) ដើម្បីកាត់បន្ថយនូវឥទ្ធិពលនៃ Outlier ដែលមាននៅក្នុងការសិក្សា ដែលធ្វើឱ្យ លទ្ធផលនៃការសិក្សាប្រែប្រួល។ ម្យ៉ាងវិញទៀត គេប្រើវាដើម្បីលុបចេញនូវឥទ្ធិពលនៃ Residual ដែលមានមក លើអថេរនីមួយៗនៅក្នុងការសិក្សា។

### តារាងទី១០៖ លទ្ធផល នៃការវិភាគឥទ្ធិពល នៃចំណាយចរន្ត ចំណាយមូលធន ចំណូលសារពើពន្ធ និងអត្រាអតិផរណា មកលើផលិតផលក្នុងស្រុកសរុបដោយប្រើ Robustness Check

**Linear Regression**

| | | |
|---|---|---|
| Number of obs | = | 15 |
| F (4, 10) | = | 926.15 |
| Prob > F | = | 0.0000 |
| R-squared | = | 0.9973 |
| Adj R-squared | = | 0.9962 |
| Root MSE | = | .01643 |

| lnRGDP | Coef. | Robust Std. Err. | t | P>I t I | (95% conf. | Interval) |
|---|---|---|---|---|---|---|
| lnCUREX | .0400782 | .0136618 | 2.93 | 0.015 | .0096379 | .0705185 |
| lnCAPEX | -.0163071 | .0328246 | -0.50 | 0.630 | -.0894448 | .0568306 |
| lnTR | .3854563 | .0174863 | 22.04 | 0.000 | .3464943 | .0007683 |
| InflationRate | -.0043269 | .0022868 | -1.89 | 0.088 | -.0094221 | .4244183 |
| _cons | 6.886265 | .2353145 | 29.26 | 0.000 | 6.361952 | 7.410578 |

ជាលទ្ធផលនៃការប្រើប្រាស់ Robustness Check នៅក្នុងសមីការវិភាគ Adj R-Squared នៅក្នុង តារាងលទ្ធផលត្រូវបានដកចេញ ហើយកម្រិតនៃ Standard Error សម្រាប់អថេរចំណាយចរន្ត ចំណាយមូល ធន ចំណូលសារពើពន្ធ អត្រាអតិផរណា និងរាចំនួនថេរថយចុះ រីឯកម្រិតនៃ Standard Error សម្រាប់ចំណាយ មូលធនកើនឡើងវិញ។

## តារាងទី១១៖ ប្រៀបធៀបរវាងការប្រើប្រាស់លោការីត និងមិនប្រើប្រាស់លោការីតនៅក្នុងការវិភាគ ដោយប្រើ Robustness Check

| Variable | Model 1 | Model 2 |
|---|---|---|
| CurrentExp-e | 1.2807087** | |
| CapitalExp-e | -.85387398* | |
| TaxRevenue | .87648001** | |
| InflationR-e | -353.59099** | -.0043269 |
| lnCUREX | | .04007818* |
| lnCAPEX | | -.01630711 |
| lnTR | | .38545631*** |
| _cons | 26239.264*** | 6.8862649*** |

| | | |
|---|---|---|
| N | 15 | 15 |
| r2 | .98731303 | .99730793 |

**Legend: * p<0.05; *** p<0.001**

តារាងខាងលើបង្ហាញពីការប្រៀបធៀបរវាង Model ចំនួន២ ដែល Model1 ប្រើប្រាស់ទិន្នន័យដើម មិន បានបំពាក់លោការីតនៅក្នុងការវិភាគ ចំណែក Model2 ប្រើប្រាស់ទិន្នន័យដែលបានបំពាក់លោការីតរួចហើយ។

តាមតារាងខាងលើយើងឃើញថា តម្លៃ R-squared របស់ Model1 ស្មើនឹង ៩៨.៧៣% ចំណែក Model1 ស្មើ នឹង ៩៩.៧៣% ដែល R-squared កើនឡើងបែបនេះបង្ហាញថាលទ្ធភាពនៃការទទួលយក Model2 ល្អជាង Model1 ដោយសារតែតម្លៃនៃទិន្នន័យទាំងអស់ត្រូវបានបំពាក់លោការីត ដើម្បីកាត់បន្ថយនូវឥទ្ធិពលនៃតម្លៃធំៗ របស់ទិន្នន័យដែលប៉ះពាល់ដល់លទ្ធផលនៃការវិភាគ។ បន្ថែមទៀត មេគុណអថេរនីមួយៗនៅមុនពេលដែល ទិន្នន័យបំពាក់លោការីតស្ថិតនៅក្នុងកម្រិត Significant level ឬ P-Value ទាំងអស់។ ផ្ទុយទៅវិញ នៅពេល យើងបំពាក់លោការីតដើម្បីកាត់បន្ថយនូវបញ្ហាបណ្តាលមកពីតម្លៃទិន្នន័យមួយចំនួនធំៗពេក អត្រាអតិផរណាជាទិន្នន័យមានតម្លៃតូចស្របពេលដែល ពេលនោះលទ្ធផលនៃការវិភាគមានតែមេគុណអថេរពីរតែប៉ុណ្ណោះស្ថិត ក្នុងកម្រិត Significant level ឬ P-Value (មិនរាប់តម្លៃចំនួនថេរចូល)។ ជាលទ្ធផលបន្ទាប់ពីប្រើ Robustness Check គេបានសមីការព្យាករណ៍៖

$lnGDP_1 = \beta + \beta_1 lnCUREX + B_2 lnCAPEX, + \beta3lnTRE + BAIFRE$ $lnGDP = 6.8863 + 0.04lnCUEXP, -0.0163lnCAEXP, + 0.3855lnTR - 0.004/FR,$ (សមីការទី៣)

SE:

0.235315

0.0136618

0.0328246

0.0174863

0.0022868

n=15, R-squared = 0.9973

## ៣.៣. ការបកស្រាយលទ្ធផល

តាមការព្យាករណ៍បានបង្ហាញថាផលិតផលក្នុងស្រុកសរុបពិតមានតម្លៃថេរចំនួន៩៧៨.៧៧៣ ៣ន់ លានរៀល ប្រសិនបើគ្មានកត្តាទាំងបួននេះចូលរួម។

ចំណាយចរន្ត មានទំនាក់ទំនងនិងឥទ្ធិពលវិជ្ជមានជាមួយកំណើនសេដ្ឋកិច្ច ត្រង់កម្រិតហានិភ័យ ១០% ដែលមានន័យថាប្រសិនបើចំណាយចរន្តកើនឡើង ១% នោះផលិតផលក្នុងស្រុកសរុបពិតនឹងកើនឡើង០.០៣៣៤% ឬនៅពេលចំណាយចរន្តកើនឡើង ១ ពាន់លានរៀល នោះផលិតផលក្នុងស្រុកសរុបពិតនឹងកើនឡើង ០.០០០៣៣៤ ពាន់លានរៀល។ លទ្ធផលនៃការសិក្សានេះដូចគ្នាទៅនឹងការសិក្សារបស់ (Fanny OktiviaDenovis, 2014) ដែលបង្ហាញថាចំណាយថវិកាចរន្ត មានឥទ្ធិពលវិជ្ជមានមកលើកំណើនសេដ្ឋកិច្ច។ ជាការពិតណាស់ ចំណាយថវិកាចរន្ត ជាចំណាយទូទៅដែលមានទំនាក់ទំនងជាមួយសកម្មភាពសេដ្ឋកិច្ច ដោយវារួមបញ្ចូលទាំងចំណាយរបស់រដ្ឋលើការទិញទំនិញ និងសេវា មាននូវចំណាយបន្ទុកបៀវត្សបុគ្គលិក ដែលជាចំណូលសម្រាប់បុគ្គល និងគ្រួសារដែលជាផ្នែកមួយនៃតម្រូវការរួម ហើយកាលណាតម្រូវការរួមកើនឡើង សេដ្ឋកិច្ចកើនឡើង។ចំណែកចំណាយមូលធនវិញ មានទំនាក់ទំនង និងឥទ្ធិពលអវិជ្ជមានជាមួយនឹងកំណើនសេដ្ឋកិច្ច។ ក៏ប៉ុន្តែទំនាក់ទំនងនិងឥទ្ធិពលអវិជ្ជមានរបស់ចំណាយមូលធនមកលើកំណើនសេដ្ឋកិច្ចកម្ពុជា ពុំបានមានន័យថាសេដ្ឋកិច្ចភិវឌ្ឍន៍ការកើនឡើងនៃចំណាយមូលធនធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាថយចុះនោះទេ។ លទ្ធផលនៃការសិក្សានេះនេះដូចគ្នាទៅ នឹងការសិក្សារបស់ (Stefanie Garry & Juan Carlon Rivas Valdivia, 2017) ដែលបង្ហាញថាចំណាយ មូលធនអាចមានមេគុណអវិជ្ជមាននៅក្នុងករណីមួយចំនួនដូចជាសម្រាប់ប្រទេស Costa Rica និងប្រទេស Nicaragua និងប្រទេសមួយចំនួនទៀតអាចមានមេគុណចំណាយមូលធនស្មើសូន្យ សម្រាប់ការសិក្សាលើឥទ្ធិ ពលនៃមេគុណចំណាយមូលធនក្នុងរយៈពេលខ្លី អាចបណ្តាលមកពីកម្រិតទាបនៃវិនិយោគសាធារណៈ និង កត្តាផ្សេងៗទៀត រួមមានភាពរឹងនៃច្បាប់ស្តីពីវិនិយោគសាធារណៈ អប្រសិទ្ធភាពនៃចំណាយ គុណភាពនៃការ គ្រប់គ្រងចំណាយ ឥទ្ធិពលនៃ Crowding out ព្រមទាំងវត្ថុធាតុដើមប្រើប្រាស់ក្នុងការវិនិយោគសាធារណៈភាគច្រើនជាទំនិញនាំចូល (Stefanie Garry & Juan Carlon Rivas Valdivia, 2017)។ សម្រាប់ករណី

ប្រទេស កម្ពុជា ចំណាយមូលធននៅមានកម្រិតទាបនៅឡើយ ដែលបណ្ដាលឱ្យកម្រិតវិនិយោគសាធារណៈនៅទាបជា កត្តាធ្វើឱ្យមេគុណរបស់ចំណាយមូលធនសម្រាប់ប្រទេសកម្ពុជាអវិជ្ជមាន។ កម្រិតទាបនៃចំណាយវិនិយោគសាធារណៈឬចំណាយមូលធននេះបណ្ដាលមកពីតម្រូវការចំណាយរបស់រាជរដ្ឋាភិបាលក្នុងវិសចំណាយចរន្តមានទំហំច្រើននៅឡើយដោយសារកម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍន៍មានប្រាក់ចំណូលមធ្យកម្រិតទាប និងទើបតែរួចផុតពីភាពជាប្រទេសក្រីក្រ ដូចនេះចំណាយមូលធននៅមានកម្រិតនៅឡើយ។ អាស្រ័យហេតុនេះ ហើយ ទើបរាជរដ្ឋាភិបាលកម្ពុជាបានខិតខំទាក់ទាញវិនិយោគិនបរទេសដើម្បីសម្រេចបាននូវការវិនិយោគដោយ ផ្ទាល់ (FDI) ព្រមទាំងកៀងគរហិរញ្ញប្បទានលើការវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈនៅកម្ពុជាដោយដៃគូ អភិវឌ្ឍន៍នានា ដើម្បីជម្រុញដល់ការវិនិយោគសាធារណៈក្នុងប្រទេសកម្ពុជា។

ចំពោះចំណូលសារពើពន្ធវិញ ក៏មានទំនាក់ទំនងនិងឥទ្ធិពលវិជ្ជមានមកលើកំណើនសេដ្ឋកិច្ចផងដែរ ត្រង់កម្រិតហានិភ័យ១%។ តាមសមីការព្យាករណ៍ខាងលើមានន័យថា ប្រសិនបើចំណូលសារពើពន្ធកើនឡើង ១% នោះផលិតផលក្នុងស្រុកសរុបនឹងកើនឡើង 0.៣៨៤% ឬនៅពេលចំណូលសារពើពន្ធកើនឡើង ១ ពាន់ លានរៀល នោះផលិតផលក្នុងស្រុកសរុបពិតនឹងកើន 0.00៣៨៤ ពាន់លានរៀល។ លទ្ធផលនៃការសិក្សានេះ ក៏ដូចគ្នាទៅនឹងការសិក្សារបស់ (Fanny Oktivia Denovis, 2014) ដែលបង្ហាញថាចំណូលសារពើពន្ធមានឥទ្ធិ ពលវិជ្ជមានមកលើកំណើនសេដ្ឋកិច្ច។ ឥទ្ធិពលវិជ្ជមាននៃកំណើនចំណូលសារពើពន្ធនេះមានន័យថានៅពេលដែលរាជរដ្ឋាភិបាលកម្ពុជាប្រមូចំណូលសារពើពន្ធបានច្រើន ស្របពេលដែលអត្រាពន្ធនៅដដែល ឬមានការ អនុគ្រោះពន្ធជាច្រើនចាប់តាំងពីឆ្នាំ២00៧ ការលុបចោលនូវពន្ធមួយចំនួន អាចបង្ហាញពីការធានាបាននូវការ ប្រមូលពន្ធប្រកបដោយប្រសិទ្ធភាព សមធម៌ និងយុត្តិធម៌។ កំណើនចំណូលពន្ធនេះហើយជាប្រភពចំណូល ថវិកាជាតិដ៏ធំសម្រាប់រាជរដ្ឋាភិបាលក្នុងការចំណាយប្រចាំឆ្នាំដើម្បីអភិវឌ្ឍជាតិ។ម្យ៉ាងវិញទៀតកំណើនចំណូលសារពើពន្ធនេះ ក៏អាចបង្ហាញពីកំណើននៃសកម្មភាពសេដ្ឋកិច្ច ដែលអាចអនុញ្ញាតឱ្យរាជរដ្ឋាភិបាលប្រមូលពន្ធពីសកម្មភាពទាំងនោះបានច្រើន។

ផ្ទុយទៅវិញអត្រាអតិផរណាមានទំនាក់ទំនងនិងឥទ្ធិពលអវិជ្ជមានមកលើកំណើនសេដ្ឋកិច្ច។ នោះ មានន័យថា កាលណាអត្រាអតិផរណាកើន នោះផលិតផលក្នុងស្រុកសរុបពិតថយចុះ និងផ្ទុយ

មកវិញ។ តាម សមីការព្យាករណ៍ខាងលើ ប្រសិនបើអត្រាអតិផរណាកើនឡើង ១% នោះផលិតផលក្នុងស្រុកសរុបនឹងថយចុះ 0.00២%។ ការរកឃើញនេះ ដូចគ្នាទៅនឹងការរកឃើញរបស់ (Thuo Victoria Wambul, 2013) ដែលបង្ហាញ ថាអតិផរណាមានឥទ្ធិពលអវិជ្ជមានមកលើកំណើនផលិតផលក្នុងស្រុកសរុបពិត។ ជាការពិតណាស់អតិផរណា នឹងធ្វើឱ្យថ្លៃទំនិញ និងសេវានៅក្នុងសេដ្ឋកិច្ចកើនឡើង ធ្វើឱ្យតម្រូវការរួមនៅក្នុងសេដ្ឋកិច្ចថយចុះ ជាលទ្ធផល សេដ្ឋកិច្ចនឹងថយចុះ។ ម្យ៉ាងទៀត ផលិតផលក្នុងស្រុកសរុបពិតបានដកចេញនូវឥទ្ធិពលនៃការប្រែប្រួលថ្លៃ ទំនិញ និងសេវាជារួមនៅក្នុងសេដ្ឋកិច្ច ដែលធ្វើឱ្យផលិតផលក្នុងស្រុកសរុបពិតថយចុះ។ យ៉ាងណាក៏ដោយ អតិផរណាក៏បានចូលរួមចំណែកនៅក្នុងកំណើនសេដ្ឋកិច្ចជាតិដែរ ព្រោះកាលណាបច្ចេកវិទ្យា និងគុណភាព របស់ទំនិញកើនឡើង ថ្លៃទំនិញក៏កើនឡើងផងដែរ ដែលការកើនឡើងនេះមានឥទ្ធិពលល្អសម្រាប់សេដ្ឋកិច្ចជាតិ មិនអាចរាប់ថាជាអតិផរណាបាននោះទេ។

---

** ប្រភព៖ ទិន្នន័យក្រសួងកិច្ច និងហិរញ្ញវត្ថុ*

**ប្រភព៖ ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច៖*

- *សូចនាករសេដ្ឋកិច្ច ២០១៤*
- *សូចនាករសេដ្ឋកិច្ច ២០១៥*
- *សូចនាករសេដ្ឋកិច្ច ២០១៦*
- *សូចនាករសេដ្ឋកិច្ច ២០១៧*
- *សូចនាករសេដ្ឋកិច្ច ២០១៨*
- *សូចនាករសេដ្ឋកិច្ច ២០១៩*

** ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ (២០១០-២០២០) និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០២៣*

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១.សេចក្តីសន្និដ្ឋាន

មុនវិបត្តិកូវីដ-១៩ សេដ្ឋកិច្ចកម្ពុជានៅតែបន្តសម្រេចបានក្នុងអត្រាកំណើនជាមធ្យម ៧% ក្នុង មួយ ឆ្នាំ ដែលចាត់ទុកថាជាប្រទេសមួយដែលមានការអភិវឌ្ឍលឿន។ ក៏ប៉ុន្តែនៅក្នុងឆ្នាំ២០២០ បញ្ហា ជំងឺកូវីដ-១៩ បានជះឥទ្ធិពលអវិជ្ជមានដល់សេដ្ឋកិច្ចពិភពលោក ហើយកម្ពុជាក៏រងឥទ្ធិពលអវិជ្ជមានពី បញ្ហានេះដែរ ដោយ មានអត្រាកំណើនសេដ្ឋកិច្ចអវិជ្ជមាន ៣.១% ដោយសារតែការធ្លាក់ចុះនៃវិស័យ សេវាកម្ម និងវិស័យឧស្សាហ កម្ម ខណៈដែលវិស័យកសិកម្មរក្សាបានកំណើនវិជ្ជមាន។ ចំណែកនៅ ក្នុងឆ្នាំ២០២១ កំណើនសេដ្ឋកិច្ចកម្ពុជា សម្រេចបានក្នុងអត្រាវិជ្ជមានមួយវិញគឺ ៣.០%។ អត្រានៃអ្នក អត់មានការងារធ្វើសម្រេចបានក្នុងអត្រា ០.៣១% ដែលជាអត្រាមួយទាបជាងគេបំផុតនៅក្នុងអាស៊ាន ទោះជាទទួលរងនូវផលប៉ះពាល់ពីជំងឺកូវីដ-១៩ ក៏ដោយ។ រីឯអត្រាអតិផរណានៅកម្ពុជា នៅតែបន្ត សម្រេចបានក្នុងអត្រា២.៩% ក្នុងឆ្នាំ២០២០ និង ៣.៤% ក្នុងឆ្នាំ២០២១ ដែលបង្ហាញពីស្ថិរភាពក្នុង ការគ្រប់អតិផរណានាពេលកន្លងមក។

រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយសារពើពន្ធតាមរយៈច្បាប់ស្តីពីការគ្រប់គ្រង ហិរញ្ញវត្ថុ សាធារណៈប្រចាំឆ្នាំ ដើម្បីធានាដល់ស្ថិរភាពកំណើនសេដ្ឋកិច្ច កាត់បន្ថយនូវភាពក្រីក្រ និង ជំរុញនូវការអភិវឌ្ឍ សេដ្ឋកិច្ចជាតិ។ បន្ថែមទៀត រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រ កំណែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ យុទ្ធសាស្ត្រគៀងគរចំណូល យុទ្ធសាស្ត្រគ្រប់គ្រងបំណុល សាធារណៈជាដើម ដើម្បីសម្រេចបាននូវ គោលដៅក្នុងការក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យម កម្រិតខ្ពស់ក្នុងឆ្នាំ២០៣០។ ក្នុងពេលជួបវិបត្តិសេដ្ឋ កិច្ចបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការគោលនយោបាយ ផ្សេងៗដូចជា ជួយសម្រួលក្នុងការកាត់ បន្ថយថ្លៃដើមតាមរយៈការកាត់បន្ថយថ្លៃ និងធានាស្ថិរភាពនៃការផ្គត់ផ្គង់ អគ្គិសនី កាត់បន្ថយថ្លៃដឹកជ ញ្ជូន។ រាជរដ្ឋាភិបាលកម្ពុជាជួយសម្រួលដល់ពេលវេលា តាមរយៈការបង្កើនការ តភ្ជាប់ឌីជីថល និង

ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបង្កើនភាពងាយស្រួលដល់ការធ្វើអាជីវកម្ម ដោយបន្តពង្រឹងកិច្ច សម្រួលពាណិជ្ជកម្ម ការអនុម័តច្បាប់វិនិយោគថ្មី ច្បាប់ស្តីពីការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស និងច្បាប់ស្តីពីការប្រកួតប្រជែងជាដើម។ បន្ថែមពីនេះទៀតរាជរដ្ឋាភិបាលបន្តការលើកទឹកចិត្តផ្នែកសារពើពន្ធ ដើម្បីលើកកម្ពស់ សហគ្រាសធុនតូច និងមធ្យម និងសហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ពង្រឹងសមត្ថភាពធនធានមនុស្សជាដើម។" ជាលទ្ធផលនៃការអនុវត្តនូវគោលនយោបាយសារពើពន្ធតាមរយៈចំណូលសារពើពន្ធ និង ចំណាយសាធារណៈ ព្រមទាំងបទប្បញ្ញត្តិនានាទាក់ទងនឹងវិស័យហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូល សារពើពន្ធនៅកម្ពុជាបានកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ចំណែកចំណាយសាធារណៈវិញ ក៏កើនឡើងពីមួយ ឆ្នាំទៅមួយឆ្នាំផងដែរ។

ម្យ៉ាងទៀត គោលនយោបាយហិរញ្ញវត្ថុសាធារណៈនេះបានជួយជំរុញនូវសកម្មភាពសេដ្ឋ កិច្ចតាមរយៈការបង្កើនប្រាក់បៀវត្សសម្រាប់បុគ្គលិក បង្កើនចំណាយទៅលើវិស័យសំខាន់ៗរួមមានវិស័យអប់រំ វិស័យសុខាភិបាល វិស័យសង្គមកិច្ចជាដើម ដែលចំណាយបានកើនពី ២៦.០៧% នៃផ.ស.ស ក្នុងឆ្នាំ២០១៩ ទៅ៣០.១៣ % នៃផ.ស.ស ក្នុងឆ្នាំ២០២០ និងថយចុះមកវិញត្រឹម ២៧.១៤% នៃផ.ស.ស ក្នុងឆ្នាំ២០២១។ ចំណាយរបស់រាជរដ្ឋាភិបាលទៅលើវិនិយោគសាធារណៈ ព្រមទាំងការវិនិយោគលើធនធានមនុស្សជាចំណាយ មួយដែលផ្តល់ផលរយៈពេលវែងសម្រាប់សេដ្ឋកិច្ចជាតិ។ ជាពិសេសការអនុគ្រោះនូវពន្ធដារ និងពន្ធគយមួយ ចំនួនបានលើកទឹកចិត្តដល់អ្នករកស៊ី និងការធ្វើពាណិជ្ជកម្មអន្តរជាតិទាំងក្នុង និងក្រៅប្រទេសដែលជំរុញការ នាំចេញ នាំចូលនៅក្នុងប្រទេសកម្ពុជា។

ឆ្លងតាមការសិក្សាខាងលើនេះរួចមក យើងសង្កេតឃើញថាការដាក់ចេញនិងអនុវត្តនូវគោលនយោបាយសារពើពន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា បានចូលរួមចំណែកនៅក្នុងការជំរុញតម្រូវការរួមនៅក្នុងសេដ្ឋកិច្ច ដែលរួមចំណែកនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា (IMF)។ ការគ្រប់គ្រងនូវចំណាយសាធារណៈរួមមាន ចំណាយមូលធន និងចំណាយចរន្ត និងការគ្រប់គ្រងនូវការប្រមូលចំណូលសារពើពន្ធឱ្យមានប្រសិទ្ធភាពតាម យុទ្ធសាស្ត្រកៀងគរចំណូល តែមិនបង្កើតពន្ធថ្មីសម្រាប់ជាបន្ទុកដល់ប្រជាពលរដ្ឋ បានចូលរួមចំណែកយ៉ាង ច្រើននៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ កាត់បន្ថយនូវភាពក្រីក្រ និងចូលរួមដោះស្រាយបញ្ហាវិបត្តិសេដ្ឋកិច្ចនានា ផងដែរ។ យ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលកម្ពុជានៅតែ

បន្តជួបនូវបញ្ហាឱនភាពថវិកាជាតិ ដែលជាបន្ទុក សម្រាប់រាជរដ្ឋាភិបាលក្នុងការធ្វើកម្ចីពីបរទេស។ ប៉ុន្តែជាដំណោះស្រាយសម្រាប់ធានាដល់ហានិភ័យ និងចីរភាព នៃបំណុល បញ្ហានេះត្រូវបានគ្រប់គ្រង និងដោះស្រាយដោយយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ដែល ធានាមិនឱ្យអនុបាតបំណុលសាធារណៈក្រៅប្រទេសលើស ៤០% នៃផ.ស.ស និងបំណុលសាធារណៈក្នុង ស្រុកលើស ១៥% នៃផ.ស.ស។

## ២.អនុសាសន៍

ដើម្បីធ្វើឱ្យការអនុវត្តគោលនយោបាយសារពើពន្ធកាន់តែមានប្រសិទ្ធភាព ជាពិសេសទៅលើការអនុវត្ត គោលនយោបាយចំណាយសាធារណៈ និងការប្រមូលចំណូលសារពើពន្ធ ក្នុងគោលដៅជំរុញកំណើនសេដ្ឋកិច្ច ជាតិ កាត់បន្ថយនូវភាពក្រីក្រ និងឈានទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ រាជ រដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងពាក់ព័ន្ធនានាគួរពិនិត្យមើលលើជម្រើសគោលនយោបាយនានាដូចជាៈ

១. រាជរដ្ឋាភិបាលកម្ពុជា គួរតែដាក់គោលនយោបាយយ៉ាងណាបន្តរក្សានូវអត្រាអតិផរណាឱ្យមានស្ថិរ ភាព និងអត្រាទាបមួយដែលល្អសម្រាប់កំណើនសេដ្ឋកិច្ចកម្ពុជា ដើម្បីធានានូវស្ថិរភាពថ្លៃទំនិញ និងសេវានៅ ក្នុងសេដ្ឋកិច្ច។

២. រាជរដ្ឋាភិបាលកម្ពុជាគួរបន្តជំរុញនូវចំណាយសាធារណៈ រួមមានចំណាយចរន្ត និងចំណាយមូល ធនដើម្បីធានាដល់ការអភិវឌ្ឍ និងតម្រូវការរួមនៅក្នុងសេដ្ឋកិច្ចមានគ្រប់គ្រាន់។ រាជរដ្ឋាភិបាលគួរតែបន្តបង្កើន ចំណាយចរន្តរួមមានបន្ទុកបុគ្គលិក និងបន្ទុកផ្សេងៗទៀតដែលធានាដល់សកម្មភាពសេដ្ឋកិច្ច និងផលិតកម្ម។ បន្ថែមទៀត រាជរដ្ឋាភិបាលកម្ពុជាគួរតែបន្តពង្រឹងចំណាយមូលធន ឱ្យបានកាន់តែប្រសើរជាងមុន ព្រោះចំណាយ មូលធនហាក់មានកម្រិតនៅឡើយ ជាពិសេសពិនិត្យផែនការថវិកាជាតិឡើងវិញដែលអាចនាំឱ្យមានការវិចារណ កម្មនៃការចំណាយសាធារណៈ។ ចំណាយមូលធនកើនឡើង ធានាឱ្យការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារ ណៈកើនឡើង ហើយកាលណាចំណាយវិនិយោគសាធារណៈកើនឡើង គុណភាពនៃការរស់នៅរបស់ប្រជាជន កើនឡើង ជាពិសេសបានចូលរួមកាត់បន្ថយនូវភាពអត់មានការងារធ្វើបានថែមទៀត។ ការបង្កើនតម្រូវការរួមនៅ

ក្នុងសេដ្ឋកិច្ច ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្សនេះហើយ នឹងអនុញ្ញាតឱ្យកម្ពុជាសម្រេច បាននូវគោលដៅឆ្ពោះទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នាឆ្នាំ២០៣០។

៣. រាជរដ្ឋាភិបាលកម្ពុជា គួរបន្តប្រឹងប្រែងនៅក្នុងការប្រមូលចំណូលសារពើពន្ធពីប្រភពសំខាន់ៗ ជាជាងការអនុវត្តនូវប្រភេទពន្ធបន្ថែមទៀត។ ការប្រមូលចំណូលសារពើពន្ធពីប្រភពសំខាន់ៗអាចធានាបាននូវ យុត្តិធម៌ សមធម៌ និងប្រសិទ្ធភាពនៃការប្រមូលចំណូលសារពើពន្ធ ដែលជាប្រភពទ្រទ្រង់នូវចំណូលថវិកាជាតិ។ ចំណូលសារពើពន្ធ មានឥទ្ធិពលវិជ្ជមានមកលើកំណើនសេដ្ឋកិច្ចជាតិដែលធានាដល់ការអនុវត្តនូវគោល នយោបាយចំណាយប្រចាំឆ្នាំ ដើម្បីជំរុញដល់កំណើនសេដ្ឋកិច្ចពីមួយឆ្នាំទៅមួយឆ្នាំ។ម្យ៉ាងទៀត ការពង្រឹងការ ប្រមូលចំណូល អាចអនុញ្ញាតឱ្យរាជរដ្ឋាភិបាលកម្ពុជា ធានានូវចំណូលថវិកាជាតិសរុបក្នុងពេលដែលរាជរដ្ឋា ភិបាលដាក់ចេញនូវគោលនយោបាយអនុគ្រោះពន្ធសម្រាប់វិស័យមួយចំនួន សម្រាប់ផលិតកម្មក្នុងស្រុកធានា ដល់ការប្រកួតប្រជែងជាមួយបរទេស និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនឱ្យបានកាន់តែល្អប្រសើរ។ជាចុងក្រោយ ដើម្បីអាចបញ្ជាក់អំពីការអនុវត្តនូវគោលនយោបាយសារពើពន្ធឱ្យកាន់តែច្បាស់ថែមទៀត នោះ ការអនុវត្តគួរតែប្រកបដោយប្រសិទ្ធភាព សមធម៌ និងយុត្តិធម៌។ សម្រាប់ការសិក្សាបន្តបន្ទាប់ទៀតទៅលើ ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធ ការសិក្សាគួរតែផ្តោតទៅលើឥទ្ធិពលនៃចំណាយតាមវិស័យសំខាន់ៗ ព្រមទាំងចំណូលសារពើពន្ធពីប្រភពសំខាន់ៗចូលនៅក្នុងការវិភាគផងដែរ។

---

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖*

*៖សូចនាករសេដ្ឋកិច្ច ២០២០-២០២១*

*ប្រភព៖ ការវាយតម្លៃនិងការព្យាករកំណើនសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០២១-២០២២*

# ឯកសារយោង

## ឯកសារយោងជាភាសាខ្មែរ


ប្រភពទិន្នន័យក្រសួងកិច្ច និងហិរញ្ញវត្ថុ៖ (ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | Ministry of Economy and Finance (mef.gov.kh)

នាយកដ្ឋានថវិកានីយកម្ម នៃអគ្គនាយកដ្ឋានថវិកា របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ថវិកាសង្ខេប ឆ្នាំ២០២២, ទំព័រទី ៥-១៨។

អង្គការទិន្នន័យអំពីការអភិវឌ្ឍ (ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០) លោកនាយករដ្ឋមន្ត្រីអំពាវនាវឱ្យក្រសួងកាត់បន្ថយចំណាយចំពេលចំណូលពន្ធទាប [https://opendevelopmentcambodia.net/km/news/prime-minister-calls-for-ministries-to-cut-spending- amid-lower-tax-revenue/#!/story=post-141801] (អានថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៣) ។

ទីស្តីការគណៈរដ្ឋមន្ត្រី (ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០) សម្រង់ប្រសាសន៍សម្តេចតេជោ ហ៊ុន សែន, ពិធីប្រកាសដាក់ឱ្យដំណើរការជា ផ្លូវការ - កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលជំងឺ កូវីដ ១៩ - [https://pressocm.gov.kh/archives/66496] (អានថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២៣)។

បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជាឆ្នាំ ២០២២ (The World Bank) **សូចនាការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ADB (2022) ទស្សនៈវិស័យអភិវឌ្ឍអាស៊ី-ប្រទេសកម្ពុជា PPS//www.adb.org/sites/default/Nes related AD02022- Cambodia-Chapter-Khmer 5, po (អានថ្ងៃទី១៣ ខែមិថុនា ឆ្នាំ ២០២៣។

សេចក្តីប្រកាសព័ត៌មាន (ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា) COUNCIL FOR THE DEVELOPMENT OF CAMBODIAថ្ងៃពុធ ៧រោច ខែមិគសិរ ឆ្នាំថោះបញ្ចាស័ក ព.ស ២៥៦៧ រាជធានីភ្នំពេញ ថ្ងៃទី៣ ខែមករា ឆ្នាំ២០២៤។

- របាយការណ៍ បូកសរុបលទ្ធផលការងារពាណិជ្ជកម្មឆ្នាំ២០២១-២០២២ (ទំព័រទី៨)
- របាយការណ៍ បូកសរុបលទ្ធផលការងារពាណិជ្ជកម្មឆ្នាំ២០២១-២០២២ (ទំព័រទី៩)
- របាយការណ៍ បូកសរុបលទ្ធផលការងារពាណិជ្ជកម្មឆ្នាំ២០២១-២០២២ (ទំព័រទី១០)

ប្រភពនាយកដ្ឋាននាំចេញ នាំចូល៖ តួលេខនាំចេញនេះ ជាតួលេខដែលទទួលបាន 51 Fresh News (ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២) មន្ត្រី៖ មូលនិធិ៥០លានដុល្លាររបស់រដ្ឋាភិបាល តាមរ

យៈ ARDB សម្រាប់ជួយវិស័យកសិកម្មផ្តល់កម្ចីការប្រាក់ទាបជូនកសិករជិតអស់ហើយ។ [https://freshnewsasia.com/index.php/en/business/253853- 2022-08-16-03-32-17.html] (អានថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣)។
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, សេចក្តីប្រកាសព័ត៌មានស្តីពីការដាក់ឲ្យដំណើរការ "គម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុន តូច និងមធ្យមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២១) សារចរណែនាំស្តីពីវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយថវិកា ថ្នាក់ជាតិ សម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖ សូចនាករសេដ្ឋកិច្ច ២០២០-២០២១

# ឧបសម្ព័ន្ធ

## ទិន្នន័យសូចនាករសេដ្ឋកិច្ច ២០១៤ - ២០១៥

| សូចនាករសេដ្ឋកិច្ច | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|
| | អនុវត្ត | ប៉ាន់ស្មាន | ព្យាករណ៍ |
| ផសស តាមថ្លៃបច្ចុប្បន្ន (ប៊ីលានរៀល) | ៦៧ ៧៤០ | ៧៤ ៩៣២ | ៨១ ៩៣៤ |
| កំណើនពិតនៃ ផសស (%) | ៧,១% | ៦,៩% | ៧,០% |
| ផសស សម្រាប់មនុស្សម្នាក់ (ដុល្លារអាមេរិក) | ១ ១៣៨ | ១ ២២៨ | ១ ៣២៨ |
| អតិផរណា (ជាមធ្យមប្រចាំឆ្នាំ) | ៣,៩% | ៣,០% | ៣,៥% |
| អត្រាប្តូរប្រាក់ (ដុល្លារអាមេរិក/រៀល) | ៤ ០៣៩ | ៤ ០៥០ | ៤ ០៥០ |
| សមតុល្យគណនីចរន្ត (% នៃ ផសស) | -៩,៧% | -៨,៧% | -៩,៧% |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាមេរិក) | ៤ ៣៨២ | ៤ ៩២៦ | ៥ ៧៣៩ |
| ទុនបម្រុងអន្តរជាតិ (ចំនួនខែនៃការនាំចូល) | ៤,៣ | ៤,៥ | ៤,៥ |

# ទិន្នន័យសូចនាករសេដ្ឋកិច្ច ២០១៦-២០១៧

| សូចនាករសេដ្ឋកិច្ច | ២០១៦ | ២០១៧ | ២០១៨ |
| --- | --- | --- | --- |
| | អនុវត្ត | ប៉ាន់ស្មាន | ព្យាករណ៍ |
| ផសស តាមថ្លៃបច្ចុប្បន្ន (ប៊ីលានរៀល) | ៨០ ៥៥៨ | ៨៩ ៥០៩ | ៩៩ ១១៦ |
| កំណើនពិតនៃ ផសស (%) | ៧, ០% | ៦, ៩% | ៦, ៩% |
| ផសស សម្រាប់មនុស្សម្នាក់ (ដុល្លារអាមេរិក) | ១ ៣០២ | ១ ៤៣៥ | ១ ៥៦៨ |
| អតិផរណា (ជាមធ្យមប្រចាំឆ្នាំ) | ៣, ០% | ៣, ៨% | ៣, ៥% |
| អត្រាប្តូរប្រាក់ (ដុល្លារអាមេរិក/រៀល) | ៤ ០៥៦ | ៤ ០៣៧ | ៤ ០៣៧ |
| សមតុល្យគណនីចរន្ត (% នៃ ផសស) | -៨, ៣% | -៧, ៩% | -៨, ៤% |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាមេរិក) | ៦ ៧៣១ | ៩ ០៥០ | ១០ ៥១៨ |
| ទុនបម្រុងអន្តរជាតិ (ចំនួនខែនៃការនាំចូល) | ៥, ៥ | ៦, ០ | ៦, ៥ |

# ទិន្នន័យសូចនាករសេដ្ឋកិច្ច ២០១៧-២០១៨

| សូចនាករសេដ្ឋកិច្ច | ២០១៧ | ២០១៨ | ២០១៩ |
|---|---|---|---|
| | អនុវត្ត | ប៉ាន់ស្មាន | ព្យាករណ៍ |
| ផសស តាមថ្លៃបច្ចុប្បន្ន (ប៊ីលានរៀល) | ៨៩ ៦៤៧ | ៩៩ ៣៣២ | ១០៩ ៨៩៥ |
| កំណើនពិតនៃ ផសស (%) | ៧,០% | ៧,០% | ៧,១% |
| ផសស សម្រាប់មនុស្សម្នាក់ (ដុល្លារអាមេរិក) | ១ ៤២៧ | ១ ៥៦៣ | ១ ៧០៦ |
| អតិផរណា (ជាមធ្យមប្រចាំឆ្នាំ) | ២,៩% | ៣,៤% | ៣,១% |
| អត្រាប្តូរប្រាក់ (ដុល្លារអាមេរិក/រៀល) | ៤ ០៤៥ | ៤ ០៣៧ | ៤ ០៣៧ |
| សមតុល្យគណនីចរន្ត (% នៃ ផសស) | -៦,៩% | -៧,៣% | -៧,១% |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាមេរិក) | ៨ ៧៥៨ | ៩ ៤៩៤ | ១១ ០៥៩ |
| ទុនបម្រុងអន្តរជាតិ (ចំនួនខែនៃការនាំចូល) | ៦,៤ | ៦,២ | ៦,៥ |

# ទិន្នន័យសូចនាករសេដ្ឋកិច្ច ២០១៨-២០១៩

| សូចនាករសេដ្ឋកិច្ច | ២០១៨ | ២០១៩ | ២០២០ |
| --- | --- | --- | --- |
| | អនុវត្ត | ប៉ាន់ស្មាន | ព្យាករណ៍ |
| ផសស តាមថ្លៃបច្ចុប្បន្ន (ប៊ីលានរៀល) | ៩៨ ៧៨៦ | ១០៨ ៥៩០ | ១១៩ ០៣៤ |
| កំណើនពិតនៃ ផសស (%) | ៧,៥% | ៧,១% | ៦,៥% |
| ផសស សម្រាប់មនុស្សម្នាក់ (ដុល្លារអាមេរិក) | ១ ៥៤៨ | ១ ៦៧៩ | ១ ៨១៦ |
| អតិផរណា (ជាមធ្យមប្រចាំឆ្នាំ) | ២,៥% | ២,៨% | ២,៩% |
| អត្រាប្តូរប្រាក់ (ដុល្លារអាមេរិក/រៀល) | ៤ ០៥៣ | ៤ ០៥៤ | ៤ ០៥៤ |
| សមតុល្យគណនីចរន្ត (% នៃ ផសស) | -១០,៧% | -៩,៦% | -៩,៣% |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាមេរិក) | ១០ ០៥២ | ១១ ៥០៥ | ១៣ ០០៧ |
| ទុនបម្រុងអន្តរជាតិ (ចំនួនខែនៃការនាំចូល) | ៥,៦ | ៥,៨ | ៦,១ |